**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: កញ្ញា **អេន សៀវយី**

កញ្ញា **សារ៉ាត់ ច័ន្ទពេជ្រសកល**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញឹក ទុធ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលៃលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និសិ្សតឈ្មោះ  កញ្ញា **អេន សៀវឃី**
កញ្ញា **សារ៉ាត់ ច័ន្ទពេជ្រសគល**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ញឹក ទុធ្នី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សារ៉ាត់ ច័ន្ទពេជ្រសកល** និង **ឈ្មោះ អេន សៀវយី** ជានិស្សិតជំនាន់ទី២៣ ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា២០១៩-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមយើងខ្ញុំទាំងពីររូប សូមសម្តែងនូវគារវកិច្ចដឹងគុណ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណគឺ ៖ - លោកឪពុក **សោម សំអឿន** និងអ្នកម្តាយ **គង់ កែវចស្សស៊ីដែត**

- លោកឪពុក **សំ ណូ** និងអ្នកម្តាយ **ពាន ហ៊ុយណា**

ដែលបានផ្តល់កំណើត ផ្គត់ផ្គង់ ចិញ្ចឹមបីបាច់ថែរក្សាកូនដោយ ក្តីមេត្តា ករុណានិង ផ្តល់នូវ ក្តីស្រលាញ់ ភាពកក់ក្តៅគ្រប់បែបយ៉ាងតាំងពីកូនតូចរហូតដល់ធំ ដោយរូបលោកបានធ្វើការប្រឹងប្រែង លះបង់ទាំកាយចិត្ត ទាំងធនធាន ទំនុកបម្រុងគ្រប់សព្វ ទាំងផ្នែកស្មារតីនិងសម្ភារៈ ព្រមទាំងឧបត្ថម្ភការសិក្សាដល់រូបកូន ដើម្បីបាន រៀនសូត្រក្រេបយកនូវចំណេះវិជ្ជា។ លោកបានអប់រំទូន្មានកូនអោយប្រកបទៅដោយគន្លងធម៌ បណ្តុះគំនិត លើកទឹកចិត្តកូនអោយប្រកាន់ខ្ជាប់នូវកតញ្ញូតាធម៌ចំពោះអ្នកមានគុណ និងបង្រៀនកូនអោយក្លាយទៅជាប្រជា ពលរដ្ឋល្អក្នុងសង្គម។ ក្រៅពីនេះ លោកតែងលើកទឹកចិត្តកូនអោយមានភាពអង់អាចក្លាហាន ហ៊ានពុះពារជម្នះ នូវរាល់ឧបសគ្គទាំងឡាយនៅក្នុងជីវិត ហើយប្រព្រឹត្តតែអំពើល្អ ប្រកបដោយគុណធម៌ និង ភាពស្មោះត្រង់។

សូមគោរពថ្លែងអំណរគុណជាពិសេស ទៅដល់ លោកសាស្ត្រាចារ្យជំនួយ **ញឹក ឧត្តម** ដែលលោកបាន ចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការដឹកនាំ រំលឹក ផ្តល់នូវមតិយោបល់ល្អៗ និង យកចិត្តទុកដាក់ក្នុងការ បង្ហាត់បង្ហាញ ពន្យល់ ណែនាំអស់ពីកម្លាំងកាយចិត្តដល់យើងខ្ញុំទាំងពីររូប អោយកាន់តែមានភាពងាយស្រួល ក្នុងការសរសេរនូវសារណាមួយនេះឡើង។

លើសពីនេះ យើងខ្ញុំ ក៏សូមថ្លែងអំណរគុណទៅដល់ **ឯកឧត្តម សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែល បានផ្តល់ឱកាសអោយយើងខ្ញុំទាំងពីររូបបានចូលសិក្សាទទួលនូវចំណេះដឹង ពីជំនាញដែលយើងបានសិក្សា ជា ពិសេសបានជំរុញលើកទឹកចិត្តយើងខ្ញុំអោយខិតខំប្រឹងប្រែងរៀនសូត្រ និងអនុញ្ញាតអោយនិស្សិតក្នុងការសរសេរ សារណា ក្នុងគោលបំណងពង្រឹងនូវការយល់ដឹងបន្ថែមរបស់និស្សិត។

ជាចុងបញ្ចប់ យើងខ្ញុំសូមធ្វើការបួងសួងទៅដល់វត្ថុស័ក្តិសិទ្ធិទាំឡាយ ជូនដល់លោក ឪពុក អ្នកម្តាយ ឯកឧត្តមលោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និង មិត្តទាំងឡាយ សូមអោយជួបតែ សេចក្តីសុខ សុខភាពល្អ ជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើង។

# **អារម្ភកថា**

អាពាហ៍ពិពាហ៍គឺ កើតចេញពីមនុស្សពីរអ្នកពីរនាក់ដែលយល់ព្រមស្ម័គ្រចិត្តថានឹងកាន់ដៃគ្នាកសាងនូវចំណងអាពាហ៍ពិពាហ៍មួយ ហើយបង្កើតបាននូវគ្រួសារមួយដែលជាកោសិការបស់សង្គម ប្រកបទៅដោយសុភមង្គល សុខដុមរមនា និងចុំចើ្កនរុងរឿង។ នេះជាបំណងប្រាថ្នារបស់មនុស្សគ្រប់រូប ប៉ុន្តែទន្ទឹមនឹងនេះក៏មានចំណងអាពាហ៍ពិពាហ៍ដែលមិនសមបំណងផងដែរ គឺនៅពេលមួយដែលពួកគេមិនមានឆន្ទៈក្នុងការរក្សានូវចំណងអាពាហ៍ពិពាហ៍មួយនោះបន្តទៀត ដោយសារការកើតឡើងនូវបញ្ហាផ្សេងៗ ដែលមិនអាចស្តាឡើងវិញបាន បណ្តាលអោយមិនអាចបន្តរួមរស់នឹងគ្នាបាន ពេលនោះនឹងមានការលែងលះកើតឡើងមក។ ជាក់ស្តែងដោយសារតែក្នុងប្រទេសកម្ពុជាយើងផ្ទាល់ តែងតែជួបប្រទះនូវបញ្ហានេះជារឿយៗ ហើយប្រជាពលរដ្ឋហាក់ពុំទាន់យល់ដឹងបានច្រើន ហើយមានភាពខ្សត់ខ្សោយទាក់ទិននឹងការលែងលះនៅឡើយ។ ដូចនេះហើយ យើងខ្ញុំយល់ឃើញថា បុគ្គលគ្រប់រូប ពិសេសគឺបុគ្គលដែលស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ដែលមានភាពមិនចុះសម្រុង មានបញ្ហារកាំរកូស ហើយមានបំណងចង់ផ្តាច់នូវ ចំណងអាពាហ៍ពិពាហ៍មួយនោះ គួរតែជ្រាបក៏ដូចជាយល់ដឹងបន្ថែមអោយបានកាន់តែច្បាស់អំពីការលែងលះ ។

ទាំងនេះហើយ ជាហេតុដែលយើងខ្ញុំទាំងពីរបានជ្រើសរើសនូវប្រធានបទ "**ការលែងលះ**" នេះមករៀបចំសិក្សាស្រាវជ្រាវ ចងក្រងជាសៀវភៅសារណា ដើម្បីទុកជាស្នាដៃនៃការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រយ៉ាងណាមិញ ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណាមួយនេះ យើងខ្ញុំពិតជាបានខិតខំព្យាយាម និងយកចិត្តទុកដាក់ស្រាវជ្រាវនូវរាល់ឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីយកមកចងក្រងជាសៀវភៅសារណា ដែលមានដូចជា ច្បាប់ បទដ្ឋានគតិយុត្ត សេចក្តីកំណត់មាត្រាច្បាប់ សៀវភៅសាស្ត្រាចារ្យ សៀវភៅសារណា និងវេបសាយដែលពាក់ព័ន្ធធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវ ។

ដោយឡែក យើងខ្ញុំសង្ឃឹមថា សារណាមួនេះនឹងអាចឆ្លើយតបទៅនឹងតម្រូវការនិងអាចជាចំណែកមួយក្នុងការជួយសម្រួលដល់ប្រជាពលរដ្ឋទាំងឡាយអោយកាន់តែជ្រាបច្បាស់និង យល់ដឹងបន្ថែម អំពីការលែលះ។ ហើយក៏នឹងអាចជាក្លាយការសិក្សាស្រាវជ្រាវ និងឯកសារ ដែលជាជំនួយទៅដល់សិស្សនិស្សិតជំនាន់ក្រោយ ជាពិសេសគឺនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្នុងកាស្វែងយល់បន្ថែមទាក់ទងទៅនឹងប្រធានបទ "**ការលែងលះ**" នេះ ។

យើងខ្ញុំក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយណា ឬ មានចំណុចខ្វះខាតក្នុងប្រការណាមួយដោយអចេតនាចំពោះពាក្យពេចន៍ ក៏ដូចជាអក្ខរាវិរុទ្ធដែលមានក្នុងកិច្ចការស្រាវជាវមួយនេះ ហើយយើងខ្ញុំនឹងទទួលស្វាមគមន៍ជានិច្ចរាល់ការរិះគន់ក្នុងន័យស្ថាបនានូវចំណេះដឹងរបស់យើងខ្ញុំ ដើម្បីបំពេញចំណុចខ្វះខាត និងកែលំអរអោយល្អប្រសើរជាងមុន។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការលែងលះ**

**ផ្នែកទី១. សញ្ញាណនៃការលែងលះ** ........ ៣

**កថាភាគទី១. និយមន័យ** ........ ៣

១. អាពាហ៍ពិពាហ៍ ........ ៣

២. ការលែងលះ ........ ៤

**កថាភាគទី២. ប្រភេទនៃការលែងលះ** ........ ៤

១. ការលែងលះដោយមានការព្រមព្រៀង ........ ៤

២. ការលែងលះដោយមិនមានការព្រមព្រៀង ........ ៥

**ផ្នែកទី២. មូលហេតុនៃការលែងលះ** ........ ៦

១. ការប្រព្រឹត្តនូវអំពើផិតក្បត់ទៅលើសហព័ទ្ធ ........ ៦

២. ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុ ........ ៧

៣. ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាង ១ ឆ្នាំ ........ ៧

៤. ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ ឆ្នាំ ........ ៧

៥. ករណីផ្សេងៗដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ........ ៨

**ជំពូកទី២**

**នីតិវិធីនៃការលែងលះ**

**ផ្នែកទី១. ការផ្តើមនៃបណ្តឹង** ........ ១០

**កថាភាគទី១. ការដាក់ពាក្យបណ្តឹងសុំលែងលះ** ........ ១០

**កថាភាគទី២. សមត្ថកិច្ចដោះស្រាយតាមរយៈឃុំ-សង្កាត់** ........ ១២

១. ការផ្សះផ្សាបានសម្រេច ........ ១២

២. ការផ្សះផ្សាមិនបានសម្រេច ........ ១២

**កថាភាគទី៣. សមត្ថកិច្ចដោះស្រាយតាមរយៈតុលាការ** ........ ១៣

១. ការទទួល និងពិនិត្យពាក្យបណ្តឹង ..... ១៣

២. ការបញ្ជូនពាក្យបណ្តឹង ..... ១៥

**ផ្នែកទី២. ដំណើរការនៃនីតិវិធីនៃការលែងលះ** ..... ១៥

**កថាភាគទី១. ការចាត់ចែងរក្សាការពារ** ..... ១៥

១. ការដាក់អោយសហព័ទ្ធរស់នៅបែកគ្នាជាបណ្តោះអាសន្ន ..... ១៥

២. ការដាក់អោយមានការថែរក្សាកូនជាបណ្តោះអាសន្ន ..... ១៦

៣. ថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ..... ១៧

**កថាភាគទី២. នីតិវិធីត្រៀមសម្រាប់ទាញហេតុផល** ..... ១៧

**កថាភាគទី៣. នីតិវិធីទាញហេតុផលផ្ទាល់មាត់** ..... ១៨

**កថាភាគទី៤. សាលក្រមលែងលះ** ..... ២០

១. ទម្រង់នៃសាលក្រមលែងលះ ..... ២២

២. ការប្រកាសសាលក្រម ..... ២២

២.១. សាលក្រមចំពោះមុខ ..... ២៣

២.២. សាលក្រមកំបាំងមុខ ..... ២៣

៣. ការចូលជាស្ថាពរនៃសាលក្រម ..... ២៣

**កថាភាគទី៥. ដីកាសម្រេច** ..... ២៤

## ជំពូកទី៣

## អានុភាពនៃការលែងលះ

**ផ្នែកទី១. អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ** ..... ២៧

១. ចំពោះបុរស ឬ ស្ត្រី ..... ២៧

២. ចំពោះឈ្មោះ និង ញាតិ ..... ២៨

៣. ចំពោះអត្តាធីនភាព ..... ២៩

**ផ្នែកទី២. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ** ..... ៣០

១. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា ..... ៣០

២. ទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់ ..... ៣០

២.១. ទ្រព្យសម្បត្តិដោយឡែក ..... ៣១

២.២. ទ្រព្យសម្បត្តិរួម ..... ៣១

**ផ្នែកទី៣. អានុភាពនៃការលៃលះចំពោះកូន** ........ ៣២

១. ការកំណត់អំណាចមេបា........ ៣២

២. អាហារកាតព្វកិច្ចចំពោះកូន ........ ៣៣

**សេចក្ដីសន្និដ្ឋាន** ........ ៣៥

**អនុសាសន៍** ........ ៣៦

**ឯកសារយោង**........ ៣៨

**ឧបសម្ព័ន្ធ**........ ៣៩

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ធម្មជាតិរបស់មនុស្សគ្រប់រូបគឺ នៅពេលដែលពេញវ័យកំលោះ ក្រមុំ រមែងតែមាននូវ គូគាប់សម្រាប់ជីវិតរៀងៗខ្លួន ដើម្បីធ្វើការស្នងនូវពូជពង្សវង្សត្រកូលរបស់គ្រួសារ។ ដូចនេះនៅពេលដែលបុរសម្នាក់និង ស្រ្តីម្នាក់មាននូវមនោសញ្ចេតនាជ្រាលជ្រៅជាមួយគ្នា ពួកកគេនឹងរួមគ្នាបង្កើតគ្រួសារមួយ ហើយរួមរស់ដោយសុភមង្គលជាមួយគ្នា។ ដែលគ្រួសារគឺជាកោសិកាដ៏សំខាន់របស់សង្គមជាតិ។ ហើយដើម្បីបង្កើតគ្រួសារមួយបាន ពួកគេត្រូវឆ្លងកាត់នូវការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងស្របទៅតាមលក្ខខណ្ឌគតិយុត្តដែលបានកំណត់សម្រាប់ការបង្កើតអាពាហ៍ពិពាហ៍ នោះទើបពួកគេអាចក្លាយជាប្តីប្រពន្ធស្របទៅតាមច្បាប់បាន។ ដែលអាពាហ៍ពិពាហ៍សំដៅទៅលើ ចំណងផ្លូវច្បាប់រវាងស្រ្តីម្នាក់និងបុរសម្នាក់រួមគ្នា ទាំងខាងសេដ្ឋកិច្ច សង្គម និងមនោសញ្ចេតនា។ ក្រោយពីរៀបអាពាហ៍ពិពាហ៍រួច ពួកគេអាចចាប់ដៃគ្នាកសាងគ្រួសារដ៏កក់ក្តៅ និងមានភាពចម្រុងចម្រើន ។ ប៉ុន្តែក៏មាននូវគ្រួសារខ្លះ ក្រោយពេលរៀបការ ពុំអាចទទួលបាននូវសុភមង្គល និង ពុំអាចរួមរស់ជាមួយគ្នាបន្តដោយសារបញ្ហាផ្សេងៗជាច្រើន ដែលមិនអាចដោះស្រាយនិងស្រោចស្រង់ឡើងវិញបាន នោះពួកគេនឹងឈានទៅដល់ដំណាក់កាលលែងលះ ដែលត្រូវចេញសាលក្រម ឬដីកាសម្រេចពីតុលាកា។ ជាការពិតណាស់ចំណងអាពាហ៍ពីពាហ៍កើតឡើងបានដោយការទទួលស្គាល់ដោយច្បាប់ ដូចនេះ នៅពេលដែលចង់រំលាយនូវចំណងអាពាហ៍ពីពាហ៍នោះវិញ ក៏ត្រូវតែធ្វើទៅតាមផ្លូវច្បាប់ផងដែរ។

ជាការពិតណាស់ ចំណងអាពាហ៍ពិពាហ៍កើតមានឡើងជាហូរហែរ ស្របពេលដែលការលែងលះក៏កើតមានជាបន្តបន្ទាប់ផងដែរ។ ចំពោះការលែងលះនាំអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវឋានៈបុគ្គល ដូចច្នេះភាគីពុំអាចធ្វើកិច្ចសន្យាលែងលះក្រៅផ្លូវតុលាការបានឡើយ ចាំបាច់ត្រូវតែមាននូវសេចក្តីសម្រេចរបស់តុលាការទើបការលែងលះនោះមានអានុភាពតាមផ្លូវច្បាប់។ ដូចច្នេះ តើអ្វីទៅជាការលែងលះ? ហើយមានមូលហេតុអ្វីខ្លះដែលបង្កអោយមានការលែងលះកើតឡើង? ចំពោះដំណើរការនិងនីតិវិធីក្នុងរឿងក្តីលែងលះប្រព្រឹត្តទៅយ៉ាងដូចម្តេច? ចំណែកឯ កូននិងទ្រព្យសម្បត្តិរបស់ភាគីនឹងត្រូវចាត់ចែងយ៉ាងដូចម្តេចខ្លះ?

ជាក់ស្តែងដោយសង្កេតឃើញថា ការលែងលះគឺពិតជាមានលក្ខណៈស្មុគស្មាញ ដែលធ្វើអោយមានការបន្សល់នូវចម្ងល់ជាច្រើនដល់ពលរដ្ឋទាំងឡាយនៅក្នុងសង្គម ជាពិសេសសាមុីខ្លួនដែលមានបំណងចង់លែងលះផ្ទាល់ ទើបនាំអោយមាននូវការស្រាវជ្រាវប្រធានបទមួយនេះឡើងមក។ ដោយក្នុងគោលបំណងចង់អោយប្រកម្ពុជាយើងមានការរីកចម្រើនខាងផ្លូវច្បាប់ ក៏ដូចជាបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីការលែងលះ ដំណើរការ នីតិវិធីនៃការលែងលះ និង អានុភាពនៃការលែងលះជាដើម។ លើសពីនេះទៅទៀត ដើម្បីអោយអាជ្ញាធរមានសមត្ថកិច្ច ដែលមានតួនាទីភារៈកិច្ចទាក់ទិនទៅនឹងផ្នែកនេះ អាចអនុវត្តការងារអោយកាន់តែម៉ត់ចត់ ហើយថែមទាំងយកចិត្តទុកដាក់ទៅលើការងារ និងមានការទទួលខុសត្រូវខ្ពស់ ដើម្បីផ្តល់ភាពងាយស្រួល និង

បង្កើតទំនុកចិត្តដល់ប្រជាពលរដ្ឋដែលមានបញ្ហាក្នុងរឿងក្តីលែងលះ។ ចំពោះការអនុវត្តដែលមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ជាចំណែកមួយយ៉ាងសំខាន់ក្នុងការអនុវត្តច្បាប់នៅប្រទេសកម្ពុជាអោយមានភាពរឹងមាំ និងប្រសិទ្ធិភាព។

ប្រធានបទស្តីពី «ការលែងលះ» នេះមានដែនកំណត់ស្ថិតក្រោមរដ្ឋធមនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ ២០០៦ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល២០១០ ច្បាប់ស្តីពីបណ្តឹងវិវាទគ្រួសារ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង២០១០ និង អនុក្រឹត្យស្តីពីអាត្រានុកូលដ្ឋាន។

ប្រធានបទនៃការស្រាវជ្រាវខាងលើផ្តល់នូវសារៈប្រយោជន៍ជូនដល់អ្នកសិក្សាទាំងឡាយ ក៏ដូចជាមហាជនអោយកាន់តែជ្រាបច្បាស់បានស៊ីជម្រៅ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការលែងលះ ដែលយល់ដឹងចាប់ពីមូលហេតុនៃការលែងលះ លំហូរនៃនីតិវិធីនៃការលែងលះរហូតដល់ការបញ្ចប់នៃរឿងក្តីលែងលះ ដែលស្របទៅតាមច្បាប់។ ជាងនេះទៅទៀតការរៀបចំ ចងក្រងប្រធានបទមួយនេះឡើងមក ដើម្បីបំភ្លឺនូវចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងរឿងក្តីលែងលះ រួមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អោយកាន់តែមានភាពរីកចម្រើនបន្ថែមទៀតផងដែរ។

យើងខ្ញុំទាំងពីរ បានខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវដោយ ប្រមូលនូវឯកសារច្បាប់ដែលពាក់ព័ន្ធនានាតាមប្រព័ន្ធអ៊ីនធឺណេត រួមជាមួយនឹងចំណេះដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូដែលជាលោកគ្រូដឹកនាំនិងសាស្ត្រាចារ្យ ដើម្បីចងក្រងបង្កើតនូវស្នាដៃមួយនេះឡើង។

នៅក្នុងការបកស្រាយប្រធានបទសារណាស្តីពី «ការលែងលះ» នេះបានធ្វើការចងក្រងឡើងដោយបែងចែកចេញជា៣ជំពូករួមមាន៖

**ជំពូកទី១៖ ការលែងលះ**

ផ្នែកទី១៖ សញ្ញាណនៃការលែងលះ

ផ្នែកទី២៖ មូលហេតុនៃការលែងលះ

**ជំពូកទី២៖ នីតិវិធីនៃការលែងលះ**

ផ្នែកទី១៖ ការផ្តើមនៃបណ្តឹង

ផ្នែកទី២៖ ដំណើរការនៃនីតិវិធីនៃការលែងលះ

**ជំពូកទី៣៖ អានុភាពនៃការលែងលះ**

ផ្នែកទី១៖ អានុភាពនៃការលែងលះចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

ផ្នែកទី២៖ អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ

ផ្នែកទី៣៖ អានុភាពនៃការលែងលះចំពោះកូន

# ជំពូកទី១
# ការលេខលះ

# ជំពូកទី១
# ការលែងលះ

## ផ្នែកទី១. សញ្ញាណនៃការលែងលះ

ជាទូទៅ ទាំងបុរសនិងស្ត្រីមានសេរីភាពពេញលេញនៅក្នុងការសម្រេចចិត្តជ្រើសរើសគូស្រកររៀងៗខ្លួន ដើម្បីបង្កើតនូវចំណងអាពាហ៍ពិពាហ៍មួយប្រកបទៅដោយសុខសុភមង្គល។ យ៉ាងណាមិញ មានគូស្វាមី ភរិយាជាច្រើនបានចាប់ដៃគ្នាកសាងគ្រួសារអោយរីកចម្រើនលូតលាស់ និង មានក្តីសុខ។ ស្របពេលដែល គ្រួសារមួយចំនួនទៀត បន្ទាប់ពីបានរួមរស់ជាមួយគ្នារួច ជីវភាពក្រោយពេលរៀបអាពាហ៍ពិពាហ៍ហាក់បីដូចជាមិនរលូនដោយមានតែភាពល្អក់កករ រស់នៅមិនចុះសម្រុង ហើយមានតែបញ្ហាជាច្រើនដែលកើតចេញពីមូលហេតុផ្សេងៗបង្កទៅជាវិវាទក្នុងគ្រួសារ ដោយពុំអាចកសាងសុភមង្គល ថែមទាំងមានផលប៉ះពាល់ទៅដល់សិទ្ធិ កិត្តិយសសេចក្តីថ្លៃថ្នូររបស់សហព័ទ្ធផ្ទាល់ និងគ្រួសារ ដែលពុំអាចទទួលយកបាន។ អាស្រ័យហេតុនេះ ប្រសិនបើសហព័ទ្ធម្ខាងណា ឬសហព័ទ្ធទាំងសងខាង យល់ឃើញថាខ្លួនពិតជាមិនអាចបន្តរួមរស់ជាប្តីប្រពន្ធតទៅមុខទៀតបានទេនោះពួកគេអាចដាក់ពាក្យសុំលែងលះចំណងអាពាហ៍ពិពាហ៍ នោះបាន។

ចំណងអាពាហ៍ពិពាហ៍ ត្រូវបានកើតចេញពី ការស្ម័គ្រចិត្ត និង ការប្តេជ្ញាចិត្ត របស់មនុស្សពីរនាក់ ដោយគោរពទៅតាមលក្ខខណ្ឌច្បាប់។ ដូចនេះ នៅពេលដែលចង់រំលាយនូវចំណងអាពាហ៍ពិពាហ៍នោះវិញ ក៏ត្រូវតែគោរព និង អាស្រ័យទៅលើលក្ខខណ្ឌច្បាប់ផងដែរ[1]។

### កថាភាគទី១. និយមន័យ

#### ១. អាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ ជាចំណងមនោសញ្ចេតនារវាងបុរសម្នាក់និងស្ត្រីម្នាក់ ដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តសមភាព និងត្រូវបានច្បាប់ទទួលស្គាល់។

អាពាហ៍ពិពាហ៍ជាកិច្ចសន្យាពិសេសមួយ ដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតាអោយតែសំណើនិងស្វីការត្រូវគ្នា គឺកិច្ចសន្យានឹងត្រូវបានបង្កើតឡើង បើទោះជាធ្វើឬមិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍វិញ ត្រូវតែប្រិតប្រៀងបំផុតនិងត្រូវគោរពតាម មាត្រា៩៥៥នៃក្រមរដ្ឋប្បវេណី ហើយកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ មិនអាចធ្វើដោយផ្ទាល់មាត់បានទេ ថ្វីបើសំណើសុំរៀបអាពាហ៍ពិពាហ៍ត្រូវគ្នាជាមួយនឹងស្វីការការរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ហើយប្រសិនបើ មិនគោរពទៅតាមលក្ខខណ្ឌទេនោះកិច្ចសន្យាអាពាហ៍ពិពាហ៍ ពុំអាចបង្កើតឡើងបានឡើយ[2]។

---

[1] មាត្រា៣ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

[2] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៦ គន្ថីទី៨ ឆ្នាំ២០១២

ពោលគឺអាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះ ធ្វើឡើងស្របទៅតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ[3]។

**២. ការលែងលះ**

ការលែងលះគ្នា គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ ក្នុងពេលរួមរស់នៅជាមួយគ្នា[4]។ ដែលសំដៅទៅលើការផ្តាច់ ឬការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ រវាងប្តី និងប្រពន្ធ ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋាន[5]។ អាស្រ័យដោយ សហព័ទ្ធទាំងសងខាងព្រមព្រៀងគ្នា ឬ សហព័ទ្ធណាម្ខាងមិនចង់បន្តរួមរស់ និងមិនអាចបន្តរស់នៅជាមួយគ្នាបាន ក៏ធ្វើការសំណូមពរសុំផ្តាច់សមគ្គសង្វាស ហើយត្រូវបានតុលាការសម្រេចចិត្តតាមបញ្ញត្តិនៃច្បាប់។

ចំពោះការលែងលះត្រូវបានចាត់ទុកជា សាលក្រមឬសាលដីការបស់តុលាការដែលប្រកាសថាចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងពីរ ត្រូវបានបញ្ចប់ទៅតាមផ្លូវច្បាប់[6]។ ពោលគឺផ្តាច់រាល់ទំនាក់ទំនងគតិយុត្តដែលមានអានុភាពនាំអោយសហព័ទ្ធទាំងពីរ រួចផុតពីករណីយកិច្ចរួមរស់ជាមួយគ្នា សហការគ្នា ជួយសង្គ្រោះគ្នា និងរួមទាំងករណីយកិច្ចស្មោះត្រង់ផងដែរ[7]។

**កថាភាគទី២. ប្រភេទនៃការលែងលះ**

ការលែងលះតាមផ្លូវតុលាការ អាចធ្វើឡើងក្រោមរូបភាព២ គឺ ការលែងលះដោយ មានការព្រមព្រៀង និង ការលែងលះដោយមិនមានការព្រមព្រៀង។

**១. ការលែងលះដោយមានការព្រមព្រៀង**

ការលែងលះដោយមានការព្រមព្រៀងចង់សំដៅទៅលើការសម្រេចចិត្តលែងលះ ដោយផ្អែកលើឆន្ទៈពិតប្រាកដរបស់សហពទ្ធ័ទាំងពីរ ក្នុងការផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ ពោលមិនមានភាគីណាមួយជំទាស់ ឬមានវិវាទមិនព្រមលែងលះនោះឡើយ។ ដោយយល់ឃើញថាភាគីទាំងសងខាង អស់និស្ស័យ អស់មនោសញ្ចេតនាជាមួយនឹងគ្នាឬ មិនអាចបន្តរស់នៅជាមួយគ្នាតទៅមុខទៀតបាន។ ច្បាប់ត្រូវបានបង្កើតឡើងដោយឈរនៅលើទស្សនៈគោរពសិទ្ធ និងការសម្រេចចិត្តរបស់បុគ្គលដែលចាត់ទុកជារឿងសំខាន់ ដូច្នេះបើភាគីទាំងពីរអស់និស្ស័យ

[3] មាត្រា៣ ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ១៩៨៧

[4] មាត្រា៣៨ ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ១៩៨៧

[5] មាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី២០០៧

[6] សៀវភៅ «នីតិគ្រួសារ និង អាពាហ៍ពិពាហ៍» បណ្ឌិត ឥន យឿន ទំព័រ១៨៥

[7] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី២០០៧

នឹងគ្នា ឬមិនអាចរស់នៅជាមួយគ្នាបាន គេមិនអាចបង្ខំមនុស្សដែលមិនចង់រស់នៅជាមួយគ្នាអោយរស់នៅជាមួយគ្នាបានទេ ច្បាប់គោរពនូវការសម្រេចរបស់ភាគីទាំងពីរ ក្នុងការព្រមព្រៀងលែងលះគ្នា ប៉ុន្តែការព្រមព្រៀងនេះ មិនត្រូវមានការគំរាមកំហែង មានការបង្ខិតបង្ខំពីភាគី ឬតតិយជនឡើយ[8]។

ភាគីទាំងសងខាង អាចឯកភាពគ្នាដោយស្ម័គ្រចិត្តក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ហើយដាក់ពាក្យសុំលែងលះ ដោយភ្ជាប់ទៅជាមួយកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ទៅកាន់សាលាដំបូងរាជធានី/ខេត្ត ហើយតុលាការនឹងអនុញ្ញាតអោយលែងលះ ក្រោយរកឃើញថា ភាគីមាន ឆន្ទៈព្រមព្រៀងគ្នាពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍[9]។ ចំពោះការលែងលះប្រភេទនេះ ការព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង គឺជាលក្ខខណ្ឌចាំបាច់សម្រាប់អោយតុលាការយកធ្វើជាមូលដ្ឋាននៃការពិចារណាក្នុងការវិនិច្ឆ័យដើម្បីចេញនូវសេចក្តីសម្រេចនៃការលែងលះ ដោយពុំចាំបាច់ពិចារណាលើមូលហេតុលែងលះដែលកំណត់ដោយក្រមរដ្ឋប្បវេណីឡើយ។ ហើយតុលាការត្រូវសម្រេចអោយភាគីលែងលះគ្នាបានតាមរយៈដីកាសម្រេចលែងលះ[10]។ ការលែងលះនាំអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវទំនាក់ទំនងឋានៈបុគ្គល ដូចនេះទោះជាមានការព្រមព្រៀងក្តី ភាគីមិនអាចបង្កើតកិច្ចសន្យាលែងលះក្រៅផ្លូវការ ឬ គ្រាន់តែប្រើវិធីដាក់លិខិតទៅឃុំ-សង្កាត់បានទេចាំបាច់ត្រូវតែ មានសេចក្តីសម្រេចពីតុលាការ ទើបការលែងលះមានអានុភាពតាមផ្លូវច្បាប់[11]។

**២. ការលែងលះដោយមិនមានការព្រមព្រៀង**

ការលែងលះដោយមិនមានការព្រមព្រៀងឬ ការលែងលះតាមបណ្តឹងទាមទារគឺជា លែងលះដោយពុំមានការព្រមព្រៀងទាំងសងខាង ពោលគឺសហព័ទ្ធណាម្ខាងមានការទាមទារលែងលះ ហើយសហព័ទ្ធម្ខាងទៀតមិនមានឆន្ទៈក្នុងការលែងលះ។ ប៉ុន្តែ បើមិនអាចរួមរស់ជាមួយគ្នាបន្តទៀត ព្រោះមានភាពរកាំរកូស មានការកើតឡើងនូវអំពើផ្សេងៗដែលបង្កអោយសហព័ទ្ធម្ខាង មិនអាចស៊ូទ្រាំ និងអធ្យាស្រ័យអោយបាន ឬមានអ្វីដែលបង្កអោយជះឥទ្ធិពលអវិជ្ជមានជាច្រើនទៅលើភាគីផ្ទាល់ កូន ញាតិជាដើម។ ដូចនេះ សហព័ទ្ធម្ខាងនោះមានការមិនសុខចិត្តដែលទទួលរងនូវទង្វើទាំងនោះ សហព័ទ្ធម្ខាងនោះអាចដាក់ពាក្យសុំលែងលះ ដើម្បីអោយតុលាការធ្វើការវិនិច្ឆ័យ ហើយចេញសាលក្រមលែងលះឆ្លើយតបទៅនឹងជនរងគ្រោះដែលជាដើមបណ្តឹងទាមទារ។បំណងនៃការទាមទារលែងលះអាចធ្វើទៅបានលុះត្រាតែមានមូលហេតុត្រឹមត្រូវ ដូចមានចែងនៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះភាគីម្ខាង(ប្តី/ប្រពន្ធ)នៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា ទៅសាលាដំបូងរាជធានី/ខេត្ត ហើយបើតុលាការរកឃើញថាមានមូលហេតុ និងភស្តុតាងបញ្ជាក់យ៉ាង

[8] ទំព័រ១៩០ សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍
[9] មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី២០០៧
[10] មាត្រា៣-២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[11] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៦ គន្ថីទី៨ ឆ្នាំ២០១២

ច្បាស់លាស់ថាភាគីទាំងពីរពិតជាមិនអាចរួមរស់នៅជាមួយគ្នាជាប្តី/ប្រពន្ធទៀតបាន នោះតុលាការត្រូវសម្រេចឲ្យភាគីលែងលះគ្នាតាមរយៈអំណាច «សាលក្រម» នេះបើយោងតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

បើទោះបីជា ពាក្យបណ្តឹងទាមទារការលែងលះរបស់ភាគី មានមូលហេតុដូចមានចែងក្នុងច្បាប់ក៏ដោយ ប៉ុន្តែប្រសិន បើតុលាការយល់ឃើញថាការលែងលះនោះ បណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់ប្តី/ប្រពន្ធ ឬកូន ក្រលំបាក មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន ឬដោយសារតែការទាមទារនោះផ្ទុយនឹងភាពសុចរិតនោះ តុលាការអាចច្រានចោល ការទាមទារលែងលះគ្នានោះបាន ដោយពិចារណាលើស្ថានភាពជាក់ស្តែង ឬដោយឆន្ទានុសិទ្ធិ។

## ផ្នែកទី២. មូលហេតុនៃការលែងលះ

សហព័ទ្ធទាំងសងខាង មានសេរីភាពពេញលេញក្នុងការដាក់ពាក្យសុំលែងលះបាន តែសេរីភាពនេះគឺស្ថិតនៅក្នុងក្របខណ្ឌនៃបញ្ញត្តិច្បាប់។ ដូចនេះ ការលែងលះអាចសម្រេចទៅបាន កាលបើមានមូលហេតុគ្រប់គ្រាន់ត្រឹមត្រូវ និងច្បាស់លាស់ក្នុងការបញ្ជាក់ថា ខ្លួនពុំអាចរួមរស់ចុះសម្រុងនឹងគ្នាបានតទៅទៀតទៅតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីដែលបញ្ញត្តិអំពី មូលហេតុនៃការលែងលះ [12] ដែលរួមមានដូចខាងក្រោមនេះ :

### ១. ការប្រព្រឹត្តនូវអំពើផិតក្បត់នៅលើសហព័ទ្ធ

អំពើផិតក្បត់គឺជា ការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយ ជាមួយនឹងស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយនឹងបុរសដទៃក្រៅពីប្តីរបស់ខ្លួន[13]។ អំពើផិតក្បត់នេះក្រៅពីអាចជាមូលហេតុដែលសហព័ទ្ធអាចសុំលែងលះ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីហើយនោះ ភាគីដែលប្រព្រឹត្តអំពើផិតក្បត់ ក៏ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌផងដែរប្រសិនបើសហព័ទ្ធម្ខាងទៀតបានប្តឹង ដោយត្រូវផ្តន្ទាទោសតាមមាត្រា១០នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ ដោយអាចជាប់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី២០០ ០០០រៀល ដល់ ១ ០០០ ០០០រៀលឬ ផ្តន្ទាទោសណាមួយនៃទោសទាំង២។ ចំពោះការទាមទារលែងលះដោយមូលហេតុនេះ សហព័ទ្ធត្រូវបញ្ជាក់ពីអង្គហេតុនៃការផិតក្បត់នោះ ដោយការថតរូបឬវីដេអូ ដែលបង្ហាញពីអំពើផិតក្បត់របស់សហព័ទ្ធម្ខាងទៀតដូចជាការដែលសហព័ទ្ធម្ខាងទៀតមានទំនាក់ទំនាក់ផ្លូវភេទនឹងតតិយជន ឬ ការមានភាពល្អកល្អើនហើយដើរចេញពីសណ្ឋាគារជាដើម ដែលនេះជាអង្គហេតុប្រហាក់ប្រហែលតែអាចចាត់ថាជាអំពើផិតក្បត់បាន នោះតុលាការនឹងពិចារណាអោយធ្វើការលែងលះបាន។

[12] មាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី២០០៧

[13] មាត្រា៧ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

ឧទាហរណ៍៖ លោក ហុង និង លោកស្រី ធីតា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាស្របទៅតាមច្បាប់។ ៥ឆ្នាំក្រោយមក លោក ហុង បានលួចចិញ្ចឹមស្រីកំណាន់ចិត្តម្នាក់ឈ្មោះ សយ នៅខាងក្រៅនិងបានរួមសម្ពសង្វាសជាមួយសយទៀតផង។ នៅពេលលោកស្រី ធីតា តាមទាន់លោកហុងនិងសយ នៅបន្ទប់សណ្ឋាគារ គាត់មានការឈឺចាប់យ៉ាងខ្លាំង និងលែងចង់បន្តរួមរស់ជាមួយលោក ហុង តទៅទៀត។ នៅក្នុងករណីនេះ លោកស្រី ធីតា អាចធ្វើការសុំលែងលះជាមួយ លោក ហុង បានដោយផ្អែកលើមូលហេតុ ការប្រព្រឹត្តនូវអំពើផិតក្បត់។

**២. ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុ**

ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ គឺជាការដែលមិនរួមរស់ជីវភាពជាមួយគ្នា មិនសហការគ្នា មិនសង្គ្រោះគ្នាទៅវិញទៅមក ហើយដែលគេអាចទទួលស្គាល់ថា ភាគីមិនមានឆន្ទៈបន្តជីវភាពរស់នៅជាប្តីប្រពន្ធតទៅមុខទៀតឡើយ។

ឧទាហរណ៍៖ បន្ទាប់ពីបានរៀបការរួចហើយបុរសជាស្វាមីបានចុះចោលលំនៅឋានទៅរស់នៅជាមួយឪពុកម្តាយរបស់គាត់វិញដោយ ពុំមាននូវមូលហេតុត្រឹមត្រូវ និងគ្មាននូវការយល់ស្របពីស្ត្រីដែលជាភរិយា។ ដូចច្នេះ ស្ត្រីជាភរិយាអាចដាក់ពាក្យបណ្តឹងសុំលែងលះទៅតុលាការបាន។

**៣. ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ឬរស់អស់រយៈពេលជាង ១ ឆ្នាំ**

ចំពោះការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់អស់រយៈពេលជាង ១ ឆ្នាំ វិញគឺសំដៅលើករណីដែលសហព័ទ្ធម្ខាង មិនបានទទួលដំណឹងពីសហព័ទ្ធម្ខាងទៀតទាល់តែសោះ ដោយពុំដឹងថាសហព័ទ្ធម្ខាងទៀត នៅទីណា ស្លាប់ឬរស់។

ឧទាហរណ៍៖បន្ទាប់ពីលោក សុខបានរៀបអាពាហ៍ពិពាហ៍នឹងលោកស្រីបូផាអស់រយៈពេល៦ឆ្នាំ។ គាត់បានចាកចេញពីប្រទេសកម្ពុជាទៅធ្វើការនៅបរទេស។ ប៉ុន្តែ ចាប់តាំងពីពេលនោះមកពុំមានដំណឹងពីគាត់ ថាស្លាប់ឬរស់ឡើយ។ ដោយហេតុនេះ បើនៅតែបាត់ដំណឹងគាត់ លើសពី១ឆ្នាំ នោះលោកស្រី បូផា អាចពាក្យបណ្តឹងសុំលែងលះទៅតុលាការបាន។

**៤. ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ ឆ្នាំ**

ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ ឆ្នាំ គឺសំដៅលើស្ថានភាពដែលសហព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ ឆ្នាំ ជាមួយគ្នា ដែលផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

ឧទាហរណ៍៖ លោក ទី និង លោកស្រី ទេពី បានរួមរស់ជាប្តី ប្រពន្ធស្របច្បាប់អស់រយៈពេល២ឆ្នាំមកហើយ។ តែដោយមានការខ្វែងមតិ និងមានការអាក់អន់ ស្រពន់ចិត្តនឹងគ្នាបន្តិចបន្តួច អ្នកទាំងពីរក៏សម្រេចចិត្តរស់នៅបែកគ្នា ។ ដូចនេះ ប្រសិនបើអ្នកទាំងពីរបែកគ្នាបែបនេះ លើសពី១ឆ្នាំ ភាគីណាម្ខាងអាចពាក្យបណ្តឹងសុំលែងលះទៅតុលាការបាន។

### ៥. ករណីផ្សេងៗដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់

ក្នុងករណីផ្សេងៗ ដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយមិនមានសង្ឃឹមថានឹងអាចស្រោចស្រង់មកវិញបាន។ ក្រមរដ្ឋប្បវេណីពុំបានកំណត់ពីលក្ខណៈទូលាយទៅលើមូលហេតុនៃការលែងលះដោយទុកអោយតុលាការជាអ្នកវាយតម្លៃនិង កំណត់អំពីករណីដែលអាចអោយយើងជឿបានថា អាពាហ៍ពិពាហ៍ត្រូវបានបែកបាក់នឹងគ្មានសង្ឃឹមថានឹងអាចស្តារមកវិញបាន។ ហើយក្នុងនោះផងដែរ តុលាការនឹងពិចារណាដល់ស្ថានភាពនានា ដែលបានកើតមានឡើងដូចជា សកម្មភាពអាកប្បកិរិយារបស់សហព័ទ្ធនៅក្នុងពេលដែលមាននូវចំណងអាពាហ៍ពិពាហ៍ ឆន្ទៈភាគីក្នុងការបន្តអាពាហ៍ពិពាហ៍ ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពសុខភាព ជាដើម[14]។

នៅក្នុងករណីនេះអាចមានច្រើន ដោយមានកំហុសឆ្គងធ្ងន់ធ្ងររួមបញ្ចូលទាំង ការប្រើអំពើហិង្សាទៅលើសហព័ទ្ធ (ហិង្សាផ្លូវកាយផ្លូវចិត្តជាដើម) ការជេប្រមាថ ជម្ងឺធ្ងន់ធ្ងរ ជំពាក់បំណុលគ្មានមូលហេតុជាអាទិ៍ ។

ផ្អែកតាមខ្លឹមសារនៃកថាខណ្ឌទី ២ នៃមាត្រា ៩៧៨ ចែងថា ៖ ទោះបីជា ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ក៏ដោយ បើសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូន ក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាច ច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាលើស្ថានភាពទាំងឡាយបាន។ [15]

ឧទាហរណ៍ ៖ លោក សីហា និង លោកស្រី រ័ត្ន បានរៀបការជាមួយ គ្នានៅឆ្នាំ ២០០៨។ ថ្មីៗនេះ លោក សីហា មានបញ្ហាផ្នែកសុខភាព រួមទាំងផ្នែកលុយកាក់ ហើយតែងតែរករឿងឈ្លោះប្រកែកជាមួយនឹងលោកស្រី រ័ត្ន រហូតដល់ ពេលខ្លះ លោក សីហា បានជេរបញ្ឆោរលោកស្រី រ័ត្ន ទៀតផង។ លោកស្រី រ័ត្ន បានដាក់ពាក្យបណ្តឹងសុំលែងលះទៅតុលាការ ហើយលោក សីហា ធ្វើការបដិសេធយ៉ាងដាច់អហង្ការ មិនយល់ព្រមនឹងការលែងលះនេះទេ។ ដោយក្នុងចំណងអាពាហ៍ពិពាហ៍ អ្នកទាំងពីរមានកូនបីនាក់ ម្នាក់អាយុ ៤ ឆ្នាំ ម្នាក់ទៀតមានអាយុ ២ ឆ្នាំទៀតទើបតែមានអាយុ ឆ្នាំ ១ ប៉ុណ្ណោះ។ ជាពិសេសទៀត លោក សីហា កំពុងបាត់បង់ការងារ ពិបាកក្នុងការរកលុយមកចិញ្ចឹមជីវិតនិងបញ្ហាសុខភាព ថែមទៀតផង ចំណែកឯទ្រព្យសម្បត្តិរួមវិញ ក៏ពុំមានច្រើនដែរ។ នៅក្នុងស្ថានភាពបែបនេះ តុលាការអាចនឹង យល់ឃើញថា " ប្រសិនបើឱ្យលោកស្រូ រ័ត្ន និងលោក សីហា លែងលះពីគ្នា ប្រហែលជាធ្វើឱ្យលោក សីហា មិនអាចទៅទ្រាំទ្រនឹងការឈឺចាប់ រួមផ្សំជាមួយនឹង ស្ថានភាពសុខភាពលោកទន់ខ្សោយផងនោះ បើយ៉ាងដូច្នេះមែន តុលាការអាច សម្រេចចានចោលការទាមទារលែងលះរបស់លោកស្រី រ័ត្នបាន។

បើយោងតាមអត្ថន័យក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៧៨ ចែងថា ៖ ក្នុងករណីមានមូលហេតុដូចបាន

[14] «សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និង គ្រួសារ» លោក រុន ពណ្ណារិទ្ធ និងលោកស្រី ទំព័រ៣៧៩
[15] មាត្រា ៩៧៨នៃក្រមរដ្ឋប្បវេណី២០០៧

កំណត់ក្នុងចំណុច កថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹង ភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោល ការទាមទារលែងលះគ្នា ដោយឆន្ទានុសិទ្ធិបាន[16]។

ឧទាហរណ៍៖ លោក ផាន់ និងលោកស្រីច័ន្ទ្រា បានរៀបអាពាហ៍ ពិពាហ៍ជាមួយគ្នានៅឆ្នាំ ១៩៨៩ ហើយមានកូនជាមួយគ្នាចំនួន4នាក់។ លុះដល់ ឆ្នាំ ២០០៨ ដោយសារតែការអាក់អន់ស្រពន់ចិត្តនឹងគ្នាបន្តិចបន្តួច លោកស្រី ចន្ទ្រា បានចាកចេញចោលផ្ទះ។ បន្ទាប់មក នៅឆ្នាំ ២០០៩ លោកស្រី ចន្ទ្រា បាន ជួបនឹងបុរសម្នាក់ផ្សេងទៀត ហើយក៏បានរស់នៅជាមួយនឹងបុរសម្នាក់នោះ។ រហូត ដល់ឆ្នាំ ២០១២ លោកស្រី ចន្ទ្រា បានដាក់ពាក្យបណ្ដឹងសុំលែងលះពីលោក ផាន់ ប៉ុន្តែលោក ផាន់ មិនយល់ព្រមលែងលះ ឡើយ។ ករណីបែបនេះ លោកស្រី ចន្ទ្រា និងលោក ន់ បានរស់នៅបែកគ្នាអស់ រយៈពេល ៥ ឆ្នាំ ក៏ពិតមែនតែតុលាការអាចច្រានចោលការទាមទារលែងលះពី សំណាក់លោកស្រី ចន្ទ្រាបាន ប្រសិនបើតុលាការយល់ឃើញថាមានមូលហេតុ ដូចមានចែងក្នុងកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៣ នៃមាត្រា ៩៧៨ ខាងលើ។

[16] «សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និង គ្រួសារ» លោក រុន ពណ្ណារិទ្ធ និងលោកស្រី ទំព័រ៣៧៩

# ជំពូកទី២

# នីតិវិធីនៃការលែងលះ

# ជំពូកទី២
# នីតិវិធីនៃការលែងលះ

ដំណើរការនៃការលែងលះ ចាប់ផ្តើមនៅពេលសហព័ទ្ធម្ខាង ឬ ទាំងសងខាងយល់ឃើញថាការរស់នៅជាមួយគ្នាពុំអាចមានសុភមង្គលតទៅទៀត ហើយចង់ផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ ដោយបានដាក់ពាក្យសុំលែងលះទៅតុលាការ។ បណ្តឹងសំដៅទៅលើ ឯកសារផ្លូវច្បាប់ដែលភាគីម្ខាងដាក់ជំទាស់ ឬ ប្រឆាំងទៅនឹងភាគីម្ខាងទៀត ដោយបង្ហាញពីការមិនសុខចិត្ត មិនយល់ស្រប ដើម្បីសុំអោយប្រព័ន្ធច្បាប់ជួយធ្វើការអន្តរាគមន៍ និងសម្រេចអោយបាន សមស្របហើយត្រឹមត្រូវ ទៅតាមលក្ខខណ្ឌច្បាប់។ ចំពោះការដាក់ពាក្យបណ្តឹងសុំលែងលះ ភាគីត្រូវដាក់តាមរយៈ ក្រុមប្រឹក្សាឃុំ/សង្កាត់ ឬ អាចដាក់ទៅតុលាការដោយផ្ទាល់តែម្តង។

នីតិវិធីនៃការលែងលះ ជាវិធានចាត់ចែងការងាររបស់តុលាការដើម្បីដោះស្រាយនូវសំណុំរឿង លែងលះដែលសហព័ទ្ធដាក់ពាក្យប្តឹងសុំផ្តាច់សមគ្គសង្វាសពីគ្នានិងរាល់សកម្មភាពនៃអ្នកដែលពាក់ព័ន្ធចូលរួមក្នុងកិច្ចការនេះ ដើម្បីការពារផលប្រយោជន៍របស់សហព័ទ្ធម្នាក់ៗ ឬកូនរបស់សហព័ទ្ធនោះទៅតាមដំណាក់កាលនីមួយៗដែលមានចែងក្នុងច្បាប់។

## ផ្នែកទី១. ការផ្តើមនៃបណ្តឹង

នៅក្នុងវិវាទរឿងក្តីលែងលះ គឺមានតែសហព័ទ្ធទាំងពីរតែប៉ុណ្ណោះ ដែលជាភាគីនៃបណ្តឹង[17]។ បុគ្គលដែលមិនមែនជាសហព័ទ្ធ គឺមិនអាចក្លាយជាភាគីនៃបណ្តឹងបានឡើយ។ ភាគីនៃបណ្តឹង គឺជាជនដែលទាមទារអោយតុលាការដោះស្រាយវិវាទរបស់ខ្លួនដោយសម្រេចចេញនូវសាលក្រម ឬ សាលដីកា។ ច្បាប់ពុំបានកំណត់សិទ្ធិចំពោះសហព័ទ្ធណាម្ខាងដែលជាអ្នកមានសិទ្ធិធ្វើបណ្តឹងលែងលះនោះទេ ដូចនេះសហព័ទ្ធមានសិទ្ធិស្មើគ្នាក្នុងការធ្វើបណ្តឹងលែងលះ ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថា ការលែងលះនោះនឹងបណ្តាលអោយការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូនក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របានតុលាការអាចធ្វើការច្រានចោល ការទាមទារលែងលះនោះដោយពិចារណាទៅលើស្ថានភាពទាំងឡាយដែលកើតមាន។ ដូច្នេះក្នុងស្ថានភាពបែបនេះសហព័ទ្ធពុំមានការសុំប្តឹងលែងលះនោះឡើយ[18]។

### កថាភាគទី១. ការដាក់ពាក្យបណ្តឹងសុំលែងលះ

ការដាក់ពាក្យសុំលែងលះរបស់សហព័ទ្ធជូនទៅតុលាការគឺដើម្បីអោយតុលាការជួយវិនិច្ឆ័យទៅលើការទាមទារនិងមូលហេតុរបស់ខ្លួន។ ដោយក្នុងពាក្យសុំលែងលះនោះមានលក្ខណៈគតិយុត្តដែលត្រូវមានគោលបំណងនិងមូលហេតុនៃបណ្តឹងច្បាស់លាស់និងស្របតាមនីតិវិធី។ ហើយពាក្យសុំលែងលះអាចធ្វើឡើងដោយ

[17] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[18] កថាខណ្ឌទី២និងទី៣ មាត្រា៩៧៨នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ភាគីផ្ទាល់ ឬ តាមរយៈអ្នកតំណាងដែលអាណត្តិរបស់ខ្លួន។

ចំពោះការដាក់ពាក្យសុំលែងលះត្រូវធ្វើឡើងជា លាយល័ក្ខណ៍អក្សរទៅតុលាការ។ ម្យ៉ាងវិញទៀតអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងដោយអាណត្តិ ត្រូវរៀបចំលិខិតនៃពាក្យបណ្តឹងមុននឹងដាក់ទៅតុលាការដោយត្រូវសរសេរបញ្ជាក់នូវចំណុចដូចជា៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីដែលដាក់ពាក្យសុំ ហើយប្តីឬប្រពន្ធដែលយកពាក្យសុំមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិ និងត្រូវសរសេរ (ផ្ទះលេខ...ផ្លូវក្រុម...ភូមិ...ឃុំ/សង្កាត់...ស្រុក/ខណ្ឌ...ខេត្ត/រាជធានី...អាសយដ្ឋាន) នៅក្នុងពាក្យសុំលែងលះ។ ប៉ុន្តែបើមានអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះក្នុងពាក្យសុំផងដែល។
- ខ្លឹមសារនៃសាលក្រមឬដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ៖ ជាការសរសេរឡើងនូវអ្វីដែលអ្នកដាក់ពាក្យសុំលែងលះបានទាមទារជាមួយគ្នានេះដែរក៏បញ្ជាក់ អំពីទំហំនៃរឿងក្តីដែលត្រូវអោយតុលាការលើកយកមកវិនិច្ឆ័យនិងសម្រេចសេចក្តីផងដែល។ ទាក់ទិននឹងខ្លឹមសារនៃការសរសេរពាក្យសុំលែងលះនេះ ដើមបណ្តឹងត្រូវសរសេរអោយបានច្បាស់លាស់នូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារផ្សេងៗទៅកាន់តុលាការដូចជាការបែកចែកទ្រព្យសម្បត្តិ ឬការបែកចែកសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោយហ៊ុយចំណាយក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន ជាអាទិ៍
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖ គឺសរសេពីមូលដ្ឋានគតិយុត្តនៃការទាមទាររបស់ភាគី។ នៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀង មូលដ្ឋានគតិយុត្ត នៃការទាមទារ ដើម្បីលែងលះបាន គឺអង្គហេតុនៃការកើតឡើងនៃចំណងអាពាហ៍ពិពាហ៍ ដែលបានបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការសម្តែងឆន្ទៈនៃការព្រមព្រៀងលែងលះគ្នាដែលបញ្ជាក់ដោយកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។ ម៉្យាងទៀត ការចាត់ចែងអំណាចមេបាលើកូន ក៏ជាអង្គហេតុដែលអាចទាមទារឲ្យ តុលាការសម្រេចចាត់ចែងចំពោះកូនផងដែរ។ លើសពីនេះទៀត គឺជាអង្គហេតុដែលអាចទាមទារឲ្យមានការចាត់ចែងទ្រព្យសម្បត្តិ សំដៅលើអង្គហេតុដែលបញ្ជាក់ពីការ មានទ្រព្យសម្បត្តិរួមគ្នា(ទ្រព្យសកម្ម និងទ្រព្យអកម្ម) ដែលអង្គហេតុបញ្ជាក់ដោយឯកសារនានា ដូចជា ប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតសម្គាល់ម្ចាស់យានយន្តជាអាទិ៍[19]។

បណ្តឹងលែងលះ ត្រូវភ្ជាប់មកជាមួយសំបុត្រអាពាហ៍ពិពាហ៍និងឯកសារពាក់ព័ន្ធផ្សេងៗរវាងសហព័ទ្ធទាំងពីរ។

[19] មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

**កថាភាគទី២. សមត្ថកិច្ចដោះស្រាយតាមរយៈឃុំ-សង្កាត់**

ភាគីអាចដាក់ពាក្យសុំលែងលះទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ខាងលំនៅដ្ឋានប្តី ឬ ប្រពន្ធឬ ទីសំណាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី៣ នៃមាត្រា១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុគ្គលភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណី[20]។ ក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើរតួនាទីជាបឋម ដែលជាអ្នកផ្សះផ្សា បញ្ចុះបញ្ចូលគូភាគីជាមុនសិន។ ដោយការផ្សះផ្សា នេះធ្វើឡើងក្នុងគោលបំណង ដើម្បីអោយគូភាគីត្រូវរ៉ូវ និងជាសះគ្នាហើយបន្តរស់នៅក្នុងជីវភាពប្តីប្រពន្ធសារជាថ្មី។ ដូចនេះក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវខិតខំក្នុងការសម្របសម្រួលធ្វើយ៉ាងណាអោយភាគីទាំងសងខាងស្រុះស្រួលគ្នា ក្នុងអំឡុងពេល ១៥ថ្ងៃ តាមការកំណត់របស់ច្បាប់ បន្ទាប់ពីទទួលពាក្យសុំនោះ[21]។

ចំពោះដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានសមត្ថកិច្ចអ្វីសម្រេចអោយ គូភាគីលែងលះគ្នា បែកចែកទ្រព្យសម្បត្តិ កំណត់អំណាចមេបា និងការបង់អាហារកិច្ចនោះឡើង។ ការដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់គ្រាន់តែជាជម្រើសរបស់ភាគីប៉ុណ្ណោះ ពោលគឺ សហព័ទ្ធអាចដាក់ពាក្យសុំដោយផ្ទាល់ទៅកាន់តុលាការមានសមត្ថកិច្ចតែម្តង។

**១. ការផ្សះផ្សាបានសម្រេច**

ក្នុងករណីដែលការផ្សះផ្សាទទួលបានលទ្ធផល ដោយភាគីទាំងសងខាងយល់ព្រមសះជាត្រូវរ៉ូវនឹងគ្នា ហើយរួមរស់ជាប្តីប្រពន្ធដដែលវិញ សមត្ថកិច្ចក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើកំណត់ត្រាអំពីលទ្ធផលសះជា ក្នុងកំណត់ហេតុការផ្សះផ្សារបស់ ប្រឹក្សាឃុំ-សង្កាត់និង ធ្វើលិខិតកិច្ចសន្យាអោយភាគីទាំងពីរ ដើម្បីទទួលយកការផ្សះផ្សា។ ហើយក្នុងករណីផ្សះផ្សាបានសម្រេចនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ចប់ដោយពុំចាំបាច់បញ្ជូនបន្តទៅកាន់តុលាការទៀតទេ។

**២. ការផ្សះផ្សាមិនបានសម្រេច**

នៅក្នុងក្រមរដ្ឋប្បវេណី ពុំបានចែងពីការផ្សះផ្សាត្រូវធ្វើឡើងច្រើនដងនោះទេ ប៉ុន្តែក្រុមប្រឹក្សា ឃុំ-សង្កាត់ អាចធ្វើការព្យាយាមក្នុងការផ្សះផ្សាជាច្រើនដងបាន។ ក្នុងករណីដែលនៅតែមិនអាចបញ្ចុះបញ្ចូលអោយជាសះបានទេ ក្រុមប្រឹក្សា-សង្កាត់ខំប្រឹងអស់ពីលទ្ធភាពហើយ ប៉ុន្តែគូភាគីនៅតែទទូចចង់ធ្វើការលែងលះ ហើយគ្មានសង្ឃឹមជាសះនឹងគ្នា ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់មានតែធ្វើការបញ្ជូនពាក្យសុំទៅកាន់តុលាការ ដើម្បីមានចំណាត់ការបន្តទៅតាមនីតិវិធីនៃច្បាប់[22]។

[20] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីនៃឆ្នាំ២០០៧

[21] មាត្រា៩៨២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃឆ្នាំ២០០៧

[22] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីនៃឆ្នាំ២០០៧

## កថាភាគទី៣. សមត្ថកិច្ចដោះស្រាយតាមរយៈតុលាការ

បន្ទាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ខិតខំធ្វើការផ្សះផ្សាតែមិនបានសម្រេច នោះពាក្យសុំនឹងត្រូវបញ្ជូនបន្តទៅកាន់តុលាការ នៃលំនៅដ្ឋានខាងប្តីឬប្រពន្ធនោះ។ បន្ទាប់មកតុលាការនឹងបន្តចំណាត់ការនេះ ព្រោះមានតែតុលាការប៉ុណ្ណោះដែលអាចសម្រេចអោយគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបាន ដោយចេះដីកាសម្រេចតាមពាក្យសុំ។ យោងទៅតាម មាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦ សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅដ្ឋាន ជាអាទិ៍។ គោលការណ៍ទូទៅនៃនីតិរដ្ឋប្បវេណីតុលាការត្រូវបំពេញតួនាទីខ្លួនអោយបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ គឺមុននឹងក្រោយការទទួលយករឿងក្តីរដ្ឋប្បវេណីណាមួយមកពិនិត្យ និងធ្វើចំណាត់ការទៅនឹងការត្រូវធ្វើការត្រួតពិនិត្យអោយច្បាស់លាស់ពីសមត្ថកិច្ចរបស់ខ្លួនជាមុនសិន។

ជាទូទៅ តុលាការអាចសាកល្បងធ្វើការផ្សះផ្សា ទោះបីជាបណ្តឹងស្ថិតក្នុងដំណាក់កាលណាមួយក៏ដោយ យោងមាត្រា៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ជាងនេះទៅទៀត មាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណី តម្រូវឱ្យតុលាការធ្វើការសាកល្បងផ្សះផ្សាទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ។

### ១. ការទទួល និងពិនិត្យពាក្យបណ្តឹង

#### ក.ការទទួលពាក្យបណ្តឹង

ដោយយោងទៅតាមមាត្រា៦ ចំណុចទី១ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង បានផ្តល់សមត្ថកិច្ចឱ្យការិយាល័យ កិច្ចការតុលាការ ទទួលបន្ទុកលើការទទួលចាត់ចែងឯកសារចេញចូលរបស់សាលាដំបូង និងចុះបញ្ជីពាក្យ បណ្តឹង និងចាត់ចែងបន្តតាមនីតិវិធី។ ហេតុដូចនេះ នៅពេលភាគីដាក់ពាក្យបណ្តឹងលែងលះ អាចដាក់ពាក្យ បណ្តឹងនៅលេខាធិការដ្ឋានរដ្ឋបាលរបស់សាលាដំបូងដែលមានសមត្ថកិច្ចនោះបាន។

នៅពេលដែលដាក់ពាក្យបណ្តឹង ត្រូវបង់ពន្ធលើពាក្យបណ្តឹង ដែលដើមចោទត្រូវបង់ពន្ធលើពាក្យបណ្តឹងនោះ ចំនួន ៥៥,០០០ ( ប្រាំម៉ឺនប្រាំពាន់ ) រៀល [23]។ ចំណែកឯការបង់ពន្ធលើប្រាក់ប្រដាប់ក្តី តុលាការក្រៅពីពន្ធភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្តី ត្រូវបង់ដែលមានចំនួនប្រែប្រួលទៅតាមការកំណត់របស់តុលាការ និងធ្វើការបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីបណ្តឹងដើម្បីឱ្យតុលាការៈ

- ធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀត តាមនីតិវិធីបណ្តឹង។
- សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅ ដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែល ធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តតៅនៅក្រៅ

[23] មាត្រា៦០នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការ។ ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្តឹង មិនបានបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធទេ នោះ តុលាការនិង លើកពាក្យបណ្តឹងចោលដោយដីកាសម្រេច[24]។

នៅពេលដែលសហព័ទ្ធដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការហើយ ក្រឡាបញ្ជីជា អ្នកមានភារៈក្នុងការទទួលពាក្យបណ្តឹងបន្ទាប់មកក្រឡាបញ្ជី ត្រូវតែអនុវត្តតាមជំហានដូចខាងក្រោមៈ

- ការវាយត្រាលើពាក្យបណ្តឹងដែលបានទទួលនោះ រួចធ្វើការចុះថ្ងៃ ខែ ឆ្នាំដែលបានទទួលពាក្យបណ្តឹង
- បន្ទាប់មកចុះលេខរៀងនៅក្នុងសៀវភៅបណ្តឹងផងដែរ
- បន្ទាប់មក ក្រឡាបញ្ជីត្រូវយកក្របសំបុត្រសំណុំរឿងមកគៀបសំណុំរឿងនោះរួចហើយបញ្ជូនសំណុំរឿងទៅតុលាការ។

ដើម្បីជៀសវាង ពាក្យបណ្តឹងមានលក្ខណៈខ្វះខាតនូវចំណុច ដែលបានកំណត់តាម បញ្ញត្តិច្បាប់ដែលតម្រូវអោយសរសេរពាក្យបណ្តឹងនោះ គេអនុញ្ញាតអោយក្រឡាបញ្ជីមានយោលបល់ចំពោះបញ្ហានៃការខ្វះខាតបាន ក្នុងការពន្យល់ដល់អ្នកដែលបានដាក់ពាក្យបណ្តឹង ដែលបានប្រព្រឹត្តនូវចំណុចខ្វះខាតដូចជា ឈ្មោះរបស់ភាគី ឬ អាសយដ្ឋានមិនច្បាស់លាស់ ដែលផ្ទុយនឹងកថាខណ្ឌទី ២ នៃមាត្រា៧៥ នីតិវិធីតីរដ្ឋប្បវេណី។

ក្រឡាបញ្ជីមិនមានសិទ្ធិ ខាងផ្លូវច្បាប់ក្នុងការពិនិត្យពាក្យបណ្តឹងទេ តែដោយក្រឡាបញ្ជីជាបុគ្គលដែលមានវិជ្ជាជីវៈខាងផ្លូវច្បាប់ផងដែរ ដូចនេះគាត់អាចសម្រួលដល់អ្នកដាក់ពាក្យបណ្តឹងដោយផ្តល់យោបល់ខ្លះៗ ហើយបង្ហាញនូវហេតុផលសមរម្យដូចជា ប្រាប់នូវកង្វះខាតត្រង់ចំណុចណាខ្លះ ដើម្បីជៀសវាងការយឺតយ៉ាវ។ ប៉ុន្តែក្រឡាបញ្ជីមិនអាចនឹងមិនទទួលពាក្យបណ្តឹងរបស់គេបានទេ ប្រសិនអ្នកដាក់ពាក្យបណ្តឹងមិនទទួលយកដំបូន្មាននៃការណែនាំរបស់គាត់ព្រោះក្រឡាបញ្ជីពុំសិទ្ធិពិនិត្យពាក្យបណ្តឹងទេដោយនោះជាសិទ្ធិរបស់តុលាការ។ ដូចនេះហើយ ទោះបីជាបណ្តឹងរបស់សហព័ទ្ធមានលក្ខណៈខ្វះខាត ឬ មិនត្រឹមត្រូវត្រង់ចំណុចណាក៏ដោយ ក៏ក្រឡាបញ្ជីត្រូវទទួលពាក្យបណ្តឹងដោយអនុវត្តតាមជំហាននៃកិច្ចការរបស់ខ្លួន ដោយមិនអាចធ្វើការបដិសេដមិនទទួលពាក្យបណ្តឹងសហព័ទ្ធបានទេ ដោយហេតុថាបណ្តឹងនោះមិនមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ទេ។

### ខ. ការពិនិត្យពាក្យបណ្តឹង

ចំពោះការពិនិត្យពាក្យបណ្តឹងគឺ ការពិនិត្យទៅលើភាពស្រប ឬ មិនស្របទៅនឹងលក្ខខណ្ឌនៃទម្រង់តែប៉ុណ្ណោះ។ បើចៅក្រមពិនិត្យឃើញថា ពាក្យបណ្តឹងបានគោរពតាមលក្ខខណ្ឌត្រឹមត្រូវ អង្គហេតុច្បាស់លាស់មានបញ្ជាក់ពីចំណុចសំខាន់ៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងរួចរាល់ ហើយចៅក្រមទទួលពាក្យបណ្តឹងលែងលះ មិនចាំបាច់បង្គាប់អោយភាគីដែលជាសហព័ទ្ធដើមចោទធ្វើការកែតម្រូវនៅក្នុង បណ្តឹងទៀតឡើយ។ ផ្ទុយទៅវិញបើចៅក្រមរកឃើញថា មានការខ្វះចន្លោះដូច ករណីពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ អង្គហេតុនៃការ

---

[24] មាត្រា៦២នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទាមទារមិនច្បាស់លាស់ ឬ ដោយកំហុសរបស់ចៅក្រមដែលទទួលពាក្យបណ្តឹងលែងលះ ត្រូវបានបង្គាប់អោយសហព័ទ្ធនៃដើមចោទធ្វើការកែតម្រូវពាក្យបណ្តឹងរបស់ខ្លួនជាបន្ទាន់ ដោយបង្គាប់អោយកែតម្រូវដោយកំណត់នូវអំឡុងពេលសមរម្យដើម្បីធ្វើការកែតម្រូវ[25]។ ប្រសិនបើសហព័ទ្ធដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលនៃការកំណត់ទេ តុលាការត្រូវលើកចោលបណ្តឹងលែងលះដោយដីកាសម្រេច។

**២. ការបញ្ជូនពាក្យបណ្តឹង**

ក្នុងដំណាក់កាលនេះ តុលាការបានធ្វើការពិនិត្យពាក្យបណ្តឹងនៃ ការលែងលះរួចហើយ តែប្រសិនបើតុលាការយល់ឃើញថាបណ្តឹងនោះបានបំពេញតាមលក្ខណៈគ្រប់គ្រាន់ហើយនោះ តុលាការត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងទៅសហព័ទ្ធចុងចម្លើយជាចំបាច់[26] ព្រោះថាការបញ្ជូនពាក្យបណ្តឹងនេះ ជាការផ្តល់ឱកាសអោយសហព័ទ្ធម្ខាងទៀតបានដឹងអំពីបណ្តឹងថា តើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងគឺជាអ្វី និងមធ្យោបាយតបទល់របស់ដើមចោទជាដើម ហើយក៏ជាការផ្តល់ឱកាសអោយសហព័ទ្ធចុងចម្លើយ តបដោះសារនិងរៀបចំមធ្យោបាយសម្រាប់ការពារខ្លួនផងដែរ។ ហើយកិច្ចការបញ្ជូននេះ ធ្វើឡើងដោយក្រឡាបញ្ជី ឬបុគ្គលិកប្រៃសណីយ៍ ឬអាជ្ញាសាលាជាដើម[27]។ ការបញ្ជូននេះត្រូវបញ្ជូនទៅដល់សហព័ទ្ធជាចុងចម្លើយទើបនីតិវិធីអាចដំណើរការបាន។

**ផ្នែកទី២. ដំណើរការនៃនីតិវិធីនៃការលែងលះ**

**កថាភាគទី១. ការចាត់ចែងរក្សាការពារ**

ក្នុងដំណើរការនៃពាក្យបណ្តឹងនៃការលែងលះ គឺត្រូវការពេលវេលាមួយយ៉ាងវែងជាពិសេសពេលដែលមានការសាកល្បងធ្វើការផ្សះផ្សាទៅលើសហព័ទ្ធ។ នៅពេលមានករណីដូច្នេះ តុលាការអាចនឹងចេញនូវវិធានការបណ្តោះអាសន្នដែលចាំបាច់ចំពោះការអោយបែកលំនៅ វិធានការចាត់ចែងរក្សាការពារ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងទ្រព្យសម្បត្តិ អាហារកិច្ចរបស់សហព័ទ្ធ សោហ៊ុយកូនជាដើម។ ដើម្បីជាដំណោះស្រាយបញ្ហាទៅលើសហព័ទ្ធ។ វិធានការនេះបានមានការណែនាំ ឬបង្ហាញដែលទៅលើតុលាការដែលមានការបង្គាប់ទៅភាគីរង់ចាំ។

ការចាត់ចែងរក្សាការពារ ជាវិធានការមួយដែលធានាអោយនៅក្នុងគ្រួសារអាចបន្តរស់នៅជាមួយគ្នាបន្តដោយសមរម្យ ទោះសហព័ទ្ធកំពុងតែមានការប្តឹងគ្នាក៏ដោយ។ វិធានការនេះ គឺជាការណែនាំ ឬបញ្ជារបស់តុលាការបង្គាប់ទៅភាគីសហព័ទ្ធហើយចៅក្រមត្រូវចុះក្នុងកំណត់ត្រារបស់តុលាការដែលមានលក្ខណៈជាបណ្តោះអាសន្ន ព្រោះវាមានប្រសិទ្ធិភាពតែក្នុងរយៈពេលដំណើរការនៃរឿងក្តីប៉ុណ្ណោះ។ ពោលគឺនៅ ពេលដែល

[25] មាត្រា៧៨ នីតិវិធីគីរដ្ឋប្បវេណី ២០០៦

[26] មាត្រា៧៩ នីតិវិធីគីរដ្ឋប្បវេណី ២០០៦

[27] មាត្រា២៤៦ នីតិវិធីគីរដ្ឋប្បវេណី ២០០៦

តុលាការ ចេញសាលក្រមស្ថាពររួច នោះនឹងមកជំនួសឱ្យវិធានការបណ្តោះអាសន្ន។ ដោយយោងតាមមាត្រា ៩៨៣នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧អនុញ្ញាតឱ្យតុលាការចេញវិធានការចាត់ចែងរក្សាការពារ ៥យ៉ាងដូចតទៅ ៖

**១. ការដាក់អោយសហព័ន្ធរស់នៅបែកគ្នាជាបណ្តោះអាសន្ន**

យោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បាន ផ្តល់សិទ្ធិអំណាចទៅដល់មេឃុំ ចៅសង្កាត់ អាចចាត់វិធានការបណ្តោះអាសន្នដែលមានដូចជា ការហាមប្រព្រឹត្ត អំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង។ ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំអោយ ចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬ របស់ញាតិសាលោហិតរបស់ជនរងគ្រោះ។ ហាមជនមុខ សញ្ញាចូលជិត ឬ ចូលទៅក្នុងទីលំនៅរួមកន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាត ពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។ ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារ សុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនដែលពាក់ព័ន្ធ[28]។

ស្របទៅនឹងការធ្វើអន្តរាគមន៍របស់ អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះក៏អាចធ្វើបណ្តឹងទៅ តុលាការ រាជធានី ខេត្ត ដើម្បីសុំចេញដីការក្សាការពារ។ តុលាការដែលបានទទួលបណ្តឹងដើម្បីចាត់ការអាចចេញដីការក្សា ការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានសហព័ទ្ធដែលបានប្រើអំពើហិង្សា។ ប្រសិនជាមានអំពើហិង្សា លើរូបរាងកាយប្រពន្ធ ក៏ដូចជាលើកូន ឬក្នុងករណីមានអំពើឃោរឃៅទៅលើស្មារតីធ្ងន់ធ្ងរ នោះប្រពន្ធអាចចង់ ស្នើសុំឱ្យ ភាគីទាំងពីររស់បែកគ្នាចាប់តាំងពីពេលចាប់ផ្តើមនីតិវិធីលែងលះគ្នាបាន។

**២. ការដាក់អោយមានការថែរក្សាកូនជាបណ្តោះអាសន្ន**

ប្រសិនបើភាគីទាំងពីរមិនមានការព្រមព្រៀងគ្នាលើការថែរក្សាកូនទេ ក្នុងអំឡុងពេលនៃនីតិវិធីលែងលះ ចៅក្រមអាចចេញវិធានការកំណត់ថា តើឪពុក ឬម្តាយដែលត្រូវថែរក្សាកូនជាបណ្តោះអាសន្ន។ ជាក់ស្តែង ភាគ ច្រើននៃការលែងលះភាគីទាំងសងខាង សុទ្ធតែប្តឹងទាមទារកូនរៀងៗខ្លួន។ ដូច្នេះដើម្បីការពារសុវត្ថិភាពកូន និង ដើម្បីបញ្ចៀសនូវរាល់វិបត្តិផ្លូវចិត្តទៅលើកូននោះ តុលាការនឹងអនុញ្ញាតឱ្យមានវិធានការគ្រប់គ្រងកូន ពោលគឺ ការថែរក្សាកូន។ តួយ៉ាងពេលឪពុកម្តាយប្តឹងលែងលះគ្នាវាជា បញ្ហាមួយយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រួសារសម្រាប់កូន ព្រោះកូននឹងត្រូវបាត់បង់ភាពកក់ក្តៅពីឪពុកម្តាយ។ ដោយឡែក ការគ្រប់គ្រងកូន ខាងប្រពន្ធអាចមានអាទិភាព ក្នុងការមើលថែទាំកូនជាងខាងប្តី ប្រសិនកូនគឺជាទារកដែលនៅបៅទឹកដោះម្តាយ ព្រោះត្រូវគិតគូរពីសុខភាព ទារកផងដែរ។ ដូចដែលបានលើកឡើងនេះ ក៏ដូចជាការជៀសវាង នូវការបង្ខិតបង្ខំនានាទៅលើការសម្រេចចិត្ត របស់កូន។ តុលាការគប្បីមានចំណាត់ការឱ្យ មានអ្នកមើលថែរក្សាកូន ដែលយល់ឃើញថាសមរម្យ ទើបអាចឱ្យ ការសម្រេចសេចក្តីមានយុត្តិធម៌ជាប្រយោជន៍ ដល់កូន។

[28] មាត្រា ១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

### ៣. ថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន

ចៅក្រម មានអំណាចចេញវិធានការបណ្តោះអាសន្ន ស្តីពីការថែរក្សាការពារនិងប្រើប្រាស់ទ្រព្យសម្បត្តិក្នុងអំឡុងពេលនីតិវិធីនៃការលែងលះ ពីព្រោះសហព័ទ្ធណាម្នាក់អាចព្យាយាមយក ឬក៏លក់ ឬ ផ្ទេរទ្រព្យសម្បត្តិមុនពេលតុលាការមានឱកាសស៊ើបអង្កេត និងធ្វើការបែងចែងទ្រព្យសម្បត្តិដោយយុត្តិធម៌។ ម្យ៉ាងទៀតក៏ជួយការពារមិនអោយភាគីម្ខាងទៀតលក់ ធ្វើអោយខូចខាត ឬ បំផ្លាញទ្រព្យសម្បត្តិនោះ។ ប្រសិនបើសហព័ទ្ធទាំងពីរជាម្ចាស់ផ្ទះ ចៅក្រមអាចសម្រេចថាអ្នកណាជាអ្នករស់នៅក្នុងផ្ទះនោះ ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីនៃការលែងលះនោះ។

### កថាភាគទី២. នីតិវិធីត្រៀមសម្រាប់ទាញហេតុផល

គោលបំណងនៃនីតិវិធីត្រៀមទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី ដើម្បីបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចរឿងក្តីលែងលះនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យនៅក្នុងនីតិវិធីត្រៀមទាញហេតុផលអោយបានល្អិតល្អន់[29]។ នីតិវិធីត្រៀមទាញហេតុផល គឺអាចធ្វើនៅបន្ទប់ធម្មតាណាមួយ ដែលមានការដាក់ឈ្មោះថា ជាបន្ទប់ត្រៀមក៏បានដែរ តែតុលាការពុំចាំបាច់ហាមឃាត់អ្នកផ្សេងចូលរួមទេ។ នៅពេលមុនពេលតុលាការត្រូវសាកល្បងផ្សះផ្សា ឬ ទុកសិទ្ធិអោយគូភាគីផ្សះផ្សារវាង ភាគីនិងភាគី ឬ មេធាវីនិងគូភាគីផ្សះផ្សាជាដំបូងសិន បើមានមេធាវីចូលរួមតំណាងអាណត្តិអោយគូភាគី។ ប៉ុន្តែបើ តុលាការយល់ឃើញថាការផ្សះផ្សា មិនមានភាពសមរម្យ និងការផ្សះផ្សាមិនអាចអោយគូភាគីបញ្ចប់វិវាទបាននោះ តុលាការពុំបាច់ចាប់ផ្តើមការផ្សះផ្សារទេ នោះតុលាការមានសិទ្ធិចាប់ផ្តើមនីតិវិធីត្រៀមទាញហេតុផលតែម្តងក៏បាន[30]។ ដូចនេះ តុលាការអាចកោះហៅភាគីទាំងពីរអោយមកធ្វើការបំភ្លឺម្នាក់ម្តង ដែលកាលបរិច្ឆេទត្រូវបានកំណត់សមរម្យទៅតាមពេលវេលា ដែលគូភាគីអាចចូលរួមបាន[31]។ ដោយសារតែរឿងក្តីលែងលះ ជាវិវាទមួយដែលត្រូវតែមានវត្តមានរបស់ភាគីទាំងសងខាងក្នុងពេលស៊ើបសួរ ទើបធ្វើអោយមានការកាត់សេចក្តីរបស់តុលាការអាចធានាបានថាសមហេតុផលប្រកបដោយភាពសត្យានុម័ត។

កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងទៅនឹងការស្នើសុំពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងទៀតដែលអាចសម្រចបានក្រៅពីកាលពិនិត្យភស្តុតាងឯកសារដោយមានកម្រិតចាំបាច់ ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង[32]។ ជាក់ស្តែងនៅគ្រប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផល តុលាការត្រូវអោយាចអោយតុលាការយកធ្វើការអះអាងនៅពេលសវនាការ។

---

[29] មាត្រា១០៣ នីតិវិធីរដ្ឋប្បវេណី ២០០៦

[30] មាត្រា១០៤ នីតិវិធីរដ្ឋប្បវេណី ២០០៦

[31] មាត្រា១០៥ នីតិវិធីរដ្ឋប្បវេណី ២០០៦

[32] មាត្រា១០៦នីតិវិធីរដ្ឋប្បវេណី ២០០៦

### កថាភាគទី៣. នីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមទាញហេតុផល បានចប់អស់ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទ ដោយធ្វើការទាញហេតុផលផ្ទាល់មាត់ហើយត្រូវកោះហៅគូភាគីមកចូលរួមសារជាថ្មីម្តងទៀត។ ចំពោះរឿងក្តីណា ឬ ចំណុចកន្លែង ណាដែលត្រូវសម្រេចដោយដីការសម្រេចទើបតុលាការអាចកំណត់បានថា ត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់ ឬមិនផ្ទាល់មាត់។ ក្នុងករណីដែលតុលាការសម្រេចមិនការទាញហេតុផលផ្ទាល់មាត់ តុលាការអាចសាកសួរភាគីបាន។

ការពិនិត្យទៅលើភស្តុតាងនៃរឿងក្តីលែងលះ ចៅក្រមត្រូវពិនិត្យលើទំនាក់ទំនងប្តីប្រពន្ធស្របច្បាប់តាមរយៈការបង្ហាញនូវសំបុត្រអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ ហើយកាលណាពិនិត្យឃើញថា ពិតជាប្តីប្រពន្ធស្របច្បាប់មែនទើបអាចបន្តនីតិវិធីទៀត។ ប្តីប្រពន្ធដែលត្រឹមត្រូវស្របច្បាប់ ត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ហើយកិច្ចសន្យានេះត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ និងមានការចុះហត្ថលេខាដោយមន្ត្រីអាត្រានុកូលដ្ឋាន ព្រមទាំងផ្តិតមេដៃរបស់ប្តីប្រពន្ធ និង សាក្សីដែលគ្រប់អាយុការចំនួន ២ នាក់[33] ហើយត្រូវមានការប្រគល់អោយសាមីខ្លួនដែលជាប្តីប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។ រីឯទំនាក់ទំនងគតិយុត្តិដែលភាគីប្តឹងទាមទារកូនក៏ដូចគ្នា ពោលគឺត្រូវមានសំបុត្រកំណើតបញ្ជាក់ដែលបង្ហាញថាកូននោះពិតជាកូនរបស់ដៃគូក្តីទាំងពីរពិតប្រាកដមែន ដែលចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់ នៃទីលំនៅអចិន្ត្រៃយ៍របស់ឪពុកម្តាយ[34] ដែលជាដៃគូក្តីលែងលះនោះ។

ម្យ៉ាងវិញទៀត សម្រាប់ការដាក់ភស្តុតាងនៃម្ចាស់កម្មសិទ្ធិ លើទ្រព្យសម្បត្តិជា បញ្ហាសំខាន់មួយទៀតដែលគូក្តីត្រូវបង្ហាញ ដោយមាន ប្លង់កម្មសិទ្ធិលើអចលនាទ្រព្យ ការបង្ហាញអោយដាច់ស្រឡះពីគ្នារវាងទ្រព្យរួម និងទ្រព្យដោយឡែករបស់អ្នកទាំងពីរ។ បន្ទាប់ពីមានការដាក់ភស្តុតាងអោយតុលាការរួចហើយ នីតិវិធីស៊ើបសួរត្រូវក៏ត្រូវប្រព្រឹត្តិទៅដោយការសាកសួរសាក្សី។ តុលាការអាចបង្គាប់នាំខ្លួនសាក្សីដែលមិនចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេច[35]។ ផ្ទុយពីនេះ តុលាការក៏អាចសួរសាក្សីនៅក្រៅតុលាការបានបើសាក្សីគ្មានករណីកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្តឹង ឬ មានមូលហេតុត្រឹមត្រូវណាមួយដែលមិនអាចចូលខ្លួនទៅតុលាការបាន ឬការចូលខ្លួនរបស់សាក្សីបណ្តាលអោយមានការចំណាយពេលវេលាមិនសមរម្យ និង គូភាគីពុំមានការតវ៉ានោះទេ។

[33] មាត្រា៣០ នៃអនុក្រឹត្យពីអាត្រានុកូលដ្ឋាន២០០០
[34] មាត្រា១៧ នៃអនុក្រឹត្យពីអាត្រានុកូលដ្ឋាន២០០០
[35] មាត្រា១៣២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ក្នុងនោះការស្វែងរកភស្តុតាងនានា មាន ភស្តុតាងចេញពីការទាញហេតុផលផ្ទាល់មាត់ ភស្តុតាងសាក្សី ភស្តុតាងភាគី ភស្តុតាងកោសលវិច្ឆ័យ និងភស្តុតាងឯកសារ។

**ក. ភស្តុតាងចេញពីការទាញហេតុផលផ្ទាល់មាត់**

ភស្តុតាងចេញពីការទាញហេតុផលផ្ទាល់មាត់ ជាដំណាក់ការនៃនីតិវិធីដែល ចៅក្រមពិចារណាពីស្ថានភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ និងព្រមទាំងទទួលស្គាល់អង្គហេតុ។ មួយវិញទៀតនោះគេទទួលស្គាល់វត្តមាននៃការសារភាពរបស់សាក្សីដោយផ្អែកទៅលើភស្តុតាងជាមូលដ្ឋាន។ តុលាការអាចពិនិត្យទៅលើភស្តុតាងតាមការស្នើសុំរបស់ភាគី បើតុលាការមិនអាចសម្រេច ទទួល ឬមិនទទួលនូវការអះអាងអំពីអង្គហេតុដែលភស្តុតាងនោះគូភាគីបានស្នើសុំអោយពិនិត្យដោយឆន្ទានុសិទ្ធិបាន។

**ខ. ភស្តុតាងសាក្សី**

តុលាការ អាចប្រមូលនូវភស្តុតាងគ្រប់គ្រាន់ ដោយចៅក្រមអាចសាកសួរជនណាម្នាក់ជាសាក្សីក៏បាន ដោយតុលាការអាចបង្គាប់អោយនាំខ្លួនសាក្សី មិនព្រមចូលមកកាន់តុលាការដោយគ្មានមូលហេតុត្រឹមត្រូវនោះ តុលាការអាចពិន័យបុគ្គលនោះជាប្រាក់បាន ដោយការពិន័យជាប្រាក់នេះមិនអោយលើសពី ១ លានរៀលទេ។

ចំពោះសាក្សី តុលាការអាចសាកសួរនៅខាងក្រៅតុលាការបាន បើសាក្សីត្រូវធ្វើ សម្បថរួចហើយផ្តល់សក្ខីកម្មក្លែងក្លាយ នោះនឹងត្រូវផ្តន្ទាទោសនៅពេលតុលាការរកឃើញថា សាក្សីមានបាននិយាយការពិតក៏អត់។

**គ. ភស្តុតាងភាគី**

តុលាការធ្វើការសាកសួរភាគី ហើយតុលាការអាចអោយភាគីនោះធ្វើសម្បថមុននឹងនិយាយ ប្រសិនបើភាគីនោះមានការនិយាយមិនពិត ឬក្លែងបន្លំសេចក្តីថ្លែងការណ៍តុលាការអាចពិន័យភាគីនោះជាប្រាក់ ដោយមិនអោយលើសពី ២ លានរៀលទេ។ ក្នុងករណីដែលភាគីនោះមិនបានចូលខ្លួនមក ឬបានបដិសេធផ្តល់នូវចម្លើយនោះតុលាការអាចទទួលស្គាល់បានថា សេចក្តីចំណុចសាកសួរទាំងប៉ុន្មានរបស់ភាគីម្ខាងទៀតនោះ ជាការត្រឹមត្រូវ។

**ឃ. ភស្តុតាងកោសលវិច្ឆ័យ**

ក្នុងដំណើរការនៃការស៊ើបអង្កេត តុលាការអាចបង្គាប់អោយមាន ការធ្វើកោសលវិច្ឆ័យតាមការស្នើសុំរបស់ភាគីបាន។ ក្នុងការធ្វើកោសលវិច្ឆ័យ តុលាការជាអ្នកចាត់តាំងអ្នកជំនាញក្នុងការធ្វើកោសលវិច្ឆ័យ ដោយជននោះត្រូវមានចំណេះវិជ្ជា រួមទាំងសមត្ថភាពគ្រប់គ្រាន់ ទៅនឹងបទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច្ឆ័យ។ ភាគីម្ខាងទៀតនោះអាចនឹងបដិសេធអ្នកធ្វើកោសលវិច្ឆ័យបាន មុខពេលដែលអ្នកធ្វើកោសលវិច្ឆ័យបានធ្វើសេចក្តីសន្និដ្ឋាន ប្រសិនបើភាគីមានភស្តុតាងថា មានការរារាំងដល់សច្ចភាពចេញពីការកោសលវិច្ឆ័យនោះ។

### ង. ភស្តុតាងឯកសារ

ភាគីអាចស្នើសុំទៅកាន់តុលាការ ក្នុងការពិនិត្យភស្តុតាងឯកសារនានា ដើម្បីបង្គាប់អោយអ្នកមានឯកសារផ្តល់នូវឯកសារដែលខ្លួនមាន។ ករណីចាំបាច់ តុលាការអាចឃាត់ទុកនូវឯកសារដែលផ្ញើមកបាន។ ក្នុងនោះម្ចាស់ឯកសារមិនអាចបដិសេធបានទេប្រសិនភាគីជាម្ចាស់ឯកសារមិនព្រមផ្តល់នូវឯកសារតាមការទាមទាររបស់តុលាការទេ នោះតុលាការអាចសន្និដ្ឋានបានថា ភាគីម្ខាងទៀតចំពោះឯកសារ នោះតុលាការអាចពិន័យជាប្រាក់បានដែលមិនអោយលើសពី ២ លានរៀល។

### កថាភាគទី៤. សាលក្រមលែងលះ

សាលក្រមជា សេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់។ ការសម្រេចក្តីនៅក្នុងរឿងលែងលះ មានលក្ខណៈខុសគ្នាពីរឿងក្តីរដ្ឋប្បវេណីធម្មតា ដោយនៅក្នុងរឿងក្តីធម្មតាតុលាការត្រូវសម្រេចនូវអ្វីដែលភាគីបានទាមទារ និងមិនចេញសាលក្រមចំពោះមុខ និងចំណុចណាដែលភាគីមិនបានសុំឡើយ។ ការសម្រេចសេចក្តីនៅក្នុងសាលក្រម ឬ សាលដីការបស់តុលាការនៅក្នុងរឿងក្តីបណ្តឹងរដ្ឋប្បវេណីទូទៅ តុលាការត្រូវសម្រេចតាមការទាមទារទាំងអស់ដែលភាគីបានសុំ ប៉ុន្តែតុលាការមិនអាចសម្រេចចំណុចណាមួយដែលភាគីមិនបានសុំឡើយ[36]។ ភាគីចង់ទាមទារអ្វីនូវអ្វីមួយក្នុងតម្លៃណាដែលភាគីចង់បាន ហើយតុលាការត្រូវតែសម្រេចអោយតាមការចង់បាននោះទេ។ ប៉ុន្តែរឿងបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងអាពាហ៍ពិពាហ៍ ច្បាប់បានផ្តល់សិទ្ធិអោយតុលាការសម្រេចសេចក្តីត្រង់ចំណុចណាដែលភាគីមិនបានស្នើសុំដោយឆន្ទានុសិទ្ធិបាន ប្រសិនបើចៅក្រមយល់ឃើញថាចាំបាច់ និងមានផលប្រយោជន៍ទៅដល់ភាគី[37]។ នៅក្នុងបណ្តឹងលែងលះ តុលាការអាចយកអង្គហេតុដែលមិនអាចអះអាងដោយភាគីមកធ្វើជាមូលដ្ឋាន នៃសាលក្រមដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន បើទោះបីជាភាគីមិនបានស្នើសុំអោយមានការពិនិត្យពីអង្គហេតុក៏ដោយ[38]។ ចំពោះបណ្តឹងទាមទារលែងលះ កាលបើតុលាការសម្រេចចេញសាលក្រមលែងលះដល់ភាគី នោះតុលាការត្រូវតែមានកាតព្វកិច្ចក្នុងការកំណត់អំពីអំណោចមេបាលើកូន និងការចាត់ចែងទ្រព្យសម្បត្តិរបស់ភាគីតាមឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងករណីដែលពុំមានពាក្យស្នើសុំពីភាគី[39]។ តុលាការមានឆន្ទានុសិទ្ធិលើការសម្រេចដោយពិនិត្យលើការពិតជាក់ស្តែង និងមិនអនុញ្ញាតអោយភាគីចាត់ចែងដោយឆន្ទៈរបស់ខ្លួនឡើយ។ ប៉ុន្តែតុលាការ ត្រូវធ្វើការសម្រេចពីអំណាចមេបានេះ ដោយឆ្លងកាត់ការ

---

[36] មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[37] មាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[38] មាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[39] មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

ពិចារណាលើយោបល់របស់កូន និងអាយុកូន[40]។ សាលក្រមអាចសម្រេចចំពោះបញ្ហាអាហារកិច្ច បញ្ហាបីបាច់ផ្គត់ផ្គង់កូន ឬការផ្តល់នូវតាវកាលិកផ្សេងៗទៀតដែល។

ករណីកិច្ចដែលភាគីណាមួយទទួលបន្ទុកប្រាក់ប្រដាប់ក្តី តុលាការត្រូវសម្រេច ទោះភាគីមិនសុំក៏ដោយ។ ចំពោះបណ្តឹងលែងលះក្នុងការសម្រេច តុលាការត្រូវធ្វើការពិចារណានូវចំណុចដូចខាងក្រោមៈ

**នៅក្នុងការទាមទារការលែងលះ** មូលហេតុ ចែងក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី

**ការសម្រេចពីទ្រព្យសម្បត្តិ** តុលាការសម្រេចតាមការពិភាក្សារបស់ភាគី ក្នុងករណីដែលភាគីមិនអាចពិភាក្សាគ្នាបានទេ តុលាការបែងចែកដោយសហព័ទ្ធទាំងពីរមានសិទ្ធិទទួលយក ១/២ នៃទ្រព្យរួម។ ក្នុងករណីបើមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយធ្វើការពិចារណាទៅលើស្ថានភាព ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីទាំងសងខាង ចំពោះលទ្ធកម្មទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើតទ្រព្យអំឡុងពេលរួមរស់ជាមួយគ្នា ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល និងជាប្រយោជន៍របស់កូនជាអាទិ៍ គេហដ្ឋានមានតម្លៃស្មើគ្នានឹងការងារនៅផ្ទះដែរ។

**ការសម្រេចអំពីមេបាន** ករណីដែលសហព័ទ្ធមានកូនជាអនីតិជន ពេលដែលឪពុកម្តាយលែងលះ ត្រូវកំណត់យកឪពុក ឬម្តាយ ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ[41]។ ប្រសិនបើឪពុកម្តាយមិនអាចស្វែងរកដំណោះស្រាយតាមរយៈការជជែកពិភាក្សាបានទេ តុលាការត្រូវសម្រេចដោយផ្ទាល់ ដោយត្រូវគិតពីប្រយោជន៍របស់កូនជាធំ។ អ្នកទទួលសិទ្ធិគ្រប់គ្រងកូននោះ ត្រូវមានការងារធ្វើជាប់លាប់ មានផ្ទះសម្បែងត្រឹមត្រូវ មានអត្តចរិត សមរម្យ និងមានការយកចិត្តទុកដាក់ក្នុងការបីបាច់ថែរក្សាកូនរបស់ខ្លួន។

**ការសម្រេចពីសោហ៊ុយចាំបាច់ដើម្បីទទួលបន្ទុកគ្រប់គ្រង និងថែរក្សាកូន** ត្រូវមានការពិចារណាពីស្ថានភាពជីវភាព ឬ ស្ថានភាពសេដ្ឋកិច្ចរបស់ភាគីម្ខាងទៀតដែលពុំមានអំណាចមេបា[42] ព្រោះស្ថានភាពជីវភាពទាំងនេះគឺសំខាន់ចំពោះកូនណាស់ក្នុងការរស់នៅ។

**ការជួបប្រាស្រ័យទាក់ទងរបស់អ្នកគ្មានអំណាចមេបា** តុលាការត្រូវសម្រេចពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ចំពោះអ្នកគ្មានអំណាចមេបា ដោយគិតពីផលប្រយោជន៍របស់កូនជាអាទិភាព។ ក្នុងនោះដើម្បីការពារកូន រួមទាំងអ្នកមានអំណាចមេបា ជៀសវាងមានជម្លោះម្តងទៀត។

**ការសម្រេចអំពីអាហារកាតព្វកិច្ច** នៅពេលដែលមានការលែងលះ បើករណីដែលភាគីម្ខាងទៀត គ្មានកំហុសហើយមានការខ្វះខាត អាចស្នើសុំអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបាន។ ចំពោះកម្រិតអាហារកាតព្វកិច្ចត្រូវ

[40]មាត្រា ២២ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[41] មាត្រា ១០៣៧ កថាខណ្ឌ ទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[42] មាត្រា ១០៤០ កថាខណ្ឌទី ៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សម្រេចយល់ព្រមពីភាគីទាំងសងខាង។ ក្នុងករណី បើជនដែលទទួលអាហារកាតព្វកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកាតព្វកិច្ចទៀតហើយ[43]។

**ការសម្រេចអំពីប្រដាប់ក្តី** យោងតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៦ បានបញ្ញត្តិថា បន្ទុកប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី តែបើមានការពិភាក្សាគ្នារវាងភាគីទាំងសងខាង នោះភាគីណាក៏អាចជាអ្នកទទួលបន្ទុកប្រដាប់ក្តី[44]។ តុលាការត្រូវសម្រេច ពីករណីកិច្ចទទួលបន្ទុកប្រដាប់ក្តី ទោះបីគ្មានពាក្យសុំរបស់ភាគីណាក៏ដោយក្តី[45]។

**១. ទម្រង់នៃសាលក្រមលៃខលះ**

ពេលដែលខ្លឹមសារនៃសាលក្រមបានបង្កើត ខ្លឹមសារដែលតុលាការសម្រេច ត្រូវសរសេរនៅក្នុងលិខិតសាលក្រម ដែលមានទម្រង់ដូចជា៖

- តុលាការ
- ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- អង្គហេតុ និងចំណុចវិវាទ ត្រូវសរសេរជាខ្លឹមសារសំខាន់ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី
- នៅក្នុងលិខិតសាលក្រម ត្រូវមានការចុះហត្ថលេខារបស់ចៅក្រម ដែលបានចេញសាលក្រមនោះ
- ក្នុងករណីដែលចៅក្រមណាម្នាក់ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ មានធុរៈក្នុងការចុះហត្ថលេខាលើលិខិតសាលក្រម ចៅក្រមផ្សេងទៀតត្រូវចុះហត្ថលេខា ដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះមិនអាចចុះហត្ថលេខាបាន។

ក្រៅពីចំណុចចាំបាច់សរសេរក្នុងលិខិតសាលក្រម ដែលបានរៀបរាប់ដូចខាងលើនេះ តុលាការត្រូវសរសេរពីចំណុចផ្សេងទៀតដូចជា សំណុំរឿង និង ប្រភេទនៃសាលក្រមជាដើម។ បើពុំបានសរសេរទៅតាមចំណុចចាំបាច់ណាមួយទេ នាំអោយមានការខុសទម្រង់សាលក្រម[46]។

**២. ការប្រកាសសាលក្រម**

ការប្រកាសសាលក្រម ជាដំណាក់កាលដែលតុលាការធ្វើការសម្រេចសេចក្តីលើរឿងក្តីហើយបានចេញជាលទ្ធផល និងប្រកាសអោយសហព័ទ្ធទាំងសងខាងបានដឹង។ ការប្រកាសសាលក្រមនៃបណ្តឹងត្រូវបានបែង

[43] មាត្រា៧៦ នៃច្បាប់អាពាហ៍ពិពាហ៍។

[44] មាត្រា ៦៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៦

[45] មាត្រា ១៨២ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៦

[46] សេចក្តីកំណត់មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ចែកជាពីរគឺសាលក្រមចំពោះមុខ និង សាលក្រមកំបាំងមុខ។ ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេលមួយខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់[47]។ ក្នុងអំឡុងពេលនេះ ជាការទុកអោយតុលាការធ្វើការពិចារណាទាំងអង្គហេតុ និងអង្គច្បាប់ ដើម្បីធ្វើការវិនិច្ឆ័យក្នុងការសរសេរសាលក្រមអោយបានត្រឹមត្រូវ។

ជាគោលការណ៍ សាលក្រមរបស់តុលាការនឹងមាននូវអានុភាពបាន លុះត្រាតែសាលក្រមនោះត្រូវបានប្រកាសជាផ្លូវការ និងជាសាធារណៈដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមជាអ្នកអានសេចក្តីសម្រេចបញ្ចប់។ ការប្រកាសសាលក្រម អាចធ្វើទៅបាន ទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសវនាការក៏ដោយ។ លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យភាគី ក្នុងអំឡុងពេល ២ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលតុលាការបានប្រកាសសាលក្រម [48]។

### ២. ១. សាលក្រមចំពោះមុខ

ការប្រកាសសាលក្រមត្រូវធ្វើឡើង តាមការបរិច្ឆេទនៅក្នុងសវនាការដែលជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអាននូវសេចក្តីសម្រេច បញ្ចប់ដោយផ្អែកលើច្បាប់ដើមនៃសាលក្រម។ ប៉ុន្តែក្នុងករណីដែលក្រុមប្រឹក្សាជំនុំជម្រះមានធុរៈដោយមិនអាចចូលរួមបាន អាចអនុញ្ញាតអោយចៅក្រមក្រុមប្រឹក្សាអានជំនួសប្រធានក្រុមប្រឹក្សាជំនុំជម្រះនូវសាលក្រមនោះបាន[49]។ ការអានជំនួសនេះពុំមានឥទ្ធិពលអ្វីដែលធ្វើអោយផ្លាស់ប្តូរនូវអត្ថន័យនៃសេចក្តីសម្រេចរបស់សាលក្រមទេ ពោលក្រុមប្រឹក្សាជំនុំជម្រះបានពិភាក្សា និងសម្រេចរួចហើយ។ ដូច្នេះការអាន ជាការប្រកាសចំពោះការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះតែប៉ុណ្ណោះ។ ក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬ ក៏អាចពន្យល់ខ្លឹមសារនៃសំអាងហេតុដោយផ្ទាល់មាត់បាន។

### ២. ២. សាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ ជាសាលក្រមដែលសម្រេចសេចក្តីដោយពុំមានគូភាគីណាម្ខាង ឬ គ្មានវត្តមានភាគីណាមួយក្នុងពេលកាត់សេចក្តី។ ពោលក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃដែលបានអោយដំណឹងពីសាលក្រមកំបាំងមុខមកដល់ គូភាគីផ្ទាល់ ឬ នៅទីលំនៅដ្ឋានរបស់គូភាគី[50]។

### ៣. ការចូលជាស្ថាពរនៃសាលក្រម

សាលក្រមនឹងមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់សម្រាប់ ការប្តឹង

[47] មាត្រា ១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[48] មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[49] មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[50] មានត្រា ៦២ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

ឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬការប្តឹងទាស់ដែលស្របច្បាប់បានទេ[51]។

**កថាភាគទី៥. ដីកាសម្រេច**

តុលាការជាអ្នកចេញដីការសម្រេចតាមពាក្យសុំ ដោយយកអង្គហេតុដែលមិនបានអះអាង។ ដោយអ្នកដាក់ពាក្យសុំឬភាគីទៀតមកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីបាននិងក្នុងករណីចាំបាច់តុលាការនឹស្រាវជ្រាវអង្គហេតុ និងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ[52]។ សេចក្តីសម្រេចត្រូវធ្វើឡើងដោយដីកាសម្រេច ដែលមានតម្លៃដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ។ គូភាគីអាចធ្វើការប្តឹងជំទាស់បានក្នុងរយៈពេល ២ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងពីដីកាសម្រេច។

ការចេញសេចក្តីសម្រេច ក្នុងរឿងក្តីលែងលះតាមការព្រមព្រៀង ការសម្រេចសេចក្តីត្រូវធ្វើឡើង ដោយដីកាសម្រេច។ តាមបញ្ញត្តិច្បាប់ ដើម្បីចេញដីកាសម្រេចពីរឿងក្តីតុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ពោលរឿងក្តីប្រភេទនេះជារឿងដែលមិនមានភាពស្មុគស្មាញ ដោយហេតុថាភាគីបានព្រមព្រៀងគ្នារួចរាល់ហើយ។ មួយវិញទៀតការលែងលះ ជាការរក្សាសម្ងាត់ផ្ទាល់ខ្លួន របស់ភាគីហេតុនេះហើយ ដើម្បីចេញដីកាសម្រេចអោយលែងលះតាមការព្រមព្រៀងមិនចាំបាច់ទាញហេតុផលដោយសាធារណៈឡើយ។ ប៉ុន្តែក្នុងករណីដែលតុលាការយល់ឃើញចាំបាច់ សម្រាប់នីតិវិធីតុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិបាន។ ដីកាសម្រេចលែងលះតាមការព្រមព្រៀងដែលជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសេចក្តីសម្រេចបញ្ចប់ និង សម្អាងហេតុ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនោះ។ ដីកាសម្រេចមានតម្លៃដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរនៅក្នុងការសម្រេចសេចក្តីនេះផងដែរ អ្វីដែលជាមូលដ្ឋានដែលចៅក្រមលើកយកមកសម្រេចអំពីការលែងលះនោះចៅក្រមធ្វើការពិចារណាទៅលើចំណុចជាច្រើនដែលនៅក្នុងនោះ ជាដំបូងនោះចៅក្រមពិចារណាទៅលើស្ថានភាពគតិយុត្តនៃទំនាក់ទំនងប្តីប្រពន្ធនៃការលែងលះនោះ។ បើចៅក្រមធ្វើការសាកសួរហើយយល់ឃើញថាភាគីប្តីប្រពន្ធមិនមានឆន្ទះពិតប្រាកដក្នុងការលែងលះនោះទេ នោះចំណាត់ការចំពោះរឿងក្តីនៃការលែងលះនោះមិនអាចប្រព្រឹត្តទៅរួចទេ ពោលចៅក្រមនឹងចេញដីកាសម្រេចលើពាក្យសុំចោល ដើម្បីបញ្ចប់នីតិវិធីលែងលះនេះ មាត្រា២០ ក្នុងករណីបែបនេះចៅក្រមមិនធ្វើការសម្រេចឆន្ទះព្រមព្រៀងពិតប្រាកដពីភាគីនៃការលែងលះ។

លើសពីនេះទៀតចៅក្រមធ្វើការពិចារណាទៅលើចំណុចនៃការទាមទារចម្បងរបស់ភាគី គឺការលែងលះ និងជាហេតុការទាមទារបន្ទាប់បន្សំផ្សេងទៀតដូចជា ការបែងចែកសិទ្ធិអំណាចមេបាលើកូនការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នកមិនមានអំណាចមេបាទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់

---

[51] មាត្រា ១៩៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[52] មាត្រា ២៨ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីនីតិវិធីរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង

ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិបំណុលជាអាទិ៍ ប៉ុន្តែពុំមានការលំបាកឡើយដោយថាការលែងលះដោយមានការព្រមព្រៀង គឺគូភាគីមានការព្រមព្រៀងទៅលើចំណុចទាំងនោះ ព្រោះការលែងលះដោយមានការព្រមព្រៀងអាចប្រព្រឹត្តបាន លុះត្រាភាគីបានព្រមព្រៀងគ្នាគ្រប់ចំណុចទើបបាន តែបើមិនមានការព្រមព្រៀងលើគ្រប់ចំណុចតែការស្រេចសេចក្តីមិនអាចធ្វើបានឡើយ។ ទោះក្នុងស្ថានភាពបែបណាក៏ដោយតុលាការអាចធ្វើការពិចារណាទៅលើចំណុចដូចខាងលើបានលុះត្រាមានការស្នើសុំពីសហព័ទ្ធផ្ទុយមកវិញប្រសិនភាគីនៃការលែងលះមិនបានលើកឡើងចំណុចនីមួយៗក្នុងកិច្ចព្រមព្រៀង ឬដោយផ្ទាល់មាត់ក៏ដោយ តុលាការមិនអាចធ្វើការពិចារណាឡើយ ប៉ុន្តែក្នុងចំណុចដែលតុលាការពិចារណា គឺឆន្ទៈព្រមព្រៀងលែងលះរបស់ភាគីដែលជាដីកាសម្រេចលើអង្គហេតុ អង្គសេចក្តីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជា បណ្តឹងដែលត្រូវធ្វើការជូនដំណឹងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតបដីកាសម្រេច ទៅភាគីនៃការលែងលះដែលសាមីខ្លួនក្នុងរឿងលែងលះនេះតែម្តង។ ចំណែកចំណុចដែលភាគីមិនបានព្រមព្រៀងលើបញ្ហាចែកទ្រព្យសម្បត្តិ ឬចែកកូនមិនមែនជាឧបសគ្គដល់ការសម្រេចសេចក្តីឡើយ។ ចំពោះទៅលើការជូនដំណឹងនេះមិនចាំបាច់ត្រូវតែធ្វើតាមរយៈ ការបញ្ជូនដែលតម្រូវអោយក្រឡាបញ្ជីត្រូវប្រគល់ដោយ ផ្ទាល់ដោយយោងតាមមាត្រា ២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីដូចជាការបញ្ជូន សាលក្រម ឬសាលដីការសម្រេចនោះទេ ម៉្យាងទៀតដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀងក៏ដូចជាការសម្រេចលើអង្គសេចក្តីនៃរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវបានចូលជាស្ថាពរ និង មានអានុភាពអនុវត្តនៅពេលផុតរយៈពេលប្តឹងជំទាស់ក្នុងរយៈពេល ០២ សប្តាហ៍គិតចាប់ពីបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។ ការសម្រេចចំពោះបណ្តឹងលែងលះដោយគ្មានការព្រមព្រៀងនេះត្រូវធ្វើឡើងដោយសាលក្រម។ នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលតុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋានសាលក្រមបាន។

ម្យ៉ាងទៀត ការទាញហេតុផលដោយផ្ទាល់មាត់មិនត្រូវធ្វើឡើងជាសាធារណៈឡើយ ករណីខ្លះតុលាការអាចអនុញ្ញាតអោយជនណាដែលតុលាការយល់ឃើញថាសមរម្យចូលស្តាប់ជាអ្នកសង្កេតការណ៍បាន។ ក្នុងសាលក្រមនៃការលែងលះទោះបីជាគ្មានការទាមទារអោយតុលាការកំណត់អំពីអ្នកមានអំណាចមេបា ចំពោះកូនក៏ដោយតុលាការអាចកំណត់ពីអ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិបានដោយសួរយោបល់របស់កូន និងថ្លឹងថ្លែងទៅតាមអាយុនិងចាស់ទុំរបស់កូននោះហើយ បើមានពាក្យសុំពីភាគីត្រូវធ្វើការសម្រេចអំពីការចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូន ឬការចាត់ចែងទាក់ទងនឹងទ្រព្យសម្បត្តិនោះ។ ករណីខ្លះភាគីព្រមព្រៀងគ្នាតែការលែងលះប៉ុណ្ណោះ ប៉ុន្តែមិនព្រមព្រៀងគ្នាចំពោះការបែងចែកទ្រព្យសម្បត្តិ និងគ្រប់គ្រងបីបាច់ថែរក្សាកូនទេ។ ប្រសិនបើដំបូងឡើងការភាគីដាក់ពាក្យបណ្តឹងលែងលះ តែក្រោយមកស្រាប់តែភាគីធ្វើការលែងលះដោយការព្រមព្រៀងគ្នាវិញ នោះភាគីត្រូវដកពាក្យបណ្តឹងលែងលះ រួចដាក់ពាក្យសុំលែងលះដោយមានការព្រមព្រៀងគ្នា

ហើយតុលាការនឹងចេញដីកាសម្រេចអំពីការលែងលះដោយមានការព្រមព្រៀងវិញ។ ប្រសិនបើភាគីព្រមព្រៀងទៅលើការលែងលះមិនមានការព្រមព្រៀងគ្នាអំពីការចែងទ្រព្យសម្បត្តិទេនោះ តុលាការនឹងសម្រេចអំពីការចែងទ្រព្យសម្បត្តិដោយសាលក្រមវិញ។

# ជំពូកទី៣
# អានុភាពនៃការលែងលះ

# ជំពូកទី៣
# អានុភាពនៃការលែងលះ

អានុភាពនៃការលែងលះគឺជាការផ្តាច់នៃចំណងអាពាហ៍ពិពាណ៍រវាងសហព័ទ្ធពេលដែលតុលាកាចេញសេចក្តីសម្រេចអំពីការលែងលះចូលជាស្ថាពររួច។ ក្នុងនោះផងដែលអានុភាពនៃការលែងលះគឺ មានចំពោះសាលក្រមនិងសេចក្តីសម្រេច។ ករណីសេចក្តីសម្រេចនោះជា ដីកាសម្រេចរយៈពេលនៃការប្តឹងជំទាស់មាន ២ សប្តាហ៍ គិតពីថ្ងៃទទួលដំណឹងពីដីកាសម្រេចមក ដោយថាសេចក្តីសម្រេចគឺ អានុភាពនៃការលែងលះ ដោយមានការព្រមព្រៀង។ នៅពេលដែលសាលក្រមគឺជា អានុភាពនៃការលែងលះដោយមិនមានការព្រមព្រៀងចំពោះការប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃដែលបានទទួលនូវការបញ្ជូលលិខិតសាលក្រម[53]។

លុះត្រាតែមានសាលក្រមលែងលះដែលជា សេចក្តីសម្រេចរបស់តុលាការក្នុងការសម្រេចអោយចំណងអាពាហ៍ពិពាហ៍ រវាងគូភាគីត្រូវបានរលាយដែលជាហេតុធ្វើអោយបាត់បង់នូវ ចំណងគតិយុត្តរវាង ប្តី និងប្រពន្ធពីមុនមក។

ដូច្នេះការលែងលះមានអានុភាពផ្តាច់នូវសិទ្ធិ និង ករណីកិច្ចរវាងប្តីប្រពន្ធធ្វើអោយមានអានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ អានុភាពចំពោះទ្រព្យសម្បត្តិ និងអានុភាពចំពោះកូន។

## ផ្នែកទី១ អានុភាពចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

នៅពេលដែល សហព័ទ្ធទាំងសងខាងបានលែងលះគ្នារួចហើយនោះ អ្នកទាំងពីរបានរួចផុតពីកាព្វកិច្ចទាំងឡាយដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍។ ជាទូទៅអតីតសហព័ទ្ធដែលត្រូវផ្តល់នូវអាហារកាតព្វកិច្ចនោះត្រូវមានលទ្ធភាពក្នុងការចំណាយនូវអាហារកិច្ចទៅអតីតសហព័ទ្ធម្ខាងទៀត។ ដោយចៅក្រមត្រូវពិនិត្យទៅលើប្រាក់ខែប្រាក់បៀវត្ស លទ្ធភាពក្នុងការរកប្រាក់ សុខភាព អាយុរបស់បុគ្គលនោះ ដើម្បីកំណត់កម្រិតនៃអាហារកាតព្វកិច្ចត្រូវបង់ ប៉ុន្តែនេះលុះត្រាតែអតីតសហព័ទ្ធម្ខាងនោះមិនទាន់រៀបការថ្មី។ ប៉ុន្តែបើអតីតសហព័ទ្ធម្ខាងនោះរៀបការជាថ្មី នោះលែងមានសិទ្ធិទទួលអាហារកិច្ចទៀតហើយ។ ដោយអ្វីទាំងឡាយនឹងបញ្ចប់ដោយអានុភាពនៃការលែងលះ។

### ១. ចំពោះបុរស ឬ ស្ត្រី

បុរស នៅពេលដែលបានបញ្ចប់នូវអាពាហ៍ពិពាហ៍រួចហើយ គឺ អាចរៀបអាពាហ៍ពិពាហ៍ម្តងទៀតបានដោយមិនបាច់រងចាំនោះទេ បន្ទាប់ពីសាលក្រមចូលជាស្ថាពរ។ ចំពោះស្ត្រីវិញ គឺផ្ទុយពីបុរសដោយថាស្ត្រីត្រូវបានច្បាប់កំណត់រយៈពេលនៃការរៀបអាពាហ៍ពិពាហ៍ថ្មី ពោលគឺ នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានទេ

[53] មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ប្រសិនបើអំឡុងពេល ១២០ ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬ លុបចោល។ ចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិត[54]។ ពោលគឺ នារីត្រូវប្រាកដខ្លួនឯងអោយច្បាស់ថា ខ្លួនមានផ្ទៃពោះ ឬ មិនមានផ្ទៃពោះអោយច្បាស់ ដើម្បីនៅពេលដែលបញ្ជាក់អំពីបញ្ហាខាងលើនេះ នោះស្ត្រីអាចរៀបអាពាហ៍ពិពាហ៍បាន។

**២. ចំពោះឈ្មោះ និង ញាតិ**

**ក. ចំពោះឈ្មោះ**

ការលែងលះគ្នានិងនាមត្រកូលប្តីឬប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបានឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន[55]។ ដោយសហព័ទ្ធមួយចំនួនជាពិសេសស្ត្រីភាគច្រើននៅពេលដែលរៀបអាពាហ៍ពិពាហ៍រួចហើយ គឺប្រើត្រកូលខាងប្តី។ ហេតុនេះ ក្នុងករណីថានៅពេលក្រោយការលែងលះ សហព័ទ្ធណាម្ខាងដែលបានប្តូរនាមត្រកូលរបស់ខ្លួន មានសិទ្ធិក្នុងការបន្តប្រើ នាមត្រកូលរបស់សហព័ទ្ធមុនរបស់ខ្លួនបាន។ ដូច្នេះនៅពេលមានការលែងលះ មិនថាសហព័ទ្ធភាគីប្តីក្តី ឬ ប្រពន្ធក្តីមានសិទ្ធិក្នុងការប្រើនាមត្រកូលតាមឆន្ទះរបស់ខ្លួនដោយគ្មានការបង្ខំពីនរណាម្នាក់។

**ឧទាហរណ៍៖** លោក ច័ន្ទ វិជ្ជា បានរៀបអាពាហ៍ពិពាហ៍ជាមួយនារីម្នាក់ឈ្មោះ លោកស្រី ទ្រី ដាវី។ ក្នុងករណីនេះ លោកស្រី ទ្រី ដាវី អាចប្រើនាមត្រកូលរបស់ប្តីលោកស្រីនាងបាន ដោយប្តូរទៅជា លោកស្រី ច័ន្ទ ដាវី វិញ។ ប្រសិនបើអ្នកទាំងពីរលែងលះគ្នាវិញ លោកស្រី ដាវី អាចប្រើឈ្មោះ ទ្រី ដាវី ដដែលក៏បាន ឬប្តូរទៅប្រើឈ្មោះដើមជា ទ្រី ដាវី វិញក៏បាន។

**ខ. ចំពោះញាតិ**

នៅពេលដែលភាគីទាំងសងខាងបានលែងលះគ្នារួចហើយនោះ ទំនាក់ទំនងញាតិទាំងសងខាងនឹងត្រូវបានបញ្ចប់ ពោលគឺ ទំនាក់ទំនងញាតិពន្ធ ត្រូវបញ្ចប់ដោយការលែងលះគ្នា[56]។ ញាតិ សំដៅទៅលើការមានជាប់ខ្សែលោហិតផ្ទាល់ ជាមួយបុគ្គលណាម្នាក់។ ដោយញាតិពន្ធនេះ កើតឡើងនៅពេលដែលមានចំណងអាពាហ៍ពិពាហ៍ដែលនាំអោយមានការភ្ជាប់គ្នាជាសាច់ញាតិ ចំពោះគ្រួសាររបស់សហព័ទ្ធទាំងសងខាង។ ហើយក៏ត្រូវបានបញ្ចប់ទៅវិញ នៅពេលដែលចំណងអាពាហ៍ពិពាហ៍នោះបានបញ្ចប់ ពោលសហព័ទ្ធទាំងសងខាងមានការលែងលះ ដោយសម្រេចចែងផ្លូវគ្នារៀងខ្លួន ដោយមិនទុកនូវញាតិពន្ធបន្តទៀតនោះទេ។ ប៉ុន្តែក្នុងករណី

[54] មាត្រា ៩៥០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[55] មាត្រា ៩៨១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[56] មាត្រា ៩៨១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បើនារីនោះមានកូន ទំនាក់ទំនងរវាងញាតិ និងកូននៅតែមានដដែលទោះភាគីទាំងសងខាងត្រូវបានលែងលះគ្នាក៏ដោយ។

**៣. ចំពោះអត្តាធីនភាព**

អត្តាធីនភាព គឺជាការផ្តល់អោយអនីតិជនបានរួចផុតពីអាណាព្យាបាល ឬ អំណាចមេបាហើយមានសមត្ថភាពដូចទៅនឹងនីតិជនដែរ។ ពោលគឺមិនថាជននោះមិនទាន់គ្រប់អាយុ ១៨ឆ្នាំក៏ពិតមែន តែនៅពេលដែលអនីតិជននោះដែរមិនទាន់ដល់វ័យរៀបអាពាហ៍ពិពាហ៍ បែរជារៀបអាពាហ៍ពិពាហ៍នោះគឺ ចាត់ទុកជានីតិជន។ អនីតិជននៅក្រោមអាណាព្យាបាល ដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានចាត់ទុកថា បានដល់នីតិភាព[57]។ លក្ខខណ្ឌនៃការរួចផុតពីអាណាព្យាបាល អនីតិជននៅក្រោមអាណាព្យាលដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយគ្មានការប្រកាសពីតុលាការ។ ក្នុងករណីខាងលើនេះ ទោះបីជាភាគីបានលែងលះនៅពេលក្រោយក៏ដោយ ក៏អានុភាពនៃការរួចផុតពីអាណាព្យាលសម្រាប់អនីតិជនមិនត្រូវរលត់ឡើយ[58]។ ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជន នោះត្រូវមានការយល់ព្រមពីសំណាក់ដែលមានអំណាចមេបាឬអាណាព្យាបាលសម្រាប់អនីតិជន[59]។ ពោលនៅពេលដែលអាណាព្យាបាលយល់ព្រមអោយអនីតិជននោះរៀបអាពាហ៍ពិពាហ៍ទើបអនីតិជននោះក្លាយជានីតិជនដែលគេហៅថាអត្តាធីនភាព។ បើទោះបីជានៅពេលដែលអនីតិជនបានរៀបអាពាហ៍ពិពាហ៍រួចហើយ តែបែបជាត្រូវលែងលះវិញក៏អត្តាធីនភាពនៅតែមានដដែល។

**ឧទាហរណ៍៖** លោក សុខ មាន អាយុ ២០ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍ ជាមួយ នារីម្នាក់ឈ្មោះ ណារី អាយុ ទើបតែ ១៥ឆ្នាំប៉ុណ្ណោះ។ អាណាព្យាបាលខាងស្រីបានអនុញ្ញាត និង យល់ព្រមអោយ ណារី បានរៀបអាពាហ៍ពិពាហ៍ជាមួយលោក សុខ ដូចដែលពួកគេចង់បាន។ នៅពេលដែររៀបអាពាហ៍ពិពាហ៍ហើយ ណារីក៏មាននូវអត្តាធីនភាព ពោលគឺ លោកស្រី ណារីបានក្លាយជា នីតិជនបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍រួច។ ហើយប្រសិនបើអ្នកទាំងពីលែងលះគ្នាវិញ នៅកំឡុងពេលដែលណារីមានអាយុត្រឹម១៦ឆ្នាំ ក៏អត្តាធីនភាពរបស់ណារីនៅតែមានដដែល។

សរុបមក នៅក្រោយពេលលែងលះ ភាគីដែលទទួលបាននូវអត្តាធិនភាពតាមរយៈអាពាហ៍ពិពាហ៍ គឺនៅតែមានសិទ្ធិទទួលនូវអត្តាធិនភាពដដែល ពោលគឺ ភាពជានីតិជន ដែលមិនបានតម្រូវអោយប្តូរត្រឡប់ទៅជាអនីតិជនឡើយ។

---

[57] មាត្រា១០៩៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] មាត្រា ១០៩៥ កថាខណ្ឌទី ២ និង ទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[59] មាត្រា៩៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ផ្នែកទី ២ អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ

ចំពោះការចែកទ្រព្យសម្បត្តិ ក្រោយពេលលែងលះត្រូវមានការព្រមព្រៀងពីភាគីទាំងសងខាង។ ដោយមានការព្រមព្រៀងនេះ ដោយលើគូភាគីទាំងពីរដោយមិនគិតទៅថាភាគីណាមួយមានតិចនោះទេ ពោលគឺ បើគូភាគីទាំងសងខាងមានការព្រមព្រៀងគ្នាដោយគ្មានការបង្ខំនោះទេ តុលាការនឹងកាត់សេចក្ដីទៅតាមការព្រមព្រៀងនោះជានិច្ច ដោយមិនពិចារណាច្រើន។

ប៉ុន្តែបើគ្មានការព្រមព្រៀងវិញនោះ សហព័ទ្ធទាំងសងខាងត្រូវយកទ្រព្យខ្លួនដែលមាននៅពេលមុនរៀបអាពាហ៍ពិពាហ៍ ជាអច្ច័យទាយក្ដីក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។ ហេតុនេះសហព័ទ្ធទាំងសងខាងត្រូវបានទ្រព្យសម្បត្តិរួមពាក់កណ្ដាលម្នាក់ ក្នុងករណីពិសេស និងតាមសំណើររបស់សហព័ទ្ធណាម្នាក់ ដែរតុលាការសម្រេចចែកទ្រព្យសម្បត្តិរួមផ្សេងដោយគិតទៅដល់ប្រយោជន៍របស់កូន[60]។

### ១. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យានេះ ជាកិច្ចសន្យាដែលជួយសម្រួល និងបង្កើតនូវភាពជាក់លាក់របស់ប្ដី ឬ ប្រពន្ធ ដែលចុះកិច្ចសន្យានោះរួមមាន ចំណាត់ចែងនូវសិទ្ធិទ្រព្យសម្បត្តិ កាតព្វកិច្ច និងករណីកិច្ច ដែលតម្រូវអោយសហព័ទ្ធគោរពទៅតាម រួមទាំងអនុវត្តតាមច្បាប់បានកំណត់។

ការចុះកិច្ចសន្យានេះ ត្រូវតែមាននូវការព្រមព្រៀងគ្នារវាងភាគី ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីក្រសួងការយុត្តិធម៌ ហើយគោរពតាមការកំណត់របស់ច្បាប់ ដើម្បីធានាអោយមានភាពត្រឹមត្រូវ។ ការចុះកិច្ចសន្យាទ្រព្យសម្បត្តិទ្រព្យរបស់សហព័ទ្ធ ជាកត្តាសំខាន់ដែលទទួលបាននូវភាពច្បាស់លាស់ទៅលើទំនាក់ទំនងទ្រព្យទាំងមុនពេលរៀបអាពាហ៍ពិពាហ៍ និង ក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ដូច្នេះនៅពេលដែលភាគីទាំងសងខាងសម្រេចចិត្តលែងលះនោះ អានុភាពនៃទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យាបានលេចឡើងម្ដងទៀត។ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើប្ដីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិ ដែលកំណត់ដោយច្បាប់)[61] ។

### ២. ទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់

ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេ ត្រូវបែកចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមច្បាប់ដែលបានចែងទ្រព្យសម្បត្តិប្ដីប្រពន្ធ ជា ២ ប្រភេទ គឺ ទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម។

តុលាការអាចសម្រេចចែងទ្រព្យសម្បត្តិដោយ សហព័ទ្ធនីមួយៗត្រូវទទួលបាននូវ ទ្រព្យសម្បត្តិដោយ

---

[60] មាត្រា ៩៨០ កថាខណ្ឌទី១ និង កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[61] មាត្រា ៩៦៩ កថាភាគទី ២នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ ភាគ ២ នៃទ្រព្យសម្បត្តិរួម និងការបែកចែកទ្រព្យសម្បត្តិរួមដោយករណីពិសេស[62]។

### ២.១. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាមួយ ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិសហព័ទ្ធនៅពេលមានចំណងអាពាហ៍ពិពាហ៍[63]។

**ឧទាហរណ៍៖** មុនរៀបអាពាហ៍ពិពាហ៍ លោក ក មានឡាន ២ គ្រឿង ម៉ូតូ ១ គ្រឿង និង ផ្ទះ២ ល្វែង ហើយ លោកស្រី ខ មាន ឡាន ១គ្រឿង និង ប្រាក់ដែលមានក្នុងកុង ចំនួន ៨០០០០ ដុល្លារ។ ក្នុងករណីនេះ ឡាន ២ គ្រឿង ម៉ូតូ និង ផ្ទះ២ ល្វែង ជារបស់លោក ក រីឯឡាន ១គ្រឿង និងប្រាក់សន្សំជារបស់លោកស្រី ខ។ នេះជាទ្រព្យដែលអ្នកទាំងពីរមានមុនពេលរៀបអាពាហ៍ពិពាហ៍ ពោលគឺ ជាទ្រព្យរៀងខ្លួន។ ប៉ុន្តែក្រោយពេល ក និង ខ រៀបអាពាហ៍ពិពាហ៍ រួចហើយឪពុកម្ដាយរបស់ ខ បានអោយ ដីពីរកន្លែងអោយទៅ ខ ដោយ ដី២កន្លែង ដែល ខ ទទួលបានគឺតាមរយៈការប្រទានកម្ម ពោលជាទ្រព្យសម្បត្តិដោយឡែករបស់ ខ។ ម៉្យាងវិញទៀត ក ដែលមានផ្ទះ ២ល្វែងរួចហើយ តែបែរជាលក់ផ្ទះមួយល្វែងចេញក្នុងតម្លៃ៧០០០០ ដុល្លារ នោះហើយថ្លៃលក់គឺជាថ្លៃតមដែលបានតាមរយៈការចែងទ្រព្យសម្បត្តិដោយឡែក ដូច្នេះហើយតម្លៃលក់ជាទ្រព្យសម្បត្តិដោយឡែករបស់ ខ ដែលមិនមានអ្វីទាក់ទងទេ។

### ២.២. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ពោលគឺ ទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្រៅដោយឡែក នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម។ ក្នុងនោះបើគ្មានការព្រមព្រៀងរវាងភាគីលែងលះទេ នោះតុលាការនឹងធ្វើការចែកទ្រព្យសម្បត្តិរួមជា ២ ទៅកាន់ប្តី និងប្រពន្ធដែលបានលែងលះ[64]។

**ឧទាហរណ៍៖** ក្រោយពី លោក ក និង លោកស្រី ខ បានរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីរបានទិញដីចម្ការដ៏ធំមួយកន្លែងដែលមានតម្លៃ ៦០០០០ ដុល្លារ ដោយបានយកលុយពីលោក ក ដើម្បីទិញដីចម្ការរបស់ គ។ ដូចនេះហើយទិញដីចម្ការដែលបានទិញពី គ ត្រូវក្លាយជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

---

[62] មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[63] មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[64] មាត្រា៩៨០កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងសង្គម គ្រួសារនីមួយៗគឺមានបន្ទុកកិច្ចការរៀងៗខ្លួន ដោយក្នុងនោះបន្ទុកក្នុងគេហដ្ឋានត្រូវបានធ្លាក់ទៅលើ ភាគីប្រពន្ធ ខណៈភាគីប្តីមានបន្ទុកមួយចេញទៅក្រៅធ្វើការ។ ចំពោះកិច្ចការក្នុងគេហដ្ឋានត្រូវបានចាប់ទុកមានតម្លៃស្មើនឹងការងារនៅក្រៅផង[65]។ ការងារនៅគេហដ្ឋានត្រូវបានអោយតម្លៃ និង កំណត់ដោយច្បាប់ដែលមានតួនាទីសំខាន់ក្នុងការចូលរួមរកប្រាក់ចំណូលទៅក្នុងគ្រួសារផង។

**ផ្នែកទី៣. អានុភាពនៃការលែងលះចំពោះកូន**

នៅក្រោយការលែងលះ តុលាការនឹងសម្រេចអំពីអំណាចមេបាទៅលើកូនអោយភាគីណា ម្ខាងជាអ្នកមានអំណាចមេបា អាចជាឪពុក ឬម្តាយ។ ការប្រគល់អំណាចមេបា ជាការប្រគល់សិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា អប់រំកូន ទៅភាគីណាមួយក្រោយពីគូភាគីបានលែងលះគ្នា។

**១. ការកំណត់អំណាចមេបា**

ករណីដែលមានការលែងលះ ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ[66]។ ពោលគឺ ជាការផ្តល់នូវសិទ្ធិបីបាច់ថែរក្សា អប់រំកូនជាដើម ដោយនេះជាតួនាទីមួយរបស់មេបាចំពោះកូន។ ប៉ុន្តែបើមិនមានការពិភាក្សាគ្នាទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយធ្វើការពិចារណាទៅលើផលប្រយោជន៍របស់កូន[67]។

**ឧទាហរណ៍៖** ប្តីបានដាក់ពាក្យសុំលែងលះ ក្នុងនោះអ្នកទាំងពីរមានកូនម្នាក់ដែលមានអាយុ ៩ ឆ្នាំ។ អ្នកទាំងពីរបានទាមទារសិទ្ធិចិញ្ចឹមកូនរៀងខ្លួន។ ដោយប្តីមានមុខរបរជាអ្នករកស៊ី ចំណែកប្រពន្ធពុំមានប្រាក់ចំណូលអ្វីទេ។ ប៉ុន្តែប្តី ចូលចិត្តដើរផឹកស្រា ពេលខ្លះមានទំនាស់ជាមួយអ្នកដទៃទៀតផង។ ករណីនេះ ទោះប្តីមានមុខរបរ មានប្រាក់យ៉ាងណា ក៏កាយវិការរបស់ ប្តីខាងលើនេះហើយអាចប៉ះពាល់ដល់សតិអារម្មណ៍ក្មេងនោះ ដែលជាផលអវិជ្ជមានទៅលើកូនបាន។ ដូចនេះតុលាការសម្រេចប្រគល់អំណាចមេបាចំពោះកូនទៅអោយប្រពន្ធ ជាម្តាយដើម្បីគ្រប់គ្រងមើលខុសត្រូវវិញ។

ក្នុងករណីដែលកូនដល់វ័យមួយសមស្របអាចយល់ដឹង នោះអាចជ្រើសរើសឪពុក ឬម្តាយជាអ្នកមានអំណាចមេបាបាន ពោលគឺយោលបល់របស់កូនតុលាការត្រូវបានយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូន[68]។

លើសពីនេះ ក្នុងករណីឪពុកម្តាយលែងលះគ្នាមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបា

---

[65] មាត្រា៩៨០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[66] មាត្រា១០៣៧ កថាភាគទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[67] មាត្រា១០៣៧ កថាភាគទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[68] មាត្រា២២ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១

ចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែនៅក្រោយកំណើតរបស់កូនអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន[69]។

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូនភាគីនោះមានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទង់កូន និងករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន[70]។ ពោល ត្រូវធ្វើឡើងដោយផ្អែកតាមការពិភាក្សារបស់ឪពុកម្តាយ ហើយករណីដែលមិនមានការពិភាក្សាគ្នាបានទេ តុលាការជាអ្នកកំណត់ តាមការទាមទាររបស់ឪពុក ឬ ម្តាយ។ ពាក់ព័ន្ធនឹងការសម្រេចសេចក្តីពីការចូលជួប និងប្រាស្រ័យទំនាក់ទំនង តុលាការត្រូវធ្វើការពិចារណាទៅលើប្រយោជន៍កូនជាអាទិភាព ពោលតុលាការត្រូវពិចារណាគិតទៅលើ ទំនាក់ទំនងរវាងកូន និងឪពុកម្តាយពេលដែលរស់នៅជាមួយគ្នា អាយុ សុខភាព ស្ថានភាពផ្លូវចិត្តរបស់កូន រួមទាំងស្ថានភាពផ្លូវចិត្តរបស់ភាគីទាំងសងខាងជាដើម។ មួយវិញទៀត តុលាការត្រូវពិចារណាទៅលើស្ថានភាពនៃជីវភាព សេដ្ឋកិច្ចរបស់ឪពុកម្តាយទាំងសងខាង។

**២.អាហារកាតព្វកិច្ចចំពោះកូន**

ភាគីដែលមិនបានថែរក្សាកូនមានកាតព្វកិច្ច ផ្តល់អាហារកិច្ចដល់កូនតាមលទ្ធភាពរបស់ខ្លួន។ អាហារកិច្ច អាចផ្តល់ជាប្រាក់ ឬជារបស់របបអ្វីមួយ។ ឪពុក ឬ ម្តាយ ដែលមានអំណាចមេបាទៅលើកូនមានសិទ្ធ និងករណីកិច្ចចិញ្ចឹមបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន រហូតដល់កូនក្លាយជានីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន[71]។ ដូចនេះក្រោយពីការលែងលះ ឪពុក ឬ ម្តាយត្រូវមានអាហារកិច្ចដល់កូនរបស់ខ្លួន ពោលទោះជាមានការលែងលះគ្នាក្តី ប៉ុន្តែកូននៅតែជាប់ខ្សែលោហិតដោយផ្ទាល់របស់អ្នកទាំងពីរដែល។

**ឧទាហរណ៍៖** លោកស្រី ដាវី  បានលែងលះគ្នាពី លោក ដារា ហើយនាងត្រូវតុលាការសម្រេចប្រគល់អំណាចមេបាលើកូនម្នាក់ ដែលជាអនីតិជន។ ហេតុផលនោះគឺការសម្រេចគឺមកពីលោក ដារា តែងតែដើរលេងយប់ផឹកស្រវឹង និងថែមទាំងពេលមកដល់ផ្ទះវិញមានការប្រើអំពើហិង្សាទៅលើប្រពន្ធកូនជាប្រចាំ។ ក្នុងនោះប្រសិនជាលោក ដារា បានការកែប្រែខ្លួនដឹងស្គាល់ពីកំហុសរបស់លោកនោះវាប្រាកដជាប្រសើរ ប៉ុន្តែនៅពេលជាមួយគ្នានោះផងដែលលោកស្រី ដាវី មានការខ្វះខាតយ៉ាងខ្លាំងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និងមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអោយកូនទៅសាលារៀនសូត្រ។ ក្នុងស្ថានភាពបែបនេះ បើសិនជាលោក ដារា ស្នើសុំទៅអោយតុលាការផ្លាស់ប្តូរអ្នកមានអំណាចមេបាទៅលើកូននោះការទាមទារអោយ លោកស្រី ដាវីប្រគល់កូនមកអោយចិញ្ចឹមថែរក្សាវិញម្តងនោះលោក ដារាពិតជាមានភាគរយឈ្នះច្រើននឹងទទួលបានអំណាចមេបាទៅលើកូនវិញ។

[69] មាត្រា១០៣៧ កថាភាគទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[70] មាត្រា១០៤០ កថាភាគទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[71] មាត្រា១០៣៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សរុបមក អាហារកាតព្វកិច្ចជា សិទ្ធរួមទាំងករណីកិច្ចមួយដែលកំណត់ចំពោះទំនាក់ទំនងញាតិ ផ្តង់ផ្តត់ទៅលើផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះញាតិដែលកំណត់ជាក់លាក់ម្នាក់ ឬ ច្រើននាក់ ជាពិសេសនោះគឺចំពោះកូន ព្រោះបើកូនជាអនីតិជន គឺត្រូវការផ្តល់អាហារកាតព្វកិច្ចជាច្រើន ដែលតម្រូវតាមការចាំបាច់ពាក់ព័ន្ធ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន តាមច្បាប់កំណត់។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយ ក្នុងទិដ្ឋភាពច្បាប់ និង ទិដ្ឋភាពជាក់ស្តែងក្នុងសង្គម រួមទាំងដំណាក់កាលនៃនីតិវិធីនីមួយៗ នៃការលែងលះរួចមក ប្រាកដណាស់យើងអាចយល់ដឹង និងមានចំណេះដឹងបន្ថែមពីលែងលះបានច្រើនជាងមុន។ ការលែងលះ ជាកត្តាមួយដែលមនុស្សក្នុងសង្គមតែងតែជួបប្រទះ ហើយជាបញ្ហាក្នុងគ្រួសារដែលធ្វើអោយភាគីសហព័ទ្ធ ត្រូវប្រឈមនឹងគុណវិបត្តិ ភាពស្មុគស្មាញ និងបញ្ហាជាច្រើន។ ដោយឥទ្ធិពលនៃការលែងលះនេះធ្វើអោយប៉ះពាល់ទៅសង្គមជាតិ ព្រោះមិនចុះសម្រុងជាមួយគ្នារវាងប្តីប្រពន្ធ។ មួយវិញទៀត ក៏ព្រោះតែការលែងលះ ធ្វើអោយប្តី ប្រពន្ធមានការខាតបង់ថវិកា និង ចំណាយពេលវេលាជាដើម ដែលជាហេតុអវិជ្ជមានមួយ ធ្វើអោយមានការរាំងរាដំណើរការការងារ និង ការវង្វេងភាពក្នុងគ្រួសារ។

ចំពោះកូន គឺអាចមានភាពប៉ះពាល់ទៅលើ ផ្នែកស្មារតី និង ផ្នែកសម្ភារៈ ជាដើម។ ដោយហេតុថា ឪពុកម្តាយមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការ មើលថែ អប់រំកូន ជាដើម។ ក្នុងពេលនោះអាចធ្វើអោយកូន មានអារម្មណ៍មួយថា ខ្វះភាពកក់ក្តៅពីឪពុកម្តាយ ពោលគឺបាត់បង់ភាពកក់ក្តៅ គ្មានការអប់រំ ប្រៀនប្រដៅ អាចធ្វើអោយកូនមិនអាចរៀន និងអាចធ្វើអោយកូនធ្វើរឿងអ្វីដែលខុសបាន។ ហេតុនេះការមានភាពកក់ក្តៅពី ឪពុកម្តាយ គឺ សំខាន់ណាស់សម្រាប់កូនដែលជា កត្តាមួយនៃកម្លាំងចិត្តរបស់កូន។

ការលែងលះបានបន្សល់ទុកនូវផលវិបាកដល់ គ្រួសារ និងកូនជាច្រើនផង តែការលែងលះនេះធ្វើអោយភាគីសហព័ទ្ធរួចផុតពីចំណងអាពាហ៍ពិពាហ៍ដែលមិនចុះសម្រុងគ្នា ក៏ជាការកាត់នូវអាពាហ៍ពិពាហ៍ដែលមានតែផលវិបត្តិ ពោលទោះជានូវតែបន្តនោះអាចនាំអោយមានបញ្ហាទៅមុខជាពុំខាត អាចឈានដល់ការប្រើហិង្សាដែល អាចធ្វើអោយប៉ះពាល់ទៅដល់ ផ្លូវកាយ និង ផ្លូវចិត្ត ដែលអាចធ្វើជាគំរូអាក្រក់ដល់កូន រួមទាំងសង្គម។ ដូចនេះការលែងលះ ជាវិធីមួយដែលល្អបំផុត ទៅលើភាគីរងគ្រោះ ដែលអាចរកនូវជីវិតថ្មីមួយភ្លឺស្វាង និង ជៀសខ្លួនពីទុក្ខទាំងឡាយដែលធ្លាប់ឆ្លងកាត់ពីមិនមក ជាជាងនៅទ្រាំដែលអាចធ្វើអោយប៉ះពាល់ដល់ ផ្លូវកាយ និង ផ្លូវចិត្ត។

យ៉ាងណាមិញ ដោយយោងតាមការបកស្រាយនៅប្រធានខាងលើ បានឆ្លុះបញ្ចាំងអោយឃើញថា ការផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ដែលល្អបំផុតនោះគឺ ការដោះស្រាយទៅតាមប្រព័ន្ធតុលាការ ដោយ អនុលោមទៅតាមច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធនឹងការលែងលះ។

សរុបសេចក្តីមក ការរៀបអាពាហ៍ពិពាហ៍មិនមែនតាមតែចំណង់ចិត្តនោះទេ មុនពេលសម្រេចចិត្តថានឹងចាប់ផ្តើមចំណងអាពាហ៍ពិពាហ៍នោះ យើងគួរគប្បីសិក្សាស្វែងយល់ ពិនិត្យ គិតពិចារណា ពីគ្នាអោយបានស៊ីជម្រៅ ក្នុងការរើសដៃគូជីវិតមួយដែលច្បាស់លាស់ ព្រោះនៅពេលដែលមានការរើសដៃគូជីវិតខុសនោះអាចឈានដល់ការលែងលះ។ ដូចនេះ យើងគួររួមគ្នាជួយកាត់បន្ថយការលែងលះ ដោយគ្រាន់តែចាប់ផ្តើមពីយើងខ្លួនឯងផ្ទាល់។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់នូវ ការស្រាវជ្រាវ សរសេរនិង រៀបចំនូវសារណាអំពីប្រធានបទ « ការលែងលះ » រួចមក យើងខ្ញុំយល់ឃើញថា ការលែងលះពិតជាមានភាពស្មុគស្មាញជាច្រើន ថែមទាំងផ្តល់នូវផលអវិជ្ជមានទៅដល់សាមីខ្លួនផ្ទាល់ បុគ្គលពាក់ព័ន្ធ ព្រមទាំងសង្គមជាតិផងដែរ។ ហេតុនេះ ដើម្បីរួមចំណែកពង្រឹងប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជាយើងអោយកាន់តែល្អប្រសើរឡើង ហើយជួយសម្រួលក្នុងការកាត់បន្ថយអត្រានៃការលែងលះនៅក្នុងសង្គម យើងខ្ញុំសូមអនុញ្ញាតសំណូមពរ រួមជាមួយនឹងការបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនមួយចំនួន ដែលពួកយើងទាំងពីរយល់ថាគួរតែកែលម្អបន្ថែមទៀត ដើម្បីជាផលប្រយោជន៍ដល់យើងគ្រប់ៗរូប ដែលរួមមាន៖

- សូមរាជរដ្ឋាភិបាល មេត្តាផ្សព្វផ្សាយនូវការយល់ដឹងបន្ថែមទៅលើការលែងលះទៅដល់ប្រជាពលរដ្ឋដោយមានការចុះដោយផ្ទាល់ពីសំណាក់សមត្ថកិច្ច ឬមានការបង្កើតនូវកម្មវិធីដែលពាក់ព័ន្ធទៅនឹងការលែងលះ ទៅកាន់ប្រជាពលដ្ឋដែលនៅឆ្ងាយពីទីក្រុង ដែលមានការខ្វះខាតការយល់ដឹងពីការលែងលះ។
- សូមរាជរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានយល់ដឹងគ្រប់ៗគ្នា ជាពិសេសដាក់ទណ្ឌកម្មដល់អ្នករំលោភបំពានច្បាប់នេះ និងអ្នកប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារឲមានលក្ខណៈធ្ងន់ធ្ងរ។
- សូមមន្ត្រីនៅថ្នាក់មូលដ្ឋាន ដែលពាក់ព័ន្ធទៅនឹង សំណុំរឿងនៃការលែងលះជួយបន្ថែមនូវការផ្សះផ្សាចំពោះសហព័ទ្ធឲ្យអស់ពីលទ្ធភាពជាមុនសិន មុនពេលសម្រេចចិត្តឲ្យពួកគាត់លែងលះគ្នាតាមផ្លូវតុលាការ។
- គប្បីមានការកំណត់អាយុមុនពេលរៀបអាពាហ៍ពិពាហ៍ដោយគិតចាប់ពីក្លាយជានីតិជន ព្រោះក្នុងវ័យនោះអ្នកទាំងពីរដែលក្លាយជាប្តីប្រពន្ធ ប្រាកដជាមានការយល់ដឹង និងជាវ័យមួយដែលអ្នកទាំងពីរមានភាពទំនួលខុសត្រូវទៅលើបន្ទុកគ្រួសារ។
- សូមប្តីប្រពន្ធមានការអធ្យាស្រ័យអោយគ្នាទៅវិញទៅមក ចេះជួយកែត្រូវគ្នាទៅវិញទៅមក ព្រោះមិនមានបុគ្គលណាម្នាក់ដែលមិនមានកំហុសឡើយ ហេតុដូច្នេះក្នុងនាមជាប្តីប្រពន្ធរមែងតែងតែមានការខុសឆ្គងចំពោះគ្នាបន្តិចបន្តួច ពោលគឺនាក់ទាំងពីរមានការកែតម្រូវគ្នានូវចំណុចដែលខ្វះខាត បែបនេះហើយទំនាក់ទំនងប្តីប្រពន្ធកាន់តែមានភាពស្និទ្ធស្នាលនឹងគ្នា។
- ប្តីប្រពន្ធទាំងសងខាង គប្បីរៀនគិតវិជ្ជមានអំពីគ្នាទៅវិញទៅមកអោយបានច្រើន ព្រោះវាមិនត្រឹមតែធ្វើឱ្យយើងរស់នៅ យ៉ាងមានក្តីសុខនោះទេ វាក៏ជារឿងមួយដែលមានប្រយោជន៍ជាខ្លាំងសម្រាប់ទំនាក់

ទំនងប្តីប្រពន្ធ ព្រោះថា នៅពេលដែលគិត អ្វីដែលល្អៗ អំពីគ្នាវាក៏ជាវិធីសាស្ត្រមួយ ដែលធ្វើឲ្យមនុស្សពីរនាក់អាចបង្កើននូវការទុកចិត្តគ្នា និងមនោសញ្ចេតនា លើសពីនេះវាក៏ជួយឱ្យទំនាក់ទំនង រវាងប្តីប្រពន្ធរបស់មនុស្សពីរនាក់ជៀសផុតពីការឈ្លោះ ប្រកែកគ្នាផងដែរ។

- ក្នុងនាមជាប្តីប្រពន្ធត្រូវមានភាពយោគយល់ចេះអធ្យាស្រ័យអោយគ្នាទៅវិញទៅមក ដើម្បីជៀសពីការកើតឡើងនៃការលែងលះ និង មានការប្រើហិង្សា។ ពោលគឺ ដើម្បីអោយគ្រួសារមួយមានសុភមង្គលទៅមុខតទៅទៀតបាននោះ គឺភាគីដែលត្រូវជាប្តីប្រពន្ធ ត្រូវមានការយល់ពីគ្នា និងចេះគិតពិតចារណាអោយត្រឹមត្រូវ ដោយត្រូវបំពេញនូវតួនាទីភារកិច្ចកាតព្វកិច្ចរបស់ខ្លួន ដូចជា ការធ្វើជាគំរូដល់កូន ក្នុងការធ្វើជាប្តីល្អ ប្រពន្ធល្អ ដែលត្រូវចេះសហការជួយគ្នាក្នុងពេលមានអាសន្នជាដើម។

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ក្រមរដ្ឋប្បវេណីនៃឆ្នាំ២០០៧
- សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨ ឆ្នាំ២០១២
- ច្បាប់ស្តីពីឯកពន្ធភាព ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៦
- ច្បាប់ស្តីពីនីតិវិធីនៃ រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
- ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០
- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥៦ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩

## ខ. បទបញ្ជា

- អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- អនុក្រឹត្យពីអាត្រានុកូលដ្ឋាន២០០០ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
- សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨ ឆ្នាំ២០១២

## គ. សៀវភៅ និង ឯកសារផ្សេងៗ

- លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត «សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និង គ្រួសារ» ឆ្នាំ២០១៧
- បណ្ឌិត ឥន យឿន «នីតិគ្រួសារ និង អាពាហ៍ពិពាហ៍» ឆ្នាំ២០២១
- សៀវភៅពន្យល់អំពីមាត្រានីមួយៗនៃនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ ក្រមរដ្ឋប្បវេណីតិយុត្ត

- ប្រកាសលេខ២៨ កយប្រក/០៧ នៃទីស្តីការក្រសួងយុត្តិធម៌ ឆ្នាំ២០០៧
- ប្រកាសស្តីពី នីតិតវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ

## ឧបសម្ព័ន្ធទី ២ ៖ទម្រង់លិខិតរដ្ឋបាលពាក់ព័ន្ធនឹងការលែងលះ

- សំបុត្រអាពាហ៍ពិពាហ៍
- កិច្ចព្រមព្រៀងលែងលះ
- ពាក្យសុំលែងលះតាមការព្រមព្រៀង
- ពាក្យសុំដីកាសម្រេចលែងលះ
- ពាក្យបណ្តឹងលែងលះ
- ពាក្យសុំតំណាងដោយអាណត្តិ
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ
- ពាក្យសុំ និងកោះហៅសាក្សី
- ដីកាកោះ ដីការបញ្ជូន
- របាយការណ៍បញ្ជូន
- ដីការបង្គាប់អោយបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ
- កំណត់ហេតុស្តីពីនីតិវិធីទាញត្រៀមសម្រាប់ការទាញហេតុផល
- កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលផ្ទាល់មាត់
- ដីកាសម្រេចលែងលះតាមការព្រមព្រៀង
- លិខិតបញ្ជាក់សាលក្រមស្ថាពរ
- សាលក្រមលែងលះ

# ឧបសម្ព័ន្ធទី ១

# ក្របខណ្ឌតាមដានតាមពិនិត្យ

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌

p

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រកាស ស្តីពី
នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ដំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៤

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ចំណាប់អារម្មណ៍របស់
## ឯកឧត្តម អង្គ វង្សវឌ្ឍនា
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងមោទនភាពខ្ពស់ដោយក្រសួងយុត្តិធម៌ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលជាច្រើនជាបន្តបន្ទាប់រួមមានៈ បញ្ញត្តិមូលដ្ឋាន បញ្ញត្តិបន្ទាប់បន្សំ និងបញ្ញត្តិពិសេស ដែលបទប្បញ្ញត្តិទាំងនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងការរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ នៅក្នុងទំនាក់ទំនងរវាង បុគ្គល និងបុគ្គល ដែលបានរៀបអាពាហ៍ពិពាហ៍ និងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្តី ជាអចលនវត្ថុក្តី គប្បីបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិនោះ ថាតើធនធានទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិរួម ? ហើយធនធានទ្រព្យសម្បត្តិណាខ្លះ ជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ ?

ករណីនេះ នៅប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសឲ្យភាគីអាចកំណត់ឲ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឲ្យមានបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹង ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ។

ទស្សនៈនៃគោលគំនិត ក្នុងការកំណត់នូវទំនាក់ទំនងនៃទ្រព្យសម្បត្តិនេះ ក៏ត្រូវបានយកមកបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយបានអនុវត្តកាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងមកនេះ ។

នៅក្នុងមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ឲ្យតែមិនផ្ទុយនឹងសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេស ចំពោះទ្រព្យសម្បត្តិនោះទេ នោះត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។ p

រីឯមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយក្រសួងត្រូវរៀបចំកំណត់អំពី បែបបទ និងទម្រង់ នៃការចុះបញ្ជីតាមរយៈប្រកាសរបស់ក្រសួង ។

ផ្អែកតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារមួយ ដោយសហការ ជាមួយជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ដើម្បីរៀបចំ បែបបទ និងទម្រង់ នៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយប្រើប្រព័ន្ធចុះបញ្ជីដែលរៀបចំឡើងដោយប្រើក្រដាសដាក់ក្នុងក្រឡា ។

ជាមួយនឹងការអបអរសាទរនៃភាពជោគជ័យ របស់ក្រុមការងារក្នុងការរៀបចំប្រកាសនេះ ខ្ញុំក៏សូមធ្វើការវាយតម្លៃខ្ពស់ កោតសរសើរ និងសូមថ្លែងអំណរគុណ ដោយស្មោះអស់ពីចិត្ត ចំពោះស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងការខិតខំប្រឹងប្រែង ការព្យាយាម យកអស់ពីកំលាំងកាយ និងបញ្ញាស្មារតី របស់ក្រុមការងារ និងជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ។ ជាពិសេស ក្រុមការងារសាស្ត្រាចារ្យជប៉ុន ដែលបានចូលរួម ប្រឹក្សាយោបល់ នៅក្នុងការរៀបចំ បទប្បញ្ញត្តិគតិយុត្តដ៏មានសារៈសំខាន់នេះ ហើយក៏ជាផ្នែកមួយនៃការអភិវឌ្ឍនវិស័យច្បាប់ ស្របតាមគោលនយោបាយ ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ជំហានបន្ទាប់ ក្រសួងយុត្តិធម៌ក៏បានកំណត់ទិសដៅឲ្យ ក្រុមការងារដែលបានរៀបចំប្រកាសនេះ ត្រូវធ្វើការបណ្តុះបណ្តាល និង ផ្សព្វផ្សាយប្រកាសនេះ ឲ្យបានទូលំទូលាយទៅដល់មន្ត្រីអនុវត្តច្បាប់និងប្រជាពលរដ្ឋទូទៅ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ប្រកាសនេះនឹងក្លាយជាឧបករណ៍គតិយុត្តដ៏សំខាន់ ដែលផ្តល់សិទ្ធិ និងបើកឱកាស ឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមានបំណងចង់ធ្វើការចុះបញ្ជី អាចធ្វើការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ហើយឈានទៅដល់ការបង្កើតទំនាក់ទំនងរវាង បុរស និងស្ត្រី ឲ្យមានភាពច្បាស់លាស់ និងតម្លាភាព ពាក់ព័ន្ធនឹងបញ្ហាទ្រព្យសម្បត្តិ និងចូលរួមចំណែកក្នុងការពង្រឹងគោលការណ៍សមភាពយេនឌ័រនៅក្នុងសង្គម ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

p

**អង្គ វង្សវឌ្ឍនា**

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ


**ជំពូកទី ១- បទប្បញ្ញត្តិទូទៅ**

ប្រការ ១ - គោលដៅ ............ ២

ប្រការ ២ - គោលបំណង ............ ២

ប្រការ ៣ - វិសាលភាព ............ ២

**ជំពូកទី ២- សមត្ថកិច្ចចុះបញ្ជី**

ប្រការ ៤ - ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី ............ ២

**ជំពូកទី ៣- ការបង្កើត ការគ្រប់គ្រងក្រូណូ និងអំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ**

**ផ្នែកទី ១- ការបង្កើតក្រូណូ**

ប្រការ ៥ - ការបង្កើតក្រូណូ ............ ៣

ប្រការ ៦ - ក្រូណូទទួលពាក្យសុំ ............ ៣

ប្រការ ៧ - ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............ ៤

ប្រការ ៨ - ក្រូណូសម្រាក់ដាក់ឯកសារពាក្យសុំ ............ ៤

ប្រការ ៩ - ក្រូណូលើកចោល ............ ៤

ប្រការ ១០ - ក្រូណូសម្រាក់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ............ ៤

ប្រការ ១១ - ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ............ ៤

**ផ្នែកទី ២- ការគ្រប់គ្រងក្រូណូ**

ប្រការ ១២ - ការគ្រប់គ្រងក្រូណូ ............ ៥

**ផ្នែកទី ៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ**

ប្រការ ១៣ - ការរក្សាទុកឯកសារក្នុងក្រូណូទទួលពាក្យសុំ និងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............ ៥

ប្រការ ១៤ - អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំ ក្រូណូលើកចោល ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ............ ៥

**ជំពូកទី ៤- បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី**

ប្រការ ១៥ - ពាក្យសុំចុះបញ្ជី ............ ៥

ប្រការ ១៦ - ទម្រង់នៃពាក្យសុំចុះបញ្ជី ............ ៦

ប្រការ ១៧ - ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី ............ ៦

ប្រការ ១៨ - ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់..........៧

## ជំពូកទី ៥- ពាក្យសុំចុះបញ្ជី

ប្រការ ១៩ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ..........៧
ប្រការ ២០ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ..........៨
ប្រការ ២១ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ..........៨
ប្រការ ២២ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ..........៩
ប្រការ ២៣ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ..........១០
ប្រការ ២៤ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយមូលហេតុ សហព័ទ្ធណាម្នាក់បានស្លាប់..........១០
ប្រការ ២៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយផ្អែកលើ សាលក្រម ឬ សាលដីកាស្ដាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ..១១
ប្រការ ២៦ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ តាមសេចក្ដីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែល មិនមែនជាបណ្ដឹង..........១១
ប្រការ ២៧ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយផ្អែកតាម សាលក្រម ឬ សាលដីកាស្ដាពរ ដែលបានកំណត់ក្នុងច្បាប់ស្ដីពីការអនុវត្ត ក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ..........១២
ប្រការ ២៨ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍..........១២

## ជំពូកទី ៦- ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

ប្រការ ២៩ - ការទទួលពាក្យសុំចុះបញ្ជី..........១៣
ប្រការ ៣០ - ការដកពាក្យសុំចុះបញ្ជី..........១៣
ប្រការ ៣១ - ការពិនិត្យពាក្យសុំចុះបញ្ជី..........១៣
ប្រការ ៣២ - ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី..........១៣
ប្រការ ៣៣ - ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ..........១៤
ប្រការ ៣៤ - ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី..........១៤
ប្រការ ៣៥ - ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ..........១៤
ប្រការ ៣៦ - អានុភាពនៃការចុះបញ្ជី..........១៤

## ជំពូកទី ៧- របៀបចុះបញ្ជី និងចងក្រងទុកក្នុងក្រុណ្ឌ

ប្រការ ៣៧ - របៀបចុះបញ្ជីក្នុងក្រុណ្ឌទទួលពាក្យសុំ..........១៥

ប្រការ ៣៨ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................១៥
ប្រការ ៣៩ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............១៥
ប្រការ ៤០ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............១៦
ប្រការ ៤១ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.១៦
ប្រការ ៤២ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍..................១៦
ប្រការ ៤៣ - វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ .......................១៧
ប្រការ ៤៤ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ.....................................១៧
ប្រការ ៤៥ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌលើកចោល.................................................................១៧
ប្រការ ៤៦ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ.....................១៧
ប្រការ ៤៧ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី....១៨

## ជំពូកទី ៨- នីតិវិធីនៃការចេញលិខិតបញ្ជាក់

ប្រការ ៤៨ - របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ...............................................................១៨
ប្រការ ៤៩ - ការចេញលិខិតបញ្ជាក់.......................................................................................១៨

## ជំពូកទី ៩- អវសានប្បញ្ញត្តិ

ប្រការ ៥០ - កាលបរិច្ឆេទ នៃការអនុវត្ត.................................................................................១៩

ឧបសម្ព័ន្ធទី ១ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..................................................២០
ឧបសម្ព័ន្ធទី ២ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..........................២១
ឧបសម្ព័ន្ធទី ៣ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន ......................................២២
ឧបសម្ព័ន្ធទី ៤ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ...............២៣
ឧបសម្ព័ន្ធទី ៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.....................២៤
ឧបសម្ព័ន្ធទី ៦ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ .......................................២៥
ឧបសម្ព័ន្ធទី ៧ - ពាក្យសុំឲ្យចេញលិខិតបញ្ជាក់...........................................................................២៦
ឧបសម្ព័ន្ធទី ៨ - សន្លឹកក្រដាសទទួលពាក្យសុំ ...........................................................................២៧
ឧបសម្ព័ន្ធទី ៩ - សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..................................................២៨
ឧបសម្ព័ន្ធទី ១០ - សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.................................២៩
គំរូចុះបញ្ជី ១ - សន្លឹកក្រដាសទទួលពាក្យសុំ ...........................................................................៣០
គំរូចុះបញ្ជី ២ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) .................................៣១
គំរូចុះបញ្ជី ៣ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា).......................៣២
គំរូចុះបញ្ជី ៤ - ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) ...............................៣៤
គំរូចុះបញ្ជី ៥ - ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ....................៣៥
គំរូចុះបញ្ជី ៦ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) .........................៣៧

គំរូចុះបញ្ជី ៧ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ........៣៨
គំរូចុះបញ្ជី ៨ - ការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋានជាអាទិ៍ (សន្លឹកចុះបញ្ជី)........................................៣៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៨០ គយធ.ប្រក/១៣

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 023 2 7 841

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបង្កើតអានុភាពរវាងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឲ្យបានត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

គោលបំណងនៃប្រកាសនេះ គឺអនុញ្ញាតឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឲ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើចំណុច ដូចខាងក្រោម ៖

- ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- នីតិវិធីនៃការចេញលិខិតបញ្ជាក់។

## ជំពូកទី ២
## សមត្ថកិច្ចចុះបញ្ជី

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី**

១- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

២- មន្ត្រីដែលទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

៣- ក្រូណូទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវរក្សាទុកនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

# ជំពូកទី ៣
# ការបង្កើត ការគ្រប់គ្រងក្រូណូ និងរយៈពេលរក្សាទុកឯកសារក្នុងក្រូណូ
## ផ្នែកទី ១
## ការបង្កើតក្រូណូ

**ប្រការ ៥ : ការបង្កើតក្រូណូ**

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ត្រូវបង្កើតក្រូណូ ដូចខាងក្រោម ៖

១. ក្រូណូទទួលពាក្យសុំ

២. ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

៣. ក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ

៤. ក្រូណូលើកចោល

៥. ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ

៦. ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

**ប្រការ ៦ : ក្រូណូទទួលពាក្យសុំ**

១- ក្រូណូទទួលពាក្យសុំ គឺជាក្រូណូសម្រាប់ចុះព័ត៌មាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងចុះលេខទទួលពាក្យសុំនៅលើពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

២- សន្លឹកក្រដាសទទួលពាក្យសុំ ដែលដាក់ក្នុងក្រូណូ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខរៀងទទួលពាក្យ
- កាលបរិច្ឆេទ នៃការទទួលពាក្យ
- ប្រភេទ នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ជាប្តីប្រពន្ធ
- បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន)
- ផ្សេងៗ

## ប្រការ ៧ : ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាក្រូណូសម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- សន្លឹកចុះបញ្ជី ដែលដាក់ក្នុងក្រូណូ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខចុះបញ្ជី និង លេខទទួលពាក្យសុំ
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណង និងមូលហេតុនៃការចុះបញ្ជី
- ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ប្រការ ៨ : ក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ

ក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ គឺជាក្រូណូសម្រាប់ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ ដែលមន្ត្រីចុះបញ្ជីបានទទួលពីអ្នកដាក់ពាក្យសុំ ។

## ប្រការ ៩ : ក្រូណូលើកចោល

ក្រូណូលើកចោល គឺជាក្រូណូសម្រាប់ដាក់លិខិតលើកចោលពាក្យសុំចុះបញ្ជីរបស់មន្ត្រីចុះបញ្ជី។

## ប្រការ ១០ : ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ

ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ គឺជាក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ព្រមទាំងដាក់សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកសារដែលភ្ជាប់មកជាមួយ ។

## ប្រការ ១១ : ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី គឺជាក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

## ផ្នែកទី ២
## ការគ្រប់គ្រងក្រូណា

**ប្រការ ១២ : ការគ្រប់គ្រងក្រូណា**

ក្រូណា គឺត្រូវគ្រប់គ្រង និងរក្សាទុកនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ។

## ផ្នែកទី ៣
## អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណា

**ប្រការ ១៣ : ការរក្សាទុកឯកសារក្នុងក្រូណាទទួលពាក្យសុំ និងក្រូណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

ឯកសារក្នុងក្រូណាទទួលពាក្យសុំ និងក្រូណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកជានិរន្តរ៍ ។

**ប្រការ ១៤ : អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណាសម្រាប់ដាក់ឯកសារពាក្យសុំ ក្រូណាលើកចោល ក្រូណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រូណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

១- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណាសម្រាប់ដាក់ឯកសារពាក្យសុំ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំ ។

២- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណាលើកចោល មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតលើកចោល ។

៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ។

៤- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ។

## ជំពូកទី ៤
## បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី

**ប្រការ ១៥ : ពាក្យសុំចុះបញ្ជី**

១- រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ ។

២- ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

ក. ការផ្លាស់ប្តូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជីជំនួសប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ។

៤- បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់ ។

## ប្រការ ១៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ។

## ប្រការ ១៧ : ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី

១- នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឲ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ ។

២- ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ ។

**ប្រការ ១៨ : ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់**

១- ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឲ្យប្រគល់វិញនៅពេលដាក់ពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង ។

២- ដើម្បីទាមទារឲ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ។

៣- ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឲ្យអ្នកទទួលការប្រគល់សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវការណ៍ ដែលខ្លួនបានទទួលការប្រគល់ឯកសារនោះ និងចុះហត្ថលេខា ។

## ជំពូកទី ៥
## ពាក្យសុំចុះបញ្ជី

**ប្រការ ១៩ : ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើមានការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឃ– ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ង– កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២០ ៖ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្តូរ)

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- ឈ្មោះ ឬ អាសយដ្ឋានថ្មី

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្តូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២១ ៖ ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណង

ខ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

គ- ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន

- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិផ្លូលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការកែតម្រូវ
- លិខិតបញ្ជាក់អាសយដ្ឋាន
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២២ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយមូលហេតុរំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ**

១- ប្រសិនបើប្ដីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរំលាយកំជាប់ពាក្យ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទរំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ)

ឯកសារភ្ជាប់:

- ដីកាសម្រេច ដែលរំលាយអាពាហ៍ពិពាហ៍តាមការព្រមព្រៀង
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹងពីការរំលាយកំជាប់ពាក្យ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ប្រការ ២៣ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយមូលហេតុមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១- ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានចុះបញ្ជីរួច ត្រូវបានមោឃៈ រំលាយ ឬ លុបចោល ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមោឃភាព, ការលុបចោល, ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់ថាកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវបានមោឃៈ លុបចោល ឬ រំលាយ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ប្រការ ២៤ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់

១- ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានស្លាប់ សហព័ទ្ធដែលនៅរស់ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលនៅរស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី p

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

ឯកសារភ្ជាប់:

- សំបុត្រមរណភាព
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៥ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ លែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ**

១- ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៦ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**

១- ប្រសិនបើតុលាការសម្រេចសេចក្តី អំពីការបែងចែកទ្រព្យសម្បត្តិ ដោយការលែងលះអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ)

ឯកសារភ្ជាប់:

- ដីកាសម្រេចការបែងចែកទ្រព្យសម្បត្តិដោយការលែងលះអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៧ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ**

១- នៅពេលមានសាលក្រម ឬ សាលដីកាស្ថាពរដែលកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ភាគីណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជី។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៨: ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

១- នៅពេលដែលបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរៀបអាពាហ៍ពិពាហ៍ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បុគ្គលនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឯកសារភ្ជាប់:

- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ជំពូកទី ៦
## ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

### ប្រការ ២៩ : ការទទួលពាក្យសុំចុះបញ្ជី

នៅពេលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះ នូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំព្រួញ និងឈ្មោះមន្ត្រីចុះបញ្ជីនោះ ។

### ប្រការ ៣០ : ការដកពាក្យសុំចុះបញ្ជី

ពាក្យសុំចុះបញ្ជីអាចដកបានមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

### ប្រការ ៣១ : ការពិនិត្យពាក្យសុំចុះបញ្ជី

១- មន្ត្រីចុះបញ្ជី ត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ ។

២- នៅពេលពិនិត្យពាក្យសុំ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន ។

### ប្រការ ៣២ : ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី

១- មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ ដោយមានមូលហេតុ ដូចខាងក្រោម ៖

- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាសនេះ
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី

- ពុំបានបង់សោហ៊ុយ ឬ
- ពាក្យសុំនោះ មិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ផ្សេងទៀត ដែលពាក់ព័ន្ធ។

៦-ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជី ពុំបានកែតម្រូវនៅក្នុងអំឡុងពេលសមរម្យនោះទេ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ។

## ប្រការ ៣៣ : ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ

ក្នុងករណីពាក្យសុំចុះបញ្ជីត្រូវបានដក ឬ លើកចោល មន្ត្រីចុះបញ្ជីត្រូវប្រគល់ឯកសារភ្ជាប់ឲ្យទៅអ្នកដាក់ពាក្យសុំវិញ បើមានការស្នើសុំ ។

## ប្រការ ៣៤ : ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី

១- ការលើកចោលពាក្យសុំរបស់មន្ត្រីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៣២ នៃប្រកាសនេះ អ្នកដាក់ពាក្យសុំចុះបញ្ជីមានសិទ្ធិដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

២- ពាក្យសុំឲ្យពិនិត្យឡើងវិញក្នុងកថាខណ្ឌទី១ ខាងលើនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំនោះ ។

## ប្រការ ៣៥ : ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានដូចខាងក្រោម ៖

- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានរបស់ភាគី
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុនៃការចុះបញ្ជី និងកាលបរិច្ឆេទ
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ប្រការ ៣៦ : អានុភាពនៃការចុះបញ្ជី

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានអានុភាពនៅពេលដែលចុះហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

p

# ជំពូកទី ៧
# របៀបចុះបញ្ជី និងរបៀបរក្សាទុកក្នុងក្រុណ្ឌា

**ប្រការ ៣៧ : របៀបចុះបញ្ជីក្នុងក្រូណ្ឌទទួលពាក្យសុំ**

នៅពេលដែលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំនូវព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី២ ប្រការ ៦ នៃប្រកាសនេះ ។

**ប្រការ ៣៨ : របៀបចុះបញ្ជីក្នុងក្រូណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីមន្ត្រីចុះបញ្ជីបានពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ១៩ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) រួច មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចដូចខាងក្រោមនេះ ៖

- ឈ្មោះ អាសយដ្ឋាន និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ភាគីនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

២- ចំពោះសន្លឹកចុះបញ្ជីនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះលេខចុះបញ្ជីផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយចុះហត្ថលេខាប់ព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៣៩ : របៀបចុះបញ្ជីក្នុងក្រូណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ ដែលបានកំណត់ក្នុងប្រការ ២០ (ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរ គោលបំណងនៃការចុះបញ្ជី មូលហេតុ និងកាលបរិច្ឆេទ ព្រមទាំងខ្លឹមសារនៃកិច្ចសន្យាទាំងអស់ឡើងវិញ នៅក្នុងសន្លឹក **"ផ្លាស់ប្តូរ"** ។

២- ចំពោះការផ្លាស់ប្តូរខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាប់ព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

៤- ចំពោះការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន មន្ត្រីចុះបញ្ជីត្រូវសរសេរឈ្មោះ ឬ អាសយដ្ឋានថ្មី មូលហេតុនៃការផ្លាស់ប្តូរ និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ចូលក្នុងសន្លឹកដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ នៅក្នុងខ្ទង់ពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរឈ្មោះ និង អាសយដ្ឋាន" រួចមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជីនោះ។

## ប្រការ ៤០ : របៀបចុះបញ្ជីក្នុងក្រួណ្ឌចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

បញ្ញត្តិនៃប្រការ ៣៩ (របៀបចុះបញ្ជីក្នុងក្រួណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

## ប្រការ ៤១ : របៀបចុះបញ្ជីក្នុងក្រួណ្ឌចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២២ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ) ប្រការ ២៣ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តប្តីប្រពន្ធ ដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ប្រការ ២៤ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់) ប្រការ ២៥ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ) ប្រការ ២៦ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) និងប្រការ ២៧ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពីគោលបំណង មូលហេតុ និងកាលបរិច្ឆេទ នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រង់ខ្ទង់ "ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ។

២- ចំពោះសន្លឹកចុះបញ្ជីក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំពេញដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រួណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

## ប្រការ ៤២ : របៀបចុះបញ្ជីក្នុងក្រួណ្ឌចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២៨ (ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពី

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍នៅខ្ទង់ "កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍" នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ៤៣ : វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ពាក់ព័ន្ធនឹងការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅត្រង់ខ្ទង់ "ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឬ ខ្ទង់ "ការផ្លាស់ប្តូរទ្រព្យសម្បត្តិប្តីប្រពន្ធ" មន្ត្រីចុះបញ្ជីក៏អាចចុះថា **"ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ"** រួចភ្ជាប់នូវលិខិតថតចម្លងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះជាមួយគ្នាក្នុងសន្លឹកចុះបញ្ជីនៃក្រុណាបាន។ ក្នុងករណីនេះមន្ត្រីចុះបញ្ជីត្រូវកត់ត្រានូវលេខចុះបញ្ជី និង លេខទទួល នៅក្នុងលិខិតថតចម្លងនៃកិច្ចសន្យា ដែលបានភ្ជាប់មកជាមួយនោះ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំពេញដើម្បីបញ្ជាក់ថា "បានពិនិត្យរួច" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច។

២- ក្រោយពេលពិនិត្យ និងសម្រេចរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងចុះហត្ថលេខា និងប្រថាប់ត្រានៅគ្រប់សន្លឹកនៃលិខិតថតចម្លងដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៤៤ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះហត្ថលេខា និងប្រថាប់ត្រារួច មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំចុះបញ្ជី និង ឯកសារភ្ជាប់ក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ ទៅតាមលំដាប់លេខរៀង និងកាលបរិច្ឆេទទទួលពាក្យសុំ ។

**ប្រការ ៤៥ : របៀបចងក្រងរក្សាទុកក្នុងក្រូណូលើកចោល**

នៅពេលដែលមន្ត្រីចុះបញ្ជី បានលើកចោលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកលិខិតលើកចោលក្នុងក្រូណូលើកចោល ទៅតាមលំដាប់លេខលិខិតលើកចោល និងកាលបរិច្ឆេទ ។

**ប្រការ ៤៦ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក្យសុំឲ្យពិនិត្យឡើងវិញ និងឯកសារភ្ជាប់ ក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅតាមលំដាប់លេខពាក្យសុំឲ្យពិនិត្យឡើងវិញ និងកាលបរិច្ឆេទ ។

p

**ប្រការ ៤៧ : របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

រាល់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្រ្តីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំនោះ នៅក្នុងក្រ្កណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ទៅតាមលំដាប់លេខនៃការទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី និងកាលបរិច្ឆេទ ។

## ជំពូកទី ៨
## នីតិវិធីនៃការចេញលិខិតបញ្ជាក់

**ប្រការ ៤៨ : របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់**

១- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

២- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ។

៣- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ ។

៤- អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤៩ : ការចេញលិខិតបញ្ជាក់**

១- នៅពេលបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ មន្រ្តីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅឲ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅលើឯកសារថតចម្លងថា ៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី..........ខែ.........ឆ្នាំ.........)
- ហត្ថលេខាបំព្រួញរបស់មន្រ្តីចុះបញ្ជី និង ហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌។ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ក៏អាចឲ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

២- ក្រោយពីបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឲ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឲ្យលើសពីរយៈពេល ៣ ថ្ងៃ ។

# ជំពូកទី ៩

# អវសានប្បញ្ញត្តិ

**ប្រការ ៥០ : កាលបរិច្ឆេទ នៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែបានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

ថ្ងៃទី ០៩.....ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍានៈ

p

# ឧបសម្ព័ន្ធទី ២
# ទម្រង់លិខិតរដ្ឋបាល
# ពាក់ព័ន្ធនឹងការលែងលះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ~~ខេត្ត~~ (១) ----- *ភ្នំពេញ* -----
~~ក្រុង ស្រុក~~ ខណ្ឌ (២) ----- *ជ្រោយចង្វារ* -----
~~ឃុំ~~ សង្កាត់ (៣) ----- *បាក់ខែង* ------

លេខ (៤)------- *០៩*-------------------------
សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-*០១/២០១៥*
ឆ្នាំ (៦)-------- *២០១៥* ----------------------

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៨) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (១០) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៨) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២១) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២២) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២៣) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៥) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**

***ចៅសង្កាត់***

(២៧) *ហត្ថលេខា និងត្រា*

*ផៃ សុនី*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

# កិច្ចព្រមព្រៀងលែងលះ

ខ្ញុំបាទឈ្មោះ ភេទ ប្រុស ឆ្នាំកំណើត 1980 ជនជាតិខ្មែរ-ឥណ្ឌូង មុខរបរៈ អាជីវករ

និង នាងខ្ញុំឈ្មោះ ភេទ ស្រី ឆ្នាំកំណើត 1983 ជនជាតិខ្មែរ មុខរបរៈ មេផ្ទះ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខៈ 102 E6 ផ្លូវលេខៈ 21 សង្កាត់ៈ ទន្លេបាសាក់ ខណ្ឌៈ ចំការមន រាជធានីភ្នំពេញ ។

សូមធ្វើកិច្ចព្រមព្រៀងលែងលះគ្នាដូចខាងក្រោម ៖

ខ្ញុំបាទឈ្មោះ ត្រូវជាប្ដី និង នាងខ្ញុំឈ្មោះ ត្រូវជាប្រពន្ធ បានចាប់រៀបការជាគ្រួសារអស់រយៈ ចំនួន 10 ឆ្នាំមកហើយ ពុំដែលបានចុះសម្រុងគ្នាក្នុងនាមជាប្ដីប្រពន្ធឡើយ តែងតែមានទំនាស់ជាមួយគ្នាជាប្រចាំ ទោះបីជាមានការសម្រុះសម្រួលពីឪពុក ម្ដាយ បងប្អូន ញាតិមិត្តក៏ដោយ ក៏នៅតែមិនឯកភាព និងចុះសម្រុងជាមួយគ្នាឡើយ ។ ដូច្នេះ ដើម្បីបញ្ចប់នូវភាពរ៉ាំរ៉ៃក្នុងគ្រួសារជាបន្តទៀត ទើបយើងខ្ញុំទាំងពីរនាក់ បានព្រមព្រៀងឯកភាពចែកផ្លូវគ្នា ដោយបញ្ឈប់ការទទួលស្គាល់គ្នាជាប្ដី និងប្រពន្ធ បន្តទៀត ចាប់ពីថ្ងៃធ្វើកិច្ចសន្យានេះតទៅ ហើយការព្រមព្រៀងនេះ គឺធ្វើឡើងដោយស្ម័គ្រចិត្ត ដោយគ្មានការគំរាមកំហែង គៀបសង្កត់ ឬបង្ខិតបង្ខំពីភាគីណាមួយឡើយ ។

ចំពោះកូនចំនួន 02 នាក់ គឺ:

1. ឈ្មោះ ភេទប្រុស អាយុ 09 ឆ្នាំ
2. ឈ្មោះ ភេទស្រី អាយុ 0.. ឆ្នាំ

បានឯកភាពគ្នាឱ្យកូនឈ្មោះ នៅឈ្មោះ ជាឪពុក ជាអ្នកមានសិទ្ធិថែរក្សា

និងកូនឈ្មោះ នៅឈ្មោះ ជាម្ដាយ ជាអ្នកមានសិទ្ធិថែរក្សា ។ ហើយ ក៏បានឯកភាពគ្នាថា នឹងមិនមានឃាត់ភាគីម្ខាងណាក្នុងការសុំជួបកូនឡើយ ។

ចំពោះ ~~ការបែងចែក~~ ទ្រព្យសម្បត្តិ ភាគីទាំងសងខាងព្រមព្រៀងឯកភាពគ្នាបែងចែកផ្ទះដែលកំពុង

រស់នៅសព្វថ្ងៃឱ្យទៅឈ្មោះ ប្រពន្ធ និង ប្រាក់ប្រមាណ ឡាន ម៉ាក ពាក់ស្លាកលេខ

ឱ្យទៅ ជាប្ដី ។

ពីស្អែកនេះទៅថ្ងៃក្រោយ ខ្ញុំនឹងសាងខ្លួនទៅរៀនរកភាពការណ៍ពិតថ្មីទៀត ខ្ញុំនឹងទាំងអស់ ខាងកុំមាន
ខាងទា ស្អុតរំរីទីតាំងទៅវិញ ទៅឯអង្គការ ។

ក្នុងការណ៍នេះ ខ្ញុំសុំអង្គការមិនពោធាសាងកិច្ចសន្យានេះ នឹងទទួលខុសត្រូវទាំងស្រុងនៅចំពោះមុខ
រាល់ដាងនោះ ។

ចំពោះទំព័រប្រាកដ ឃើញខ្ញុំតាំងពីនាក់ ស្នាមផ្តិតមេដៃស្តាំទុកជាភស្តុតាងច្បាស់ ។

ធ្វើនៅថ្ងៃទី ខែ ឆ្នាំ

សាក្សីនឹងពួក



ស្នាមមេដៃស្តាំសាមីខ្លួន





គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

## ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

**ដើមចោទ** ៖ ឈ្មោះ..................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ..................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...........................................................។

**សូមគោរពជូនមក**
**ឯកឧត្តមប្រធានសាលាដំបូង..........................**

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.........................................................................................................

.........................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.........................................................................................................

.........................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

.........................................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

.........................................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។

- ..........................................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់............................ តាមលិខិតលេខ............ ចុះថ្ងៃទី.................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្ដីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្ដីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្ដាំចុងចម្លើយ
(ស្នាមមេដៃស្ដាំ)

..................

ស្នាមមេដៃស្ដាំដើមចោទ
(ស្នាមមេដៃស្ដាំ)

.....................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ
ពាក្យសុំលែងលះ
គ្មានការព្រមព្រៀង

## ពាក្យបណ្ដឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ............... មានទីលំនៅបច្ចុប្បន្ន...........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ............... មានទីលំនៅបច្ចុប្បន្ន...........................................................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូង**.........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្ដាច់សបត្តសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.............................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.............................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.........................។

- ...........................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បានចងអាពាហ៍ពិពាហ៍ ជាឈ្មោះ......................... ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ: (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) ......................................................................................................................................។

អាស្រ័យហេតុនេះ: សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្ដឹងសុំខាងលើដោយក្ដីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្ដាំចុងចម្លើយ
(ស្នាមមេដៃស្ដាំ)

ស្នាមមេដៃស្ដាំដើមចោទ
(ស្នាមមេដៃស្ដាំ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ [illegible]
ថ្ងៃទី 08 ខែ 11 ឆ្នាំ 2016

## ពាក្យបណ្តឹង

**ដើមបណ្តឹង:** ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

**ចុងចម្លើយ:** ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិរកាកោង ឃុំរកាកោង២ស្រុកមុខកំពូល ខេត្តកណ្តាល ។

**សូមគោរពជូន**

**លោកប្រធាន សាលាដំបូងខេត្តកណ្តាល**

*សូមទានជ្រាប !*

**កម្មវត្ថុ:** សំណើសុំឱ្យតុលាការចេញសាលក្រមដោយវិនិច្ឆ័យសេចក្តីដូចខាងក្រោម:

១- សុំលែងលះពីប្រពន្ធឈ្មោះ ។

២- សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

៣- សុំសិទ្ធិគ្រប់គ្រងរថយន្តម៉ាក Hilander ពណ៌ទឹកមាស សេរីឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង ។

៤- ផ្ទះលេខ WC សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រគល់ឱ្យកូនឈ្មោះ និងកូនឈ្មោះ ។

៥- ប្រគល់:

-ផ្ទះល្វែងនៅផ្សាររកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល

-ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល

-ដីទំហំ ២៥ម៉ែត្រ គុណ ១៧០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្តាល

-រថយន្តម៉ាក Lexus RX ៣០០ ពណ៌ស សេរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង

-រថយន្តម៉ាក Visto ពណ៌ស ចំនួន០១គ្រឿង

-គ្រឿងអលង្ការ មួយចំនួនកំពុងលក់ដូរ

-កូនប្រុសឈ្មោះ អាយុ ឆ្នាំ ឱ្យទៅប្រពន្ធឈ្មោះ មានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាប **លោកប្រធាន** មេត្តាជ្រាបថា៖ ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ បន្ទាប់ពីខ្ញុំបាទ និងប្រពន្ធឈ្មោះ ចាប់ដៃគ្នាជាប្តីប្រពន្ធមកគឺពួកយើងខ្ញុំមានកូនប្រុសចំនួន ០២នាក់ គឺឈ្មោះ អាយុ ឆ្នាំ និងឈ្មោះ អាយុ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត ។ ប៉ុន្តែដោយហេតុថា ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទ និងប្រពន្ធបានរស់នៅបែកគ្នាអស់រយៈពេល ៥-៦ឆ្នាំមកហើយ ជាក់ស្តែងខ្ញុំបាទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀតហើយ ហេតុដូច្នេះ ខ្ញុំបាទប្តឹងសុំឱ្យតុលាការចេញសាលក្រមដោយវិនិច្ឆ័យសេចក្តីដូចខាងក្រោម:

១- សុំលែងលះពីប្រពន្ធឈ្មោះ ។

២- សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

៣- សុំសិទ្ធិគ្រប់គ្រងលើរថយន្តម៉ាក Hilander ពណ៌ទឹកមាស សេរីឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង ។

៤- ផ្ទះលេខ WC សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រគល់ឱ្យកូនឈ្មោះ និងកូនឈ្មោះ ។

៥- ប្រគល់:

-ផ្ទះល្វែងនៅផ្សាររកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល

-ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល

-ដីទំហំ ២៥ម៉ែត្រ គុណ ១៤០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្ដាល

-រថយន្តម៉ាក Lexus RX ៣០០ ពណ៌ស សេរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង

-រថយន្តម៉ាក Visto ពណ៌ស ចំនួន០១គ្រឿង

-គ្រឿងអលង្ការ មួយចំនួនកំពុងលក់ដូរ

-កូនប្រុសឈ្មោះ អាយុ ឆ្នាំ ឱ្យទៅប្រពន្ធឈ្មោះ មានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា

អាស្រ័យសេចក្ដីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ ទទួល និងសម្រេចតាមពាក្យបណ្ដឹងរបស់ខ្ញុំបាទ ដូចមានចែងក្នុងកម្មវត្ថុខាងលើ ដោយក្ដីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦

**ស្នាមមេដៃស្ដាំ**



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ 1076

ថ្ងៃទី ០៤ ខែ 11 ឆ្នាំ 2016

## ពាក្យបណ្ដឹង

**ដើមបណ្ដឹង:** ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

**ចុងចម្លើយ:** ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិរកាកោង ឃុំរកាកោង២ស្រុកមុខកំពូល ខេត្តកណ្ដាល ។

## សូមគោរពជូន

## លោកប្រធាន សាលាដំបូងខេត្តកណ្ដាល

*សូមទានជ្រាប !*

**កម្មវត្ថុ:** សំណើសុំឱ្យតុលាការចេញសាលក្រមដោយវិនិច្ឆ័យសេចក្ដីដូចខាងក្រោម:

១- សុំលែងលះពីប្រពន្ធឈ្មោះ ។

២- សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

៣- សុំសិទ្ធិគ្រប់គ្រងរថយន្តម៉ាក Hilander ពណ៌ទឹកមាស សេរីឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង ។

៤- ផ្ទះលេខ WC សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រគល់ឱ្យកូនឈ្មោះ និងកូនឈ្មោះ ។

៥- ប្រគល់:

- ផ្ទះល្វែងនៅផ្សាររកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល
- ដីនៅភូមិចុងព្រែក ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល
- ដីទំហំ ២៥ម៉ែត្រ គុណ ១៩០ម៉ែត្រ នៅស្រុកមុខកំពូល ខេត្តកណ្ដាល
- រថយន្តម៉ាក Lexus RX ៣០០ ពណ៌ស សេរីឆ្នាំ១៩៩៩ ផ្លាកលេខ ភ្នំពេញ ចំនួន០១គ្រឿង
- រថយន្តម៉ាក Visto ពណ៌ស ចំនួន០១គ្រឿង
- គ្រឿងអលង្ការ មួយចំនួនកំពុងលក់ដូរ
- កូនប្រុសឈ្មោះ អាយុ ឆ្នាំ ឱ្យទៅប្រពន្ធឈ្មោះ មានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាប **លោកប្រធាន** មេត្តាជ្រាបថា៖ ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ បន្ទាប់ពីខ្ញុំបាទ និងប្រពន្ធឈ្មោះ ចាប់ដៃគ្នាជាប្ដីប្រពន្ធមកគឺពួកយើងខ្ញុំមានកូនប្រុសចំនួន ០២នាក់ គឺឈ្មោះ អាយុ ឆ្នាំ និងឈ្មោះ អាយុ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត ។ <u>ប៉ុន្តែដោយហេតុថា</u> ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទ និងប្រពន្ធបានរស់នៅបែកគ្នាអស់រយៈពេល ៥-៦ឆ្នាំមកហើយ ជាក់ស្ដែងខ្ញុំបាទអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀតហើយ ហេតុដូច្នេះ ខ្ញុំបាទប្ដឹងសុំឱ្យតុលាការចេញសាលក្រមដោយវិនិច្ឆ័យសេចក្ដីដូចខាងក្រោម:

១- សុំលែងលះពីប្រពន្ធឈ្មោះ ។

២- សុំសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាលើកូនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ។

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំដីកាសម្រេចលែងលះ

**-អ្នកដាក់ពាក្យសុំ**ឈ្មោះ ភេទស្រី កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៨៣សញ្ជាតិខ្មែរ មុខរបរកម្មការនីរោងចក្រ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។(០៧១.៥១៧.៨០០៥, ០៩៧.៤១៥១.៣៩៤)

**-ភាគីម្ខាងទៀត**ឈ្មោះ ភេទ ប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៨៧ សញ្ជាតិខ្មែរ មុខរបរយោធារោងចក្រ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។(០៣១.៤៤៤៤៣៤៨)។

## សូមគោរពចូល
## ឯកឧត្តម ប្រធានសាលាដំបូង ខេត្តកណ្តាល

**កម្មវត្ថុ:** សុំឲ្យតុលាការចេញដីកាសម្រេចដែលមានខ្លឹមសារដូចខាងក្រោម៖

១-សុំលែងលះតាមការព្រមព្រៀង

២-ភាគីអ្នកដាក់ពាក្យសុំៗសិទ្ធិគ្រប់គ្រងកូនចំនួន០៣នាក់,កូនទី១-ឈ្មោះ ភេទស្រីកើតថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៣,កូនទី២ ឈ្មោះ ភេទស្រី កើតថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៧ ,កូនទី៣ឈ្មោះ ភេទ ប្រុស កើតថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៩។

៣-ភាគីអ្នកដាក់ពាក្យសុំឈ្មោះ សុំសិទ្ធិគ្រប់គ្រងដីតាមកិច្ចសន្យាលក់ដី-ផ្តាច់លេខ១០៨៦/១៦សកពចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៦ មានទីតាំងស្ថិតនៅភូមិព្រែករាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

**៤**-ភាគីម្ខាងទៀតឈ្មោះ**សរ វាសនា សុំសិទ្ធិគ្រប់គ្រងផ្ទះ**ថ្មទំហំ ៤,២ម X១២ម មានទីតាំងស្ថិតនៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល,ម៉ូតូមួយគ្រឿងម៉ាកហុងដាC-125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ប.មានជ័យ 1P-8280 ឈ្មោះ សរ វាសនា សុំសិទ្ធិគ្រប់គ្រង។

៥-ប្រាក់ពន្ធនិងប្រាក់ប្រាដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ

**ឯកសារជាភស្តុតាង**៖-សំបុត្រអាពាហ៍ពិពាហ៍លេខ៖១១សៀវភៅអាពិពាហ៍លេខ០១/២០១៨ ចុះថ្ងៃទី១២ ខែ មេសសសា ឆ្នាំឈ២០១៨ ។

**ហេតុចាំបាច់នៃការទាមទារ**

កាលពីថ្ងៃទី១១ខែមីនាឆ្នាំ២០១១យើងខ្ញុំបានរៀបការជាមួយគ្នានិងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ តាមសបុត្រអាពាហ៍ពិពាហ៍លេខ ១១ ចុះថ្ងៃទី១២ ខែ មេសា ឆ្នាំ២០១៨ ចេញដោយអគ្រានុកូលដ្ឋានឃុំព្នៅទី១ ។ក្នុងការរួមរស់ជាមួយគ្នាបានកូនចំនួន០៣នាក់ កូនទី១-ឈ្មោះ វាសនា សុវណ្ណីអេលីណា ភេទស្រីកើតថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៣,កូនទី២ ឈ្មោះ វាសនា សុវណ្ណនីសា ភេទស្រី កើតថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៧ ,កូនទី៣ឈ្មោះ វាសនា សុវណ្ណធិរាជភេទ ប្រុស កើតថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៩ និងមានទ្រព្យសម្បត្តិរួមមាន៖ ផ្ទះថ្មទំហំ ៤,២ម X១២ម មានទីតាំងស្ថិតនៅភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល,ម៉ូតូមួយគ្រឿងម៉ាកហុងដាពណ៍ខ្មៅ ពាក់ស្លាកលេខប.មានជ័យ 1P-8280, ដីតាមកិច្ចសន្យាលក់ដី-ផ្ដាច់លេខ១០៨៦/១៦សកពមានទីតាំងស្ថិតនៅភូមិព្រែកវាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

នៅអំឡុងខែ៥ ឆ្នាំ២០២០ ប្ដីទាក់ទងមានស្រីខាងក្រៅ មិនគិតគូប្រពន្ធកូនហើយមានទំនាស់គ្នារហូត និងបានប្រើអំពើហិង្សាជាញឹកញាប់មកលើនាងខ្ញុំ ដែលជាហេតុនាំឲ្យអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុនិងអង្គហេតុខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាជួយចេញដីកាសម្រេចតាមការស្នើសុំរបស់យើងខ្ញុំទាំងពីរនាក់ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពអំពីយើងខ្ញុំ។

ថ្ងៃ.....................កើតខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ថ្ងៃទី..........ខែតុលាឆ្នាំ២០២១

**ស្នាមមេដៃស្ដាំ**

**ភាគីម្ខាងទៀត** **អ្នកដាក់ពាក្យសុំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

17/3

ក្រុមហ៊ុនមេធាវី ខ្មែរអប្សរា
KHMER APSARA LAW FIRM
លេខ..............កមខអ/១៩

| សាលាដំបូងខេត្តកណ្ដាល | |
|---|---|
| ចូល | លេខ: 198<br>ថ្ងៃទី 28 ខែ 01 ឆ្នាំ20.19<br>ម៉ោង 3 និង 02 នាទី |

## ពាក្យសុំតំណាងដោយអាណត្តិ

ខ្ញុំបាទមេធាវី អត្តលេខ: និងលោកមេធាវី អត្តលេខ: ជាសមាជិកមេធាវីនៃ ក្រុមហ៊ុនមេធាវី ខ្មែរអប្សរា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

ទូរស័ព្ទទំនាក់ទំនងលេខ: /

សូមគោរពជូន
លោក ប្រធានសាលាដំបូងខេត្តកណ្ដាល

*សូមមានជ្រាប។*

**កម្មវត្ថុ:** ស្ដីពីមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

2801 19

**យោង:**
- ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា: ឈ្មោះ បានប្រគល់សិទ្ធិឲ្យយើងខ្ញុំ ធ្វើជាមេធាវីតំណាងដោយអាណត្តិ និងមានសិទ្ធិអំណាចធ្វើកិច្ចការអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាទទួលស្គាល់យើងខ្ញុំជាមេធាវីតំណាងនៅក្នុងរឿងរដ្ឋប្បវេណីខាងលើនេះទៅតាមនីតិវិធីច្បាប់ ដោយក្ដីអនុគ្រោះ។

*ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី. មេធាវី.

អាស័យដ្ឋាន: ផ្ទះលេខ ៥A, ផ្លូវលេខ ២៨៥, សង្កាត់បឹងកក់១, ខណ្ឌទួលគោក, រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០៩៩ ៧១៦ ៦៧១ / ០១៦ ៧១៦ ៦៧១ Email: pich_sorya@yahoo.com / web: apsaralaw.com

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

នាងខ្ញុំឈ្មោះ អាយុ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី **ពេជ្រ សូរិយា** អត្តលេខ: ៥១៣ លោកមេធាវី **គីម សម្បត្តិ** អត្តលេខ: ១២៣៣ ជាសមាជិកមេធាវីនៃ **ក្រុមហ៊ុនមេធាវី ខ្មែរអរប្បរា** ដែលមានការិយាល័យផ្ទះលេខ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិ និងធ្វើកិច្ចការដោយអាណត្តិឱ្យនាងខ្ញុំនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល។

<u>**បញ្ជាក់:**</u> រាល់ការចំណាយលើការបង់ពន្ធ ឬការចំណាយផ្សេងៗពាក់ព័ន្ធទៅនឹងរឿងក្ដីជាបន្ទុករបស់នាងខ្ញុំជាអាណត្តិទាយក។ ក្នុងករណីមិនបានគោរពកាតព្វកិច្ចនេះ នាងខ្ញុំសុខចិត្តទទួលខុសត្រូវនូវរាល់ការខាតបង់ផលប្រយោជន៍នានាដោយខ្លួនឯង។

លោក **មេធាវី** ដែលបានទទួលសិទ្ធិធ្វើជាមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអំណាចធ្វើជំនួសនូវរាល់បណ្ដឹងដែលពាក់ព័ន្ធក្នុងរឿងក្ដី និងធ្វើនូវរាល់សកម្មភាពដែលស្របទៅនឹងស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីចាប់ពីថ្ងៃដែលនាងខ្ញុំផ្ដិតមេដៃនេះតទៅ។

*ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*

**ស្នាមមេដៃស្ដាំ**

**បានឃើញ និង យល់ព្រម**

*ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.

មេធាវី.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបន្ទាយមានជ័យ
លេខ...៣៣២៨......
ថ្ងៃ...១៥...ខែ...១១...ឆ្នាំ...១៨...
ម៉ោង...៤:០០.........

**ពាក្យសុំឲ្យកោះហៅសាក្សី**

ខ្ញុំបាទឈ្មោះ អាយុ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាចុងចំលើយ ( )

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ**

__កម្មវត្ថុ__ សំណើសុំកោះហៅសាក្សីឲ្យចូលមកឆ្លើយបំភ្លឺក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៨ព្រឹក។

__យោង__ .សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៦.១១.២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

តាមកម្មវត្ថុ និង យោងខាងលើនេះ ខ្ញុំបាទ សូមគោរពជំរាបជូន **លោកប្រធាន**មេត្តាជ្រាបថា ៖ ខ្ញុំបាទត្រូវបានប្រពន្ធឈ្មោះ ប្ដឹងសុំលែងលះពីខ្ញុំបាទ។ ព័ន្ធរឿងក្ដីនេះ មានការវិវាទក្នុងរឿងទ្រព្យសម្បត្តិ ខ្ញុំសូមបញ្ជាក់ថា ចំពោះទ្រព្យសម្បត្តិមានដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងដែលប្រពន្ធទាមទារថាជាទ្រព្យរួមនោះ គឺមិនត្រឹមត្រូវទេ។ ដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងជាទ្រព្យសម្បត្តិដោយឡែករបស់ខ្ញុំបាទ គឺ៖

១.ដី និងផ្ទះនៅលើដី ជារបស់ឪពុកម្ដាយខ្ញុំបាទ ចែកឲ្យក្រោយពេលរៀបការ។

២.ម៉ូតូ១គ្រឿង គឺជាម៉ូតូដែលប្អូនខ្ញុំបាទឈ្មោះ ឲ្យខ្ញុំបាទខ្ចីជិះទៅធ្វើការ មានសាក្សីដឹងលឺ ៖

.ឈ្មោះ ភេទស្រី អាយុ ឆ្នាំ នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាម្ដាយខ្ញុំបាទ។

.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ នៅភូមិស្ទឹង សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ខ្ញុំបាទមានសំណូមពរ សុំឲ្យតុលាការកោះអញ្ជើញសាក្សី ដើម្បីបំភ្លឺការពិតជូនតុលាការពេលសវនាការ។

អាស្រ័យដូចបានគោរពជូនខាងលើនេះសូម **ប្រធាន** មេត្តាសំរេច តាមសំណូមពរ ខ្ញុំបាទ ដោយក្ដីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅថ្ងៃទី ១៥ ខែវិច្ឆកា ឆ្នាំ២០១៨

ស្នាមមេដៃស្តាំ

បញ្ជូនទៅ...[illegible]...
ដើម្បីចាត់ការតាមនីតិវិធីច្បាប់
បន្ទាយមានជ័យ, ថ្ងៃទី...15...ខែ...11...ឆ្នាំ...2018
ប្រធានសាលាដំបូង

ក្រឡាបញ្ជី សក សក្តសម

24/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## ដីកាកោះ

សំណុំរឿងរដ្ឋប្បវេណី

| | |
|---|---|
| បង្គាប់មកឈ្មោះ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ។<br>អាសយដ្ឋានបច្ចុប្បន្ន៖ ភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ | |
| សញ្ញាណនៃរឿងក្តី(លេខនិងភាគី) ផែ្សងៗ | សំណុំរឿងក្តីលេខ ២៣២ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩<br>-ដើមចោទឈ្មោះ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ<br>-ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក<br>តុលាការសាលាឧទ្ធរណ៍ សាលសវនាការបន្ទប់ទី ៣ |
| ប្រភេទដំណាក់កាលនៃនីតិវិធី | នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ | |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបាន បង្ហាញខ្លួន ដោយគ្មានមូលហេតុ ត្រឹមត្រូវ | ១-ចំពោះសាមីភាគី : បើពុំចូលខ្លួន នោះតុលាការទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៤០ កថាខ័ណ្ឌទី២, មាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>២-ចំពោះសាក្សី : បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ រៀល (មួយលានរៀល)។ តាមមាត្រា១៣២ កថាខ័ណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលបានកំណត់ខាងលើនេះ ។<br>ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣<br>សាលាឧទ្ធរណ៍ ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៩<br>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ<br>យុន ណាទម៉េង | |

បញ្ជាក់៖ -ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួន សូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក
-ទម្រង់នេះប្រើសម្រាប់ ភាគី, សាក្សី, អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង
-អាសយដ្ឋានសាលាឧទ្ធរណ៍ : ផ្លូវតិរៈ វិថីព្រះស៊ីសុវត្ថិ សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

24/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## របាយការណ៍អំពីការបញ្ជូន

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី :

-កាលបរិច្ឆេទផ្ញើចេញ៖ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៩
សំណុំរឿងលេខ : ២៣២ ចុះថ្ងៃទី ០២-៨-២០១៩
ឈ្មោះឯកសារផ្ញើចេញ៖ ដីកាកោះ ចុះថ្ងៃទី ២២-៨-១៩ (ទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៣-៩-១៩ ម៉ោង ៨:០០ នាទីព្រឹក បន្ទប់៣)
ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សក ស័ក្តិសម (ក្រឡាបញ្ជី)
អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សាលាឧទ្ធរណ៍
ឈ្មោះជនដែលត្រូវទទួលឯកសារបញ្ជូនទៅ : ដើមចោទឈ្មោះ

-ហត្ថលេខាឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង ..........



-ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន(កត្តាប្រៃសណីយ៍ ឬអាជ្ញាសាលា ឬក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងធ្វើការបញ្ជូនទៅ : | |
| កាលបរិច្ឆេទនៃការបញ្ជូន : | |
| **វិធីដាក់ស្តែងក្នុងការបញ្ជូន** | |
| □ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។ |
| | □ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ ។ |
| □ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ ។ |
| | □អ្នកបំរើ □អ្នកផ្សេងដែលនៅធ្វើការនៅទីនោះ □អ្នកនៅជាមួយ |
| | ឈ្មោះ.......... |
| □ ៣ | ឯកសារត្រូវបានទុកនៅទីកន្លែងធ្វើការបញ្ជូន ដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | □ជនដែលត្រូវទទួលការបញ្ជូន □អ្នកបំរើ □អ្នកនៅជាមួយ □អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ .......... |
| □ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | |
| □ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ នេះទេ ។ | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០១៩ | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍:..........សាន សឿន.......... | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ: ១០ "ប" រ.វ

# ដីកាសម្រេច
## បង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

យើង ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** មាត្រា **៦២** កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ: **១៧៥** ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ឈ្មោះ

**រវាង** ដើមចោទឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៧៦ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៦៦អឺ០ ផ្លូវ ២៧៦ ភូមិ៩ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**និង** សហចុងចម្លើយឈ្មោះ កើតឆ្នាំ១៩៨២ និងឈ្មោះ កើតឆ្នាំ ១៩៨៥ មានទីលំ នៅបច្ចុប្បន្ននៅផ្ទះលេខ MH១៦៨ ផ្លូវបេតុង ភូមិស្មោរកើត សង្កាត់ស្មោរ ខណ្ឌកំបូល រាជធានីភ្នំពេញ។

**ដែលមានកម្មវត្ថុនៃបណ្តឹងស្នើសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ:**

១-បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ចំនួន **១០,២០០ (មួយម៉ឺនពីររយ)** ដុល្លារអាមេរិក និងការប្រាក់យឺតយ៉ាវចំនួន **៥%** (ប្រាំ) ភាគរយ ក្នុងមួយខែ គិតចាប់ពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចទៅឱ្យដើមចោទ។

២-បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់សំណងខូចខាត សោហ៊ុយចំណាយ និងការខាតបង់ពេលវេលាជាប្រាក់ចំនួន **៥,០០០ (ប្រាំពាន់)** ដុល្លារអាមរិក មកឱ្យទៅដើមចោទ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៤-សុំសាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន។

## **សំអាងហេតុ**

ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ជាទឹកប្រាក់ចាំបាច់សម្រាប់តុលាការដំណើរការនីតិវិធីនៃបណ្ដឹង ហើយប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនេះ ជាបន្ទុករបស់ភាគីដែលត្រូវបង់តម្កល់ទុកជាបណ្ដោះអាសន្ននៅតុលាការ ដើម្បីឱ្យតុលាការអាចដំណើរការនីតិវិធីបណ្ដឹងតាមច្បាប់បាន គប្បីសម្រេចឱ្យឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ តាមមាត្រា **៦២** កថាខណ្ឌទី៣ និងមាត្រា **៨២** នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

## **ហេតុដូច្នេះសម្រេច**

**១**-បង្គាប់ឱ្យដើមចោទឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៦៦អឺ០ ផ្លូវ ២៧៦ ភូមិ៤ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធចំនួន**១០០,០០០ (មួយសែន)** រៀល ក្នុងរយៈពេល **០២ (ពីរ)** សប្ដាហ៍ គិតចាប់ពីថ្ងៃទទួលដំណឹង។

**២**-ក្នុងករណីដែលដើមចោទ មិនបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធខាងលើ តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ។

ថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ចៅក្រមអក្សរ (ប)

# បង្កាន់ដៃទទួលប្រាក់

យើង ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ។

បានទទួលប្រាក់ពីឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៦៦អឺ០ ផ្លូវ២៧៦ ភូមិ៤ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ចំនួន**១00,000 (មួយសែន)** រៀល ជាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: **១៧៥** ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

ថ្ងៃ............................... ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី........... ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត
បន្ទាយមានជ័យ

សំណុំរឿងរដ្ឋប្បវេណី

លេខ:

ចុះថ្ងៃទី ០៦-១១-២០១៨

## កំណត់ហេតុស្តីពីនីតិវិធីត្រៀមតាញហេតុផល

( មាត្រា ១១០ និង មាត្រា ១១១ )

### សញ្ញាណនៃរឿងក្តី

សំណុំរឿងរដ្ឋប្បវេណីលេខ ៦៨៦ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

លោក **ជួន វណ្ណៈ** ចៅក្រម

លោក **ឡៀម ដាណា** ក្រឡាបញ្ជី

- កាលបរិច្ឆេទ: ១៤-១១-២០១៨ វេលាម៉ោង ៨ ព្រឹក

### គូភាគីដែលបានបង្ហាញខ្លួន

-ដើមចោទលោកស្រី ភេទស្រី ថ្ងៃខែឆ្នាំកំណើត៣០-១២-១៩៩៥ មុខរបរកម្មករកាត់ដេរ ទីលំនៅបច្ចុប្បន្នភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយលោក ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ មុខរបរកម្មករកាត់ដេរ ទីលំនៅបច្ចុប្បន្នភូមិ ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

អង្គហេតុដែលជាមូលហេតុនៃការទាមទារអោយតុលាការចេញសាលក្រម

១-ខ្លឹមសារដែលដើមចោទទាមទារអោយតុលាការចេញ :-

-សុំលែងលះពីចុងចម្លើយឈ្មោះ ។

-សុំអំណាចមេបាលើកូន ០១ នាក់

-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរ ។

-សុំអាហារកិច្ចផ្គត់ផ្គង់ចំនួន ៥០០០ ដុល្លា ។

-សុំរ៉ាប់រងពន្ធ។

២-ខ្លឹមសារដែលចុងចម្លើយទាមទារអោយតុលាការចេញ :- លែងលះ , ចែកទ្រព្យសម្បត្តិរួម។

ដំណាក់កាលផ្សះផ្សា

-ដើមចោទ និង ចុងចម្លើយព្រមសះជាគ្នា

សេចក្តីថ្លែងការណ៍របស់ដើមចោទ : នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ២០១៥ ព្រមទាំងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ការរួមរស់ជាមួយចុងចម្លើយមានកូនម្នាក់ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ២០-១២-២០១៥ កូនប្រុសម្នាក់នេះនាងខ្ញុំសុំអំណាចមេបា។ ចំពោះទ្រព្យសម្បត្តិរួមមានដី និង ផ្ទះសង់ពីលើដីទំហំ ១៥ ម៉ែត្រ គុណ ៥០ ម៉ែត្រ ខាងជើងទល់ផ្លូវ , ខាងត្បូងជាប់ព្រំដី ខាងលិចជាប់ព្រំដី , ខាងកើតជាប់ព្រំដីឈ្មោះ ស្ថិតនៅភូមិ ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ , ម៉ូតូមួយគ្រឿងម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ស្លាកលេខ បជ នាងខ្ញុំសុំចែកជាពីរចំណែកស្មើគ្នា ហើយសុំអោយចុងចម្លើយបង់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ៥០០០ ដុល្លា ។

បានជានាងខ្ញុំសុំលែងលះដោយសាររស់នៅមិនចុះសម្រុងគ្នា ចុងចម្លើយពេលផឹកស្រវឹងតែងយកកាំបិទមកកាប់ផ្ទះគំរាមដល់នាងខ្ញុំជារឿយៗ មិនតែប៉ុណ្ណោះដេញនាងខ្ញុំចេញពីផ្ទះទៀតផង។ មូលហេតុទាំងនេះហើយធ្វើនាងខ្ញុំអស់មនោសញ្ចេតនារួមរស់ជាមួយចុងចម្លើយតទៅទៀតបាន ទើបដាក់ពាក្យសុំលែងលះតាមច្បាប់។

សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ : ខ្ញុំបាទសុំឯកភាពលែងលះតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ចំពោះកូនប្រុសម្នាក់ក៏ខ្ញុំបាទព្រមប្រគល់អំណាចមេបាអោយទៅដើមចោទដែរ ។ ចំណែកទ្រព្យសម្បត្តិដែលដើមចោទរៀបរាប់ខ្ញុំបាទមិនឯកភាពតាមទេ ពីព្រោះដីនេះគឺម្តាយខ្ញុំបាទគាត់ចែកអោយប្តីប្រពន្ធខ្ញុំបាទរស់នៅ ។ ចំពោះអាហារកិច្ចខ្ញុំបាទសុំចិញ្ចឹមកូនក្នុង ០១ ខែ ២០០,០០០រៀល។

ចំណុចវិវាទ : លែងលះ , ចែកទ្រព្យសម្បត្តិរួម , អាហារកិច្ច ។

តុលាការបញ្ឈប់នីតិវិធីត្រៀមទាញហេតុផល និង លើកយកមកធ្វើនិតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ វេលាម៉ោង ៨ ព្រឹក ។

បានអានអោយដើមចោទស្តាប់ថាត្រឹមត្រូវហើយ ។ សុខចិត្តផ្តិតមេដៃចំពោះមុខយើង ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង បីសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល ។

| ដើមចោទ | មេធាវី | ចុងចម្លើយ | ក្រឡាបញ្ជី | ចៅក្រម |
| --- | --- | --- | --- | --- |
| | | | ឡៀវ ដារណា | ជួន ចណ្ណា |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# កំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

សំណុំរឿងរដ្ឋប្បវេណី
លេខ ០២-០៥-២០១៩
សាលដីកា
លេខ
ចុះថ្ងៃទី ២៣-០៩-២០១៩

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកញ្ញា ថ្ងៃម្ភៃបី វេលាម៉ោងប្រាំបីនិងសាមសិបនាទីព្រឹក សភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្ដម ឃុន លាងម៉េង ប្រធានក្រុមប្រឹក្សា
លោក យូ ម៉ិនណា ចៅក្រមប្រឹក្សា
លោក លាង សំណាត់ ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក ទ៉ែត សារ៉ាត ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

**លោក សក ស័ក្ដិសម**

-ដើមចោទឈ្មោះ: [redacted] ភេទស្រី ថ្ងៃខែឆ្នាំកំណើត ៣០-១២-១៩៩៥ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ ។

-ចុងចម្លើយឈ្មោះ: [redacted] ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០២-១២-១៩៩០ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ ។

-អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ: [redacted] មេធាវី [redacted] ។

**នាពេលទាញហេតុផលដោយផ្ទាល់មាត់**

-ដើមចោទឈ្មោះ: [redacted] វត្តមាន
-ចុងចម្លើយឈ្មោះ: [redacted] អវត្តមាន
-មេធាវី [redacted] វត្តមាន

-មេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ: [redacted] បាន ធ្វើសេចក្ដីថ្លែងការណ៍ថា៖ កូនក្ដីខ្ញុំបាទបានប្ដឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ ។ ខ្ញុំបាទសូមបញ្ជាក់នូវមូលហេតុនៃការប្ដឹងឧទ្ធរណ៍ត្រង់ចំណុចនិមួយៗដូចតទៅ៖

ចំណុចទី៤ ទាក់ទងនឹងការឱ្យកូនក្តីខ្ញុំបាទ បង់អាហារកិច្ចចំនួន ២០០ ០០០ (ម្ភៃម៉ឺន) រៀល ក្នុងមួយខែ ឱ្យទៅដើមចោទ សម្រាប់ចិញ្ចឹមកូន រហូតដល់កូនមានវ័យនីតិភាព គឺកូនក្តីខ្ញុំបាទមិនសុខចិត្ត ដោយសុំបង់តាមលទ្ធភាពវិញ ព្រោះពុំមានលទ្ធភាព ប៉ុន្តែចម្លើយរបស់គាត់នៅក្នុងនីតិវិធីត្រៀមទាញហេតុផល គាត់យល់ព្រមបងតាមចំនួននេះ លុះក្រោយមក នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍សុំបងអាហារកិច្ចតាមលទ្ធភាពទៅវិញ ។

ចំណុចទី៦ ទាក់ទងនឹងការឱ្យកូនក្តីខ្ញុំបាទប្រគល់ម៉ូតូមួយគ្រឿង ម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ផ្លាកលេខ ប.ជ ទៅឱ្យដើមចោទ គឺកូនក្តីខ្ញុំបាទមិនសុខចិត្ត ដោយហេតុថា ម៉ូតូនេះ កូនក្តីខ្ញុំបាទខ្ចីប្អូនគាត់ជិះ ហើយឈ្មោះកម្មសិទ្ធិក៏ជាឈ្មោះប្អូនគាត់នៅឡើយដែរ ។

ចំណុចទី៧ ទាក់ទងនឹងការបង្គាប់ឱ្យកូនក្តីខ្ញុំបាទ ប្រគល់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ និងចំណុចទី៨ ទាក់ទងនឹងការបង្គាប់ឱ្យដើមចោទ និងកូនក្តីខ្ញុំបាទរួមគ្នាសងបំណុលរួម (ថ្លៃឈ្នួលជាង) ចំនួន ១.៩០០ (មួយពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ម្នាក់ពាក់កណ្តាល ចំណុចទាំងពីរនេះ ខ្ញុំបាទសូមបញ្ជាក់ជារួម គឺកូនក្តីខ្ញុំបាទបានអះអាងថា លុយថ្លៃធ្វើផ្ទះជាលុយរបស់ម្តាយឱ្យយមកមកធ្វើផ្ទះ ហើយចំណាយធ្វើផ្ទះអស់ប្រហែលចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក រីឯថ្លៃឈ្នួលជាងធ្វើផ្ទះបានទូទាត់អស់ហើយ ។ ម្តាយគាត់ក៏បានមកបំភ្លឺនៅក្នុងនីតិវិធីត្រៀមទាញហេតុផល ដោយបានបញ្ជាក់ថា គាត់បានប្រគល់លុយឱ្យចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ដូច្នេះ ការបង្គាប់ឱ្យកូនក្តីខ្ញុំបាទប្រគល់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ និងការឱ្យកូនក្តី ខ្ញុំបាទរួមគ្នាសងបំណុលរួមម្នាក់ពាក់កណ្តាល គឺមិនត្រឹមត្រូវទេ ដោយសារការទូទាត់គ្នាមក ឃើញថា នៅសល់តែប្រហែលចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ខ្ញុំបាទសំណូមពរបដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៦៨ (គ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសេចក្តីសម្រេចបញ្ចប់ ។

-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ចំពោះគាត់ប្តឹងឧទ្ធរណ៍នឹងចំណុចការបង់អាហារកិច្ច នាងខ្ញុំមិនព្រមទេ ដោយហេតុថា មិនមែនគាត់អត់លទ្ធភាពនោះឡើយ ព្រោះគាត់ធ្វើជាជាងឡាន ។ ចំពោះម៉ូតូវិញ គឺនាងខ្ញុំបានទិញពីប្អូនថ្លៃនាងខ្ញុំក្នុងតម្លៃ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក មិនមែនខ្ចីជិះទេ ប៉ុន្តែមិនបានធ្វើលិខិតទិញលក់ ហើយកាតគ្រីនៅនឹងនាងខ្ញុំ រីឯម៉ូតូនៅនឹងប្អូនថ្លៃនាងខ្ញុំ ។ ចំពោះការចំណាយធ្វើផ្ទះអស់ប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក មិនអស់ប្រហែលចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដូចការលើកឡើងរបស់មេធាវីទេ ដោយផ្ទះនេះសាងសង់អំពីថ្ម ប្រក់ស័ង្កសីទទឹង ៥ (ប្រាំ) ម៉ែត្រ គុណ ១៦ (ដប់ប្រាំមួយ) ម៉ែត្រ ហើយការសាងសង់ គឺប៉ា និងបងប្អូននាងខ្ញុំ ជាជាងសាងសង់ ។

នាងខ្ញុំបានទទួលប្រាក់ពីម្ដាយក្មេកនាងខ្ញុំ សម្រាប់សាងសង់ផ្ទះ មានចំនួន ៣ ០០០ (បីពាន់) ដុល្លារអាមេរិក តែប៉ុណ្ណោះ ។ ដូច្នេះ ការប្ដឹងឧទ្ធរណ៍របស់គាត់ មិនត្រឹមត្រូវទេ នាងខ្ញុំសូមបដិសេធទាំងស្រុង និងសំណូមពរតម្កល់សាលក្រមរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។

តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តំណាងមហាអយ្យការបានមកចូលរួមនាពេលទាញហេតុផលដោយផ្ទាល់មាត់នេះ គឺពាក់ព័ន្ធតែចំណុចការផ្ដល់អាហារកិច្ចតែប៉ុណ្ណោះ ។ ការដែលចៅក្រមសាលាដំបូងបានសម្រេចឱ្យចុងចម្លើយឈ្មោះ                    បង់អាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល មានលក្ខណៈត្រឹមត្រូវហើយ ព្រោះចុងចម្លើយមានមុខរបរ ហើយចំនួននេះ គឺមានភាពសមល្មមហើយ ។ ដូច្នេះ ចំណុចនេះ មិនគប្បីក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ សម្រេចធ្វើការកែប្រែឡើយ ។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ប្រកាសថយទៅពិចារណាសម្រេច និងចេញមកវិញប្រកាសសាលដីកា ។

### សំអាងហេតុ

១-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៩ របស់ចុងចម្លើយឈ្មោះ
ប្ដឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ៦៨ (គ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលា-ដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសេចក្ដីសម្រេចបញ្ចប់ ធ្វើឡើងក្នុងកំណត់ច្បាប់ ដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ផ្អែកតាមបញ្ញត្តិមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ភាគីចុងចម្លើយ បានធ្វើសេចក្ដីថ្លែងការណ៍អំពីមូលហេតុដែលភាគីខ្លួនប្ដឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ៦៨ (គ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសេចក្ដីសម្រេចបញ្ចប់ ដោយបញ្ជាក់ថា៖

ក-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួនបង់អាហារកិច្ច ក្នុងមួយខែ ចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល ឱ្យទៅភាគីដើមចោទសម្រាប់ចិញ្ចឹមកូន ដោយភាគីខ្លួនមិនសុខចិត្ត និងសុំបង់តាមលទ្ធភាពវិញ ដោយមូលហេតុថា ភាគីខ្លួនពុំមានលទ្ធភាព ប៉ុន្តែការលើកឡើងនេះ ត្រូវបានភាគីដើមចោទបដិសេធ ដោយបញ្ជាក់ថា ភាគីចុងចម្លើយមានមុខរបរជាជាងឡាន ដូច្នេះ ភាគីចុងចម្លើយពុំអលទ្ធភាពក្នុងការបង់អាហារកិច្ចក្នុងមួយខែ ចំនួន ២០០.០០០ (ម្ភៃម៉ឺន) រៀល ឡើយ ហើយចំណុចនេះ តំណាងមហាអយ្យការក៏ពុំឯកភាពផងដែរ ។

ខ-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួនប្រគល់ម៉ូតូ ១(មួយ) គ្រឿង ម៉ាកឌ្រីមសង់ ២០១៥ ពណ៌ខ្មៅ ផ្លាកលេខ ប.ជ ...      ទៅឱ្យដើមចោទ ដោយភាគីខ្លួន

មិនសុខចិត្ត និងបានលើកឡើងថា ម៉ូតូនេះ គឺភាគីខ្លួនខ្ចីប្អូនជិះប៉ុណ្ណោះ ប៉ុន្តែ ការលើកឡើងនេះ ត្រូវបានភាគីដើមចោទបដិសេធ ដោយបញ្ជាក់ថា ម៉ូតូនេះ ខ្លួនបានទិញពីប្អូនថ្លៃក្នុងតម្លៃ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ហើយការបញ្ជាក់នេះ មានភាពស្របគ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ (ប្អូនថ្លៃដើមចោទ) ដែលបានបំភ្លឺនៅក្នុងនីតិវិធីស៊ើបអង្កេតទាញហេតុផលនៅសាលាដំបូង ថា ខ្លួនពិតជាបានលក់ម៉ូតូខាងលើនេះ ឱ្យទៅដើមចោទ ក្នុងតម្លៃ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ប្រាកដមែន និងបានទទួលប្រាក់គ្រប់ចំនួនរួចហើយ ។

គ-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួន ប្រគល់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទ ដោយភាគីខ្លួនមិនសុខចិត្ត និងបានលើកឡើងថា លុយក្នុងការសាងសង់ផ្ទះ គឺជាលុយដែលម្តាយខ្លួនឱ្យពួកខ្លួនចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក យកមកសាងសង់ ហើយការសាងសង់នេះអស់ប្រាក់ប្រហែល ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ប៉ុន្តែការលើកឡើងនេះ ត្រូវបានភាគីដើមចោទបដិសេធ ដោយបញ្ជាក់ថា ការសាងសង់ផ្ទះនេះ ខ្លួនបានចំណាយអស់ប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហើយខ្លួនបានទទួលប្រាក់ពីម្តាយសម្រាប់សាងសង់ផ្ទះតែចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ប៉ុណ្ណោះ ។

ឃ-ការដែលសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចឱ្យភាគីខ្លួន និងដើមចោទរួមគ្នាសងបំណុលរួម (ថ្លៃឈ្នួលជាង) ចំនួន ១.៥០០ (មួយពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ម្នាក់ពាក់កណ្តាល ដោយភាគីខ្លួនមិនសុខចិត្ត និងបានលើកឡើងថា ថ្លៃឈ្នួលជាងក្នុងការសាងសង់ផ្ទះ បានទូទាត់រួចរាល់អស់ហើយ ប៉ុន្តែភាគីខ្លួនពុំមានភស្តុតាងបញ្ជាក់ពី ការទូទាត់ឡើយ ហើយការលើកឡើងនេះភាគីដើមចោទក៏មិនឯកភាពផងដែរ ។

៣-ផ្អែកតាមសំអាងហេតុខាងលើនេះ ក្រុមប្រឹក្សាជំនុំជម្រះសភាវដ្ឋប្បវេណីសាលាឧទ្ធរណ៍ ពិនិត្យឃើញថា ការទាមទាររបស់ភាគីចុងចម្លើយ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភាវដ្ឋប្បវេណីសាលាឧទ្ធរណ៍ សម្រេចឡើងជាថ្មី គ្រង់សេចក្តីសម្រេចបញ្ចប់ ចំណុច ទី៤, ទី៦, ទី៧ និងទី៨ នៃសាលក្រម មិនមានមូលហេតុត្រឹមត្រូវឡើយ គប្បីច្រានចោល ។

៤-រឿងក្តីនេះ ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ បានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះសភាវដ្ឋប្បវេណីសាលាឧទ្ធរណ៍ ឯកភាពតាមសំអាងហេតុរបស់ចៅក្រមសាលាដំបូង ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតឡើយ ។

៥-សេចក្តីសម្រេចបញ្ចប់នៃសាលក្រមរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ មានមូលហេតុត្រឹមត្រូវ គប្បីក្រុមប្រឹក្សាជំនុំជម្រះសភាវដ្ឋប្បវេណីសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ។

ចំណែកប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៩ របស់ចុងចម្លើយឈ្មោះ

។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ( ) ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុច ទី៤ ទី៦ ទី៧ និងទី៨ នៃសេចក្តីសម្រេចបញ្ចប់ ទុកជាបានការ ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៩ ។

បញ្ចប់កំណត់ហេតុ នៅវេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក ថ្ងៃខែឆ្នាំដដែល ។

ស្នាមមេដៃ លឹម ស្រីយ៉ាន ហត្ថលេខាមេធាវី ផាត់ សុផល

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| **សក ស័ក្តិសម** | **លាង សំណាត់, យូ ម៉ិនណា** | **ឃុន លាងម៉េង** |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ ថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ សាលា... ២៣ ខែកញ្ញា ឆ្នាំ២០១៩

ក្រឡាបញ្ជី

ឃុន_លាងម៉េង សក ស័ក្តិសម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ១៣៣ "ច"

## <u>ដីកាសម្រេច</u>

យើង **សេខ នាខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានឃើញមាត្រា ៩៧៩មាត្រា ១០៣៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ៨៦ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១៤ ដែលមាន៖

**អ្នកដាក់ពាក្យសុំ**

ឈ្មោះ **កសជ** ភេទស្រី កើតថ្ងៃទី ១៤ ខែឧសភា ឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ ទីលំនៅ បច្ចុប្បន្ន ផ្ទះលេខ១៣៧C ផ្លូវលេខ ៥៣BT សង្កាត់បឹងទំពន់ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី **គមស** ការិយាល័យមេធាវី **ក្រុមមេធាវីកម្ពុជាស្ពិត** នៅអគារលេខ១៥៩-១៦០ ផ្លូវលេខ១១៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ភាគីម្ខាងទៀត**

ឈ្មោះ **កណរ** ភេទប្រុសកើតថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៧២ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៣៧C ផ្លូវលេខ ៥៣BT សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ការទាមទាររបស់អ្នកដាក់ពាក្យសុំ ៖**

សុំដីកាសម្រេចលែងលះពីឈ្មោះ កណរ តាមកិច្ចព្រមព្រៀងលែងលះ។

## <u>សំអាងហេតុ</u>

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីសាកសួរឃើញថា ៖

១. ឈ្មោះ **កសជ** និងឈ្មោះ **កណរ** ពិតជាបានរៀបការ និងចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានក្នុងសេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍លេខ ៨៧ ឃ.ដ.៩ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ ១៩៩៥ប្រាកដមែន ។

២. ក្រោយពេលរៀបអាពាហ៍ពិពាហ៍ គឺពិតជារស់នៅមិនចុះសម្រុងនឹងគ្នា ដែលធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាមួយគ្នាប្រាកដមែន។ ម្យ៉ាងទៀត បើពិនិត្យលើកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៤ និងការអះអាងរបស់គូភាគី បញ្ជាក់ថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ ពិពាហ៍ប្រាកដមែន។

៣. ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍គូភាគីមានកូនបីនាក់មានឈ្មោះ **រសម** ភេទស្រី កើតថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៩៨ ឈ្មោះ **រសយ** ភេទស្រី កើតថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងឈ្មោះ **រដន** ភេទប្រុស កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៦ គូភាគីបានព្រមព្រៀងផ្ដាក់ណាត់យកឪពុកឈ្មោះ **អណរ** ជាអ្នកមានអំណាចមេបាលើកូនទាំងបីនាក់។

៤. អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដីតាមមាត្រា ២២ កថាខណ្ឌទី ៣ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

**១.** ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ **គសដ** ដែលមានអំណាចមេបាលើកូនឈ្មោះឈ្មោះ **រសម** ភេទស្រី កើតថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៨ ឈ្មោះ **រសយ** ភេទស្រី កើតថ្ងៃ ទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងឈ្មោះ **រដន** ភេទប្រុស កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៦ តាមការព្រមព្រៀងរបស់គូភាគី និងភាគីម្ខាងទៀតឈ្មោះ **គណរ** លែងលះគ្នា។ តាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៤

**ចៅក្រម**

ហត្ថលេខា និងត្រា **សេខ នាខ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
លេខ: ...... /២០២០

# លិខិតបញ្ជាក់សាលក្រមស្ថាពរ

យើង **ឃី អៀង** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្តាល។

បានឃើញ សាលក្រមលេខ: ........ ចុះថ្ងៃថ្ងៃទី ... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្តាល ។

បានឃើញ ពាក្យសុំបញ្ជាក់ការចូលជាសាលក្រមស្ថាពរនៃសាលក្រម ចុះថ្ងៃទី ........ ខែ ...... ឆ្នាំ ........ របស់មេធាវីឈ្មោះ .................... ជាមេធាវីតំណាងដោយអាណត្តិរបស់ឲ្យចុងចម្លើយ។

សូមបញ្ជាក់ថា សាលក្រមលេខ: ........ ចុះថ្ងៃទី ... ខែ ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្តាល បានចូលជាស្ថាពរពីថ្ងៃទី ...... ខែ ... ឆ្នាំ ........ តទៅហើយដោយភាគីពុំបានប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតបញ្ជាក់នេះ: ដើម្បីអនុញ្ញាតឲ្យដាក់របមន្តអនុវត្តលើសាលក្រមនេះ: សម្រាប់ភាគីសុំយកទៅអនុវត្តតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣
ខេត្តកណ្តាល , ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

ឃី . អៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង............

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង...........

-សំណុំរឿងរដ្ឋប្បវេណីលេខ ...........

ចុះថ្ងៃទី........ ខែ........ឆ្នាំ........

-សញ្ញាណរឿងក្តី : បណ្តឹងសុំលែងលះប្តី

-សាលក្រមរដ្ឋប្បវេណីលេខ : .........

ចុះថ្ងៃទី........ ខែ........ឆ្នាំ........

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

-បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

-បានប្រកាសសាលក្រម នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

### ចៅក្រមជំនុំជម្រះ

លោក ........................... **ចៅក្រម** សាលាដំបូង...........................

### ក្រឡាបញ្ជី

លោក ........................... **ក្រឡាបញ្ជី** សាលាដំបូង........................

-ដើមចោទឈ្មោះ ................ភេទ...... កើតនៅថ្ងៃទី...... ខែ........ ឆ្នាំ...... ជនជាតិខ្មែរ មុខរបរ .............. ទីលំនៅសព្វថ្ងៃនៅភូមិ........... សង្កាត់ ........... ក្រុង........... ខេត្ត............។

-ចុងចម្លើយឈ្មោះ ................ភេទ...... កើតនៅថ្ងៃទី...... ខែ........ ឆ្នាំ...... ជនជាតិខ្មែរ មុខរបរ .............. ទីលំនៅសព្វថ្ងៃនៅភូមិ........... សង្កាត់ ........... ក្រុង........... ខេត្ត............។

### អង្គហេតុ និងចំណុចវិវាទ

**I-ការទាមទាររបស់ដើមចោទ**

**+ដើមចោទបានប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រមសម្រេច :**

**១**-សុំលែងលះពីចុងចម្លើយឈ្មោះ ............ ។

**២**-សុំមានអំណាចមេបាលើកូនប្រុសឈ្មោះ ............ ។

**៣**-សុំឱ្យចុងចម្លើយផ្តល់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

**II-ការអះអាងរបស់គូភាគី :**

**ក/-ការអះអាងរបស់ដើមចោទ**

ដើមចោទឈ្មោះ ............បានធ្វើសេចក្តីថ្លែងការណ៍ថា :

**ខ/-ការអះអាងរបស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ ............ បានធ្វើសេចក្តីថ្លែងការណ៍ថា :

III -ចំណុចវិវាទ

-.......................................................................................................។

## សំអាងហេតុ :

**តាមលទ្ធផលនៃការសាកសួរសាម៉ីភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា :**

១-.......................................................................................................។

២-.......................................................................................................។

៣-.......................................................................................................។

៤-.......................................................................................................។

៥-.......................................................................................................។

៦-.......................................................................................................។

៧-.......................................................................................................។

## សេចក្តីសម្រេចបញ្ចប់

I-ឱ្យដើមចោទឈ្មោះ ................ លែងលះគ្នាពីចុងចម្លើយឈ្មោះ .............ចាប់ពីពេលនេះតទៅ។

II-ឱ្យដើមចោទឈ្មោះ ................ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ........................ ភេទ......កើតនៅថ្ងៃទី......ខែ...... ឆ្នាំ......។

III -ឱ្យចុងចម្លើយឈ្មោះ .................ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាព។

IV -ឱ្យចុងចម្លើយឈ្មោះ ........................ ទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា .....**

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

............ ថ្ងៃទ...... ខែ...... ឆ្នា......

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**